ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ក្រុមគ្រួសារដែលសុំធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ
- មរណភាពរបស់ នួន ជា ធ្វើឲ្យសន្តិភាពកាន់តែទូលំទូលាយជាងមុន

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៣៧ ខែកញ្ញា ឆ្នាំ២០១៩

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២៣៧ ខែកញ្ញា ឆ្នាំ២០១៩


## មាតិកា


### សំបុត្រ

◆ មរណភាពរបស់ នួន ជា ធ្វើឲ្យសន្តិភាព ....................................១

### ផ្នែកឯកសារ

◆ផែនការធ្វើបដិវត្តន៍ផ្តួលរំលំបក្សកុម្មុនីស្តកម្ពុជា ........................ ៤

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ ក្រុមគ្រួសារនាងខ្ញុំបានរងផលប៉ះពាល់ពី ............................... ៨

◆ ស៊ីម សឿង ...................................................................១០

◆ សិស្សនៅអនុវិទ្យាល័យក្រពើពីរ ក្នុងស្រុកវាលវែង .................១៣

◆ អតីតតំបន់គ្រាប់មីន និងកន្លែងលាក់ខ្លួនរបស់ ........................ ១៦

◆ ប្រវត្តិរបស់ នួន ជា .......................................................១៨

◆ ឧបទ្ទវហេតុកប៉ាល់ម៉ាយ៉ាហ្គេសនៅកោះតាង....................... ២៦

◆ ឯក សុផល អតីតគណៈតំបន់៣៧ ......................................៣៤

◆ ការបញ្ច្រៀបប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ..................៣៧

◆ មេភូមិ ស៊ឹម ចំរើន ........................................................៣៩

### ផ្នែកច្បាប់

◆ សេចក្តីសង្ខេបសាលក្រមសំណុំរឿង០០២/០២......................៤៧

### វេទិកាពិភាក្សាសាធារណៈ

◆ ក្រសួងអប់រំ យុវជន និងកីឡា៖ សៀវភៅ «អំពើប្រល័យ .........៥១

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆ ក្រុមគ្រួសារដែលបានស្នើសុំមាតុភូមិនិវត្តន៍ ...........................៥៨




ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ថ្លែងសុន្ទរកថា នៅក្នុងពិធីបើកសម្ពោធវិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្ទីករីត នៃវិទ្យាស្ថានជាតិអប់រំ


## វក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម,៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្ទេរលេខនេះ៖** លី សុខឃាង, ដាត ចាន់សុនិតា, គាត ស្រីឡែន, ផេង ពង្សរ៉ាស៊ី, សុង ថាណៃ, ព្រំ ផល្លា, ឡុង ដានី, **អ្នកនិពន្ធ និងស្រាវជ្រាវ៖** ហូ ថុនា, អ៊ុន សុដារី, ដារ៉ាវដ្ឋ មេត្តា **អ្នកបកប្រែ៖** អ៊ុន សុដារី **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន **ជំនួយការនិពន្ធនាយក៖** ហូ ថុនា **ក្រាហ្វិកកុំព្យូទ័រ៖** ដាត ចាន់សុនិតា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង



**Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# មរណភាពរបស់ នួន ជា ធ្វើឲ្យសន្តិភាព កាន់តែទូលំទូលាយជាងមុន

មរណភាពរបស់នួនជានាពេលថ្មីៗនេះ គឺជាការជំរុញដល់ការរំពឹងទុកចំពោះសន្តិភាព និងការផ្សះផ្សានៅក្នុងប្រទេសម្ពុជា។មេមនោគមន៍វិជ្ជាខ្មែរក្រហមមួយរូបនេះត្រូវបានប្រកាសថាស្លាប់ ដោយសាររោគជរាពាធ និងជំងឺរ៉ាំរ៉ៃនៅអាយុ៩៣ឆ្នាំនៅក្នុង មន្ទីរពេទ្យ នៅភ្នំពេញនៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩។ នួនជាគឺជាបងធំទីពីរបន្ទាប់ពីប៉ុល ពតដែលជាអតីតនាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩),នួនជាស្ថិតនៅក្នុងចំណោមមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដែលត្រូវបានកាត់ទោសនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងបទល្មើសផ្សេងៗទៀត។ ការគ្រប់គ្រងដ៏ផ្តាច់ការរបស់នួនជា ត្រូវបានទទួលស្គាល់ថាមានការទទួលខុសត្រូវចំពោះការបាត់បង់ជីវិតរបស់ប្រជាជនកម្ពុជាជិត២លាននាក់ចាប់ពីថ្ងៃទី១៧ ខែមេសាឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

នួន ជា បានស្លាប់មុនពេលបទចោទប្រកាន់ទាំងអស់ចំពោះខ្លួន ត្រូវបានវិនិច្ឆ័យនៅក្នុងការកាត់សេចក្តីវគ្គពីរ។ នៅថ្ងៃដែលគាត់ស្លាប់ខ្ញុំកំពុងនៅក្នុងស្រុកអន្លង់វែង ដែលជាតំបន់កាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម ជាមួយមិត្តរួមការងារម្នាក់ទៀតរបស់ខ្ញុំ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។នៅពេលដែលត្រឡប់មកភ្នំពេញវិញ មិត្តម្នាក់បានសួរខ្ញុំថា តើខ្ញុំបានសង្កេតឃើញថា តើអតីតកម្មាភិបាលខ្មែរក្រហមដែលរស់នៅក្នុងស្រុកអន្លង់វែងបានដឹងអំពីមរណភាពរបស់នួន ជា ដែរឬទេ ហើយតើឥឡូវនេះពួកគេនឹងពិចារណាចូលរួមពិធីបុណ្យសពរបស់នួន ជានៅប៉ៃលិនដែលជាតំបន់កាន់កាប់ចុងក្រោយ របស់ខ្មែរក្រហមមួយទៀតនៅភូមិភាគពាយ័ព្យដែរឬទេ។ ចាប់តាំងពីពេលនោះមកខ្ញុំបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះរឿងមួយនេះ។ ដូចដែលត្រូវបានរាយការណ៍ពីខេត្តប៉ៃលិន សពរបស់ នួន ជា ត្រូវបានបូជាដោយមានវត្តមានតិចតួចពីអតីតមេបញ្ជា ការយោធា និងកម្មាភិបាលខ្មែរក្រហមបើប្រៀបធៀបទៅនឹងពិធីបុណ្យសពរបស់ អៀង សារី ដែលជាអតីតរដ្ឋមន្ត្រីក្រសួងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ កាលពីខែមីនា ឆ្នាំ២០១៣។ វត្តមានរបស់អ្នកកាន់ទុក្ខនៅក្នុងពិធីដង្ហែសពរបស់ នួន ជា ឆ្លុះបញ្ចាំងអំពីសំណុំរឿង និងសាលដីការរបស់គាត់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។



នួន ជា មេដឹកនាំជាន់ខ្ពស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ជាការពិតណាស់ សហការីទាំងឡាយរបស់ នួន ជា ប្រាថ្នាចង់ឃ្លាតឆ្ងាយពីអតីតមេដឹកនាំរបស់ខ្លួនដែលត្រូវបានគេចោទប្រកាន់ទោសជាសាធារណៈ និងមានកេរ្តិ៍ឈ្មោះអាប់ឱន។នេះគឺជាសក្ខីកម្មបញ្ជាក់អំពីប្រសិទ្ធភាព នៃដំណើរការរបស់អង្គជំនុំជ្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានផ្ទៀងផ្ទាត់បញ្ជាក់នូវមូលដ្ឋានគ្រឹះនៃការពិតអំពីភាពសាហាវឃោរឃៅរបស់ខ្មែរក្រហម។ តាមរយៈនីតិវិធីច្បាប់ សូម្បីតែអតីតកម្មាភិបាលខ្មែរក្រហម និងឯកសារភ័ស្តុតាងបានទទួលស្គាល់អំពីតួនាទីផ្ទាល់របស់ នួន ជា និងមេដឹកនាំជាន់ខ្ពស់ដទៃទៀតក្នុងការបោសសម្អាតជាប្រព័ន្ធ ដើម្បីប្រឆាំងនឹងសត្រូវខាងក្នុងនិងខាងក្រៅ ដែលបណ្តាលឲ្យមានអំពើប្រល័យពូជសាសន៍កើតឡើង។

មរណភាពរបស់ នួន ជា គឺជាការបញ្ជាក់អំពីការដើតជាមរបស់ខ្មែរក្រហមដែលបានថមថយយ៉ាងខ្លាំង។ សែសិបឆ្នាំមុនឬក៏ម្ភៃឆ្នាំមុនអ្នកគាំទ្ររបស់ នួន ជា បានមានមោទនភាពយ៉ាងខ្លាំង ដែលខ្លួនត្រូវបានសាធារណជនមើលឃើញថាមានទំនាក់ទំនងជិតស្និទ្ធជាមួយមេដឹកនាំរបស់ខ្លួន។ ប៉ុន្តែបន្ទាប់ពីដំណើរនៃការជំនុំជម្រះដ៏វែងឆ្ងាយដែលបានបង្ហាញអំពីការពិតនៃការទទួលខុសត្រូវទើប នួន ជា បានផ្លាស់ប្តូរទៅជាពិរុទ្ធជនដែលគ្មានអំណាច និងត្រូវបានអតីតកម្មាភិបាលខ្មែរក្រហមរបស់ខ្លួនមិនយកចិត្តទុកដាក់ និងមើលងាយ។

វាគឺជារឿងធម្មតាទេ នៅគ្រប់ទីកន្លែងទាំងអស់នៅក្នុងពិភពលោក ដែលការស្លាប់របស់អតីតមេដឹកនាំក្នុងប្រទេសមិនទទួលបានសេចក្តីអំណរ ឬភាពសុទិដ្ឋិនិយមជាថ្មី។ ជាធម្មតា សូម្បីតែចំពោះមេដឹកនាំដែលមានរឿងអាស្រូវក៏ដោយសេចក្តីស្លាប់របស់មេដឹកនាំទាំងនោះគឺជាពេលវេលាមួយប្រកបដោយភាពខ្សឹបខ្សួលនិងការចងចាំ។ប៉ុន្តែសេចក្តីស្លាប់របស់នួនជាគឺខុសគ្នា។ នួន ជា គឺជាមេដឹកនាំហើយក៏ជាប្រធានសភាតំណាងប្រជាជនកម្ពុជា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ប៉ុន្តែគ្មានហេតុផលណាមួយគួរតែសញ្ជឹងគិតអំពីភាពវិជ្ជមានអំពីអ្វីដែល នួន ជា បានបន្សល់ទុកនោះទេ។ជាតិនិយម គឺមានអត្ថប្រយោជន៍ហើយនៅក្នុងចំណោមនោះគឺការគោរពចំពោះអតីតមេដឹកនាំ។ ប៉ុន្តែយើងត្រូវតែប្រុងប្រយ័ត្ន។ នេះគឺជាការលើកទឹកចិត្តចំពោះការគោរពមេដឹកនាំនយោបាយថ្មី ហើយក៏ជាការដាស់ស្មារតីដល់អ្នកដែលធ្វើការឲ្យរដ្ឋាភិបាលមេដឹកនាំទាំងនោះថា ពួកគេគួរតែរក្សាការគាំទ្ររបស់ខ្លួន ទោះបីជានៅក្នុងកាលៈទេសៈល្អ ឬក៏អាក្រក់។ វាហាក់បីដូចជាការអត្ថាធិប្បាយអវិជ្ជមានទៅលើរដ្ឋាភិបាលនេះ ប្រសិនបើនៅពេលដែលមេដឹកនាំបាត់បង់អំណាចធ្វើឲ្យមានការបែកបាក់ ព្រោះតែការស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួន និងមានការបដិសេធការចូលរួមជាមួយអតីតមេដឹកនាំរបស់ខ្លួន។ ប៉ុន្តែពេលវេលានេះគឺខុសគ្នា។

ខ្ញុំឃើញថាមរណភាពរបស់ នួន ជា គឺជាសញ្ញាថ្មីមួយនិងល្អ ដែលបង្ហាញថាការខិតខំប្រឹងប្រែងរបស់ជាតិដើម្បីសន្តិភាពទីបំផុតទទួលបានជ័យជម្នះធំធេងមួយ។មរណភាពរបស់ នួន ជា បានបញ្ជាក់អំពីការបដិសេធទៅលើមនោគមវិជ្ជាដែលមានជាយូរមកហើយនៅក្នុងប្រទេស។ នួន ជា បានបាត់បង់ឱកាសក្នុងជីវិតរបស់ខ្លួនព្រមទាំងការរំពឹងទុករបស់អ្នកគាំទ្រ ដែលគិតថានឹងអាចមានការផ្លាស់ប្តូរដ៏ចៃដន្យមួយដែលអាចធ្វើឲ្យចលនារបស់ពួកគេរស់ឡើងវិញ។

យ៉ាងណាវិញ នួន ជា គឺពោរពេញដោយឧបាយកល។ នួន ជា អាចបំភ្លៃរឿងរ៉ាវផ្សេងៗដើម្បីផ្លាស់ប្តូរមតិសាធារណៈជនចំពោះខ្លួន និងបង្វែរមតិផ្សេងៗតាមរយៈអ្នកស្រាវជ្រាវ អ្នកយកព័ត៌មាន និងមធ្យោបាយផ្សេងទៀត។ មរណភាពរបស់នួនជាគួរតែធ្វើឲ្យអ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមមានភាពធូរស្បើយនៅក្នុងចិត្ត និងដឹងថាការវិលត្រឡប់មករកការកាន់អំណាចវិញរបស់ខ្មែរក្រហមគឺមិនអាចទៅរួចនោះទេ។ ចំនួនដ៏តិចតួចនៃអ្នកដែលកាន់ទុក្ខការស្លាប់របស់ នួន ជា គឺជាការបង្ហាញថាសន្តិភាព នៅក្នុងប្រទេស គឺទទួលបានជ័យជម្នះលើលទ្ធភាពនៃការបញ្ចេះឡើងវិញនៃជម្លោះ។

**លី សុខឃាង**

# កាលវិភាគបញ្ចាំងខ្សែភាពយន្តឯកសារ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា







បញ្ចាំងរៀងរាល់ថ្ងៃសុក្រ
វេលាម៉ោង១០:០០ ព្រឹក
ទីតាំងនៅវិចិត្រសាលសិល្បៈ
សហសម័យវិទ្យាស្ថានស្លឹករឹត
អគារ H នៃវិទ្យាស្ថានជាតិអប់រំ
(មហាវិថីព្រះសីហនុ
រាជធានីភ្នំពេញ)










វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត ដែលមានទីតាំងស្ថិតនៅក្នុងអគារ H នៃវិទ្យាស្ថានជាតិអប់រំ ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីស្នាដៃសិល្បៈ និងវប្បធម៌តាមរយៈការតាំងពិព័រណ៍ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានាៗ ជារួម វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើកកម្ពស់និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់កសាងឡើងក្នុងរជ្ជកាលបារាំង សម្រាប់ការដាក់តាំងពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង ស៊ាន ចិន្តា ទូរសព្ទលេខ ០២៣ ២១១ ៨៧៥ អ៊ីម៉ែល truthchenda.s@dccam.org

# ផែនការធ្វើបដិវត្តន៍ផ្តួលរំលំបក្សកុម្មុយនីស្តកម្ពុជា

ខ្ញុំបាទឈ្មោះ ឥន សារ៉ុន ហៅ ថុល មានស្រុកកំណើតរស់នៅភូមិចំបក់ពាមឃុំស្វាយរៀង ស្រុកប្រសូត្រតំន់២៣។ ខ្ញុំមានអាយុ២៧ឆ្នាំ (នៅឆ្នាំ១៩៧៨)។នៅឆ្នាំ១៩៦៣ខ្ញុំរៀនបានត្រឹមថ្នាក់ទីនៅវិទ្យាល័យកំពង់រោទ៍។ ក្រោយមកដោយសារមានរដ្ឋប្រហារនៅថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ ខ្ញុំក៏បានឈប់រៀនហើយចូលធ្វើបដិវត្តន៍ជាមួយខ្មែរក្រហម។ អំឡុងពេលនោះឈ្មោះ សូ ដែលជាលេខាតំបន់២៣ បានចាត់តាំងខ្ញុំឲ្យទៅធ្វើជាកងការពារនៅមន្ទីរស្រុក។ ក្រោយមក សូ បានបញ្ចុះបញ្ចូលខ្ញុំឲ្យចូល សេ.អ៊ី.អា ដោយលើកឡើងពីការលំបាកនៃការធ្វើវដិវត្តន៍ ដែលមានភាពអន់ថយជាងសង្គមចាស់។ នៅខែធ្នូ ឆ្នាំ១៩៧០ សូ ក៏បានបញ្ចូលខ្ញុំជា សេ.អ៊ី.អា ជាមួយ យ៉ាន បច្ចុប្បន្នប្រធានពេទ្យ តំបន់២៣, សំអឿន សមាជិកស្រុក,សាត យុទ្ធជនប្រធានវរសេនាធំ១១២ តំបន់២៣។ អំឡុងពេលនោះ ខ្ញុំមានភារកិច្ចជានីរសារសម្រាប់ទាក់ទងខ្សែ សេ.អ៊ី.អា។

បន្ទាប់ពីខ្មែរក្រហមឡើងគ្រប់គ្រងអំណាច នៅថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥ សូ បានបើកកិច្ចប្រជុំផែនការជាមួយខ្សែបណ្តាញក្នុងក្រុមនៅផ្ទះរបស់គាត់ ដែលមានកងការពារមួយក្រុមនៅចាំយាមល្បាត។ ក្រោយពី សូ បានណែនាំរួចខ្ញុំបានពិភាក្សាជាមួយសមាជិកក្រុមដើម្បីត្រៀមខ្លួនធ្វើសកម្មភាព។ ក្រុមខ្ញុំបានលួចលាក់ស្រូវ២.០០០ ថាំងនៅក្នុងជង្រុកស្រូវរបស់តំបន់២៣ ដោយមិនរាយការណ៍ឲ្យអង្គការបាន




វត្តបឹងរាំ ស្ថិតក្នុងស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ដែលត្រូវបានខ្មែរក្រហមជ្រើសរើសធ្វើជាមន្ទីរសន្តិសុខ សម្រាប់ឃុំឃាំងអ្នកទោស។

ដឹងឡើយ។ ក្រៅពី នេះខ្ញុំបានលាក់សាំង២០ពុយនៅឃ្លាំងពាណិជ្ជកម្មតំបន់២៣ ដើម្បីទុកត្រៀមធ្វើរដ្ឋប្រហារបក្សកុម្មុយនីស្តកម្ពុជានៅដើមឆ្នាំ១៩៧៦។ ។ ក្រុមខ្ញុំបានលួចលក់ស្រូវទៅឲ្យយួន១.០០០បាវនៅដើមឆ្នាំ១៩៧៦។ ក្រោយមកទៀតក្រុមខ្ញុំក៏បានធ្វើវិទ្ធង្សនកម្មលួចដុតស្រូវនៅតាមព្រំដែន អស់ចំនួន២០ហិកតានិងបានលួចលាក់ស្រូវបាន១.៥០០បាវ បន្ថែមទៀតនៅជង្រុកស្រូវរបស់ឃុំត្រពាំងលាចស្រុកកំពង់រោទ៍។ អង្គការ និងផែនការលួចបាញ់សម្លាប់កម្មាភិបាលបដិវត្តន៍។

នៅខែឧសភា ឆ្នាំ១៩៧៦ សូ បានប្រមូលបក្ខពួកទាំងអស់មកប្រជុំដោយបានលើកឡើងពីផែនការបន្តធ្វើរដ្ឋប្រហារ។នៅក្នុងផែនការនេះត្រូវត្រៀមស្បៀងគ្រាប់រំសេវ និងឡានសម្រាប់ដឹកជញ្ជូន។ជាពិសេសសូ បានឲ្យសមាជិកត្រៀមសព្វាវុធសម្រាប់ធ្វើរដ្ឋប្រហារ ព្រមទាំងទាក់ទងជាមួយវៀតណាមជាកម្លាំងជំនួយ។ មួយវិញទៀតសូបានឲ្យបង្កប់គ្រាប់



**ព្រះវិហារវត្តបឹងវែ ស្ថិតក្នុងស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ដែលត្រូវបានខ្មែរក្រហម ជ្រើសរើសធ្វើជាមន្ទីរសន្តិសុខសម្រាប់ឃុំឃាំងអ្នកទោស**

ក្រុមរបស់ខ្ញុំបានលួចធ្វើសកម្មភាពបែបនេះ ជាច្រើនលើកច្រើនសារ។ សូ បានបញ្ជាឲ្យសមាជិកនៅក្នុងក្រុមទាក់ទងជាមួយវៀតណាម ដើម្បីត្រៀមខ្លួនធ្វើរដ្ឋប្រហារនៅខែ មេសា ឆ្នាំ១៩៧៦។ នៅខែមីនា ឆ្នាំ១៩៧៦ ក្រុមខ្ញុំបានប្រជុំដោយបានលើកផែនការដូចជា ជ្រើសរើសកម្លាំងចេញពីអ្នកដែលមិនពេញចិត្តចំពោះបដិវត្តន៍ផែនការលួចលាក់ស្បៀង និងលក់ស្បៀងទៅឲ្យវៀតណាម ផែនការលួចបំផ្លាញសេដ្ឋកិច្ច មីនតាមថ្នល់ ដើម្បីកម្ទេចឡានយោធា ខ្មែរក្រហមហើយសូក៏បានចាត់តាំងឲ្យបក្ខពួកលួចបាញ់សម្លាប់ និងបំពុលកម្មាភិបាលខ្មែរក្រហម។

នៅចុងខែមករា ឆ្នាំ១៩៧៨ សូបានចាត់តាំងឲ្យខ្ញុំរៀបចំកម្លាំងការពារ១០នាក់ ដើម្បីជូន សូ ទៅប្រជុំផែនការណ៍ជាមួយវៀតណាមក្នុងផ្ទះសម្ងាត់របស់ សូ នៅក្នុងឃុំត្រពាំងលាចស្រុកកំពង់រោទ៍។ ពេលនោះ ខ្ញុំក៏បានណែនាំថុនមេក្រុម

កងការពារមន្ទីរតំបន់២៣ ឲ្យយកកម្លាំងក្នុងក្រុមទាំងអស់មកយាមការពារ។ សមាសភាពប្រជុំពេលនោះខាងយួនមាន បៃការ ហុក និងម្នាក់ទៀតខ្ញុំមិនស្គាល់ឈ្មោះមានតួនាទីជាប្រធានយោធាខេត្តតៃនិញ។ ចំណែកខ្មែរមាន សូលេខាតំបន់២៣,គួនអនុលេខាតំបន់២៣,កែវសំណាងហៅ ម៉ុន ប្រធានសេនាធិការយោធាភូមិភាគបូព៌ា, ឆែម ប្រធានសេនាធិការយោធាតំបន់២៣,ស៊ែលប្រធានកងពលតំបន់២៣,សាម៉ន, ផន,ថាន់ និង ម៉ាន។

កិច្ចប្រជុំនេះស្តីអំពី ការរៀបចំផែនការធ្វើរដ្ឋប្រហារផ្តួលរំលំបក្សកុម្មុយនីស្តកម្ពុជា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨។តាមរយៈកិច្ចប្រជុំនេះខ្ញុំបានដឹងអំពីផែនការរបស់វៀតណាមក្នុងការវាយលុកខ្មែរក្រហម និងផែនការត្រៀមខ្លួនធ្វើរដ្ឋប្រហាររបស់បក្ខពួកខ្ញុំ ក្នុងការផ្តួលរំលំបក្សកុម្មុយនីស្តកម្ពុជា។ ក្នុងនោះវៀតណាមបានលើកយកមុខព្រួញ២ជាសំខាន់ ៖ មុខព្រួញទី១) គឺចូលមកបារិត តាមបណ្តោយផ្លូវជាតិលេខ១ ហើយមកជួបគ្នាជាមួយក្រុមខ្ញុំនៅស្រុកប្រសូត្រ។ មុខព្រួញទី២) គឺមានគោលដៅវាយយកទីក្រុងស្វាយរៀងឲ្យបាន។ ចំពោះមុខព្រួញនីមួយៗវៀតណាមយកកងទ័ពស្រួចមជ្ឈិមបក្សរបស់ប្រទេសវៀតណាមមួយកងពល មកធ្វើជាកម្លាំងស្នូលហើយឲ្យកងទ័ពខេត្តតាយនិញ និងឡុងអានជួយជាកម្លាំងបន្ថែម។នៅពាក់កណ្តាលខែកុម្ភៈ ឆ្នាំ១៩៧៨ គណៈយោធាខេត្តតៃនិញបានសួរអំពីសភាពការណ៍យោធា របស់បក្សកុម្មុយនីស្តកម្ពុជាទាក់ទងនឹងចំនួន កម្លាំងទ័ពប្រភេទអាវុធនិងរថក្រោះនៅតាមព្រំដែន និងនៅក្រុងស្វាយរៀង។ខាងវៀតណាមចង់ដឹងអំពីផែនការ របស់បក្សកុម្មុយនីស្តកម្ពុជាថានឹងវាយលុកទៅលើប្រទេសវៀតណាមថ្ងៃណា?

តាមរយៈការណែនាំរបស់ សូ ខ្ញុំក៏បានរាយការណ៍ប្រាប់ទៅខាងវៀតណាមវិញថា កងកម្លាំងទ័ពរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាមានចំនួនច្រើន មានរថក្រោះ១០គ្រឿងមានកាំភ្លើងធំច្រើន ហើយកងទ័ពស្រួចរបស់អង្គការខ្មែរក្រហមអូសកាំភ្លើង១៣០ចល័តជាប់រហូតដោយមិននៅតែមួយកន្លែងទេ។ ចំណែកសភាពការណ៍ខាងក្នុងខ្សែបណ្តាញរបស់ក្រុមខ្ញុំកំពុងតែត្រូវបានអង្គការស្រាវជ្រាវតាមដាន និងចាប់ខ្លួនជាបន្តបន្ទាប់។ដូច្នេះការរៀបចំផែនការធ្វើរដ្ឋប្រហារផ្តួលរំលំបក្សកុម្មុយនីស្តកម្ពុជា ពិតជាមានការលំបាក។ បើទោះបីជាលំបាកយ៉ាងណាក៏ដោយបក្ខពួកខ្ញុំនឹងខិតខំអនុវត្តន៍ផែនការធ្វើរដ្ឋប្រហារនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៨ ខាងមុខនេះឲ្យបានសម្រេច។

ខាងខ្ញុំស្នើសុំខាងវៀតណាមជួយផ្តល់ជាកម្លាំង និងអាវុធដើម្បីត្រៀមខ្លួនធ្វើរដ្ឋប្រហារ។ បន្ទាប់ពីខ្ញុំបានរាយការណ៍ហើយវៀតណាមក៏បានឲ្យត្រៀមរៀបចំសម្ភារ កម្លាំង ស្បៀងនិងឧបករណ៍ដឹកជញ្ជូនសម្រាប់អនុវត្តផែនការ។

ក្រោយមក នៅក្នុងខែកុម្ភៈ ឆ្នាំដដែល សូ បានឲ្យខ្ញុំ និង ថាន់ប្រធានកងការពារ ដឹកអាវុធចំនួនឡានទៅឲ្យវៀតណាមក្នុងនោះមានកាំភ្លើងបេ៤០, បេ៤១, ដេកា៧៥, ដេកា៨២និងកាណុង១២០មីលីម៉ែត្រ។ចុងខែកុម្ភៈឆ្នាំ១៩៧៨ខ្ញុំបានធ្លាក់ខ្លួនឈឺ ហើយខ្ញុំបានដេកព្យាបាលនៅមន្ទីរពេទ្យតំបន់២៣ រហូតដល់ថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧៨។

សូ ត្រូវបានអង្គការដកឲ្យទៅធ្វើជាលេខាតំបន់២៤ ហើយគាត់ក៏បាននាំខ្ញុំទៅជាមួយដែរ។ ខ្ញុំទៅនៅជាមួយ សូ បាន៤ថ្ងៃអង្គការបានចាប់ខ្លួន សូ នៅថ្ងៃទី១៦ខែមីនា ឆ្នាំ១៩៧៨។ ក្រោយពីការចាប់ខ្លួនសូបានមួយថ្ងៃ អង្គការក៏បានចាប់ខ្លួនខ្ញុំនៅព្រឹកថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៨។

**ផាត ចាន់សុនិតា**

***កំណត់ចំណាំ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់ដែលជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានឡើយថាចម្លើយរបស់ ឥន សារ៉ុន ហៅ ថុល នេះពិតឬយ៉ាងណានោះទេ។***

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរគឺ ជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លូនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ប្រាំបី ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ ដល់ម៉ោង៥។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង យី សុឃី តាមរយៈទូរសព្ទលេខ៖ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល៖ truthsokhy.y@dccam.org។






























# ក្រុមគ្រួសារនាងខ្ញុំបានរងផលប៉ះពាល់ពីរបបខ្មែរក្រហម

នាងខ្ញុំឈ្មោះ គាត ស្រីខ្មែន កើតនៅឆ្នាំ១៩៩៦ នៅភូមិដីដុះ ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម មានឪពុកឈ្មោះ គាត ណាត និងម្តាយឈ្មោះ ឡុង ចាន់ណា ។នៅក្នុងឆ្នាំ២០០៤ខណៈពេលដែលនាងខ្ញុំមាន អាយុទើប ៨ ឆ្នាំម្តាយខ្ញុំបានស្លាប់ដោយសារជំងឺរុំារ៉ៃដែលបង្កឡើងតាំង ពីក្នុងរបបខ្មែរក្រហម១៩៧៥-១៩៧៩។ ការបាត់បង់ម្តាយ នេះបានបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់ជីវិតរស់នៅ របស់ខ្ញុំ និងបានធ្វើឲ្យរូបខ្ញុំក្លាយជាក្មេងកំព្រារស់នៅជាមួយជីដូនរហូ តមកដល់សព្វថ្ងៃ។ ខាងក្រោមគឺជាការរៀបរាប់របស់ជីដូន ខ្ញុំនៅក្នុង របបខ្មែរក្រហម ៖

ជីដូនរបស់ខ្ញុំឈ្មោះ គ្រី វួចលាង មានអាយុ៦៨ឆ្នាំ បានរៀបការជាមួយជីតាខ្ញុំឈ្មោះ ឆាយ ស៊ាងឡុង នៅភូមិដី ដុះឃុំពាមកោះស្នាស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ក្នុងឆ្នាំ១៩ ៧៣។ជីដូនជីតាខ្ញុំមានកូនចំនួន៤នាក់ (កូនប្រុស២នាក់ និង កូនស្រី២នាក់)។ ម្តាយខ្ញុំជាកូនទី២បានកើតក្នុងនៅ ខែវិច្ឆិកា ឆ្នាំ១ ៩ ៧ ៦ គឺបន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចប្រមាណ ជាជាងមួយឆ្នាំ។ បន្ទាប់ពីខ្មែរក្រហមឡើងកាន់កាប់អំណាច នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅភូមិដីដុះក៏ដូចជាភូមិដ៏ ទៃទៀតនៅទូទាំងប្រទេសដែរខ្មែរក្រហម បានប្រមូលទ្រព្យ សម្បត្តិឯកជនទាំងអស់យកទៅដាក់រួមនៅក្នុងសហករណ៍។ ខ្មែរក្រហម ក៏ចាប់ផ្តើមបែងចែកប្រជាជនឲ្យរស់នៅធ្វើការ តាមកងតាមក្រុមរៀងៗខ្លួន។ ជីដូនរបស់ខ្ញុំត្រូវបានចាត់តាំង ឲ្យរស់នៅនឹងធ្វើការនៅក្នុងកងមីង។ ដែលមានសមាជិកសុទ្ធ តែជានារីដែលមានគ្រួសាររួចហើយចំនួនពី១៨ ទៅ ២០នាក់ ។ចំណែកជីតារបស់ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការ ក្នុងកងភ្ជួរ និងដឹកជញ្ជូនបន្លែតាមរទេះគោទៅឲ្យកងចល័ត ហូបចុកនៅ កន្លែងធ្វើការងារឆ្ងាយៗពីភូមិដូចជានៅស្រណាបខ្ចី នៅអូរ កាប់មាន់និងកន្លែងឆ្ងាយៗផ្សេងទៀត។ ការដឹកជញ្ជូននេះគឺ មានរយៈពេលរហូតទៅដល់មួយសប្តាហ៍ឬ១០ ថ្ងៃទើបត្រឡ ប់មកភូមិជួបប្រពន្ធម្តង។ ជីដូន និងជីតារបស់ខ្ញុំមិនសូវបាន ជួបជុំគ្នាទេនៅក្នុងរបបខ្មែរក្រហមព្រោះពួកគាត់ត្រូវបំពេញ ការងាររៀងៗខ្លួន គឺខ្មែរក្រហមមិនអនុញ្ញាតឲ្យឈប់សម្រាក នៅមើលថែប្រពន្ធកូនឡើយទោះបីជាទើបតែសម្រាលកូនរួច ក៏ដោយ។ នៅក្នុងឆ្នាំ១៩៧៦ នៅខណៈពេលដែលជីដូនខ្ញុំ មានផ្ទៃពោះកូនទី២ (ម្តាយរបស់ខ្ញុំ) គាត់ត្រូវបានគណៈសហករណ៍ខ្មែរក្រហមឈ្មោះ ហន និង អង្គត់ ចាត់តាំងឲ្យរែកទឹក ស្រោចកូនថ្នាំជក់ (នៅក្នុងភូមិដីដុះត្រូវបានខ្មែរក្រហមចាត់ តាំងឲ្យប្រជាជនដាំដំណាំថ្នាំជក់ សម្រាប់ផ្គត់ផ្គង់ដល់កម្មាភិ បាលខ្មែរក្រហមដែលជក់បារី និងបុកថ្នាំជក់)។ នៅពេលធ្វើ ការងាររែកទឹកស្រោចកូនថ្នាំជក់នោះជីដូន ខ្ញុំបានរអិលដួល ជាញឹកញាប់ប៉ុន្តែអ្វីដែលគួរឲ្យចាប់អារម្មណ៍នោះ គឺនៅ ខណៈពេលដែលជីដូនរបស់ខ្ញុំមានផ្ទៃពោះបាន៨ខែហើយខ្មែរ ក្រហម នៅតែចាត់តាំងឲ្យរែកទឹកស្រោចកូនថ្នាំជក់ដដែល ជាអកុសលគាត់បានរអិលដួលអុកគូថយ៉ាងខ្លាំង ទៅលើដី



គាត ស្រីខ្មែន

ហើយប៉ុន្មានថ្ងៃក្រោយមកគាត់ក៏សម្រាលបានម្តាយខ្ញុំ។

ជីដូនខ្ញុំមានប្រសាសន៍ថា នៅអំឡុងពេលមានផ្ទៃពោះម្តាយខ្ញុំធ្លាប់មានកម្មាភិបាលខ្មែរក្រហម ទិតៀនគាត់ថាជាពួកនាយទុនមិនធ្លាប់ធ្វើការងារធ្ងន់ធ្ងរ ហើយពេលអង្គការចាត់តាំងឲ្យធ្វើការងារ គឺធ្វើចុងដៃចុងជើង មិនខិតខំធ្វើឲ្យសម្រេចតាមផែនការរបស់អង្គការដាក់ទិសឲ្យនោះទេ។ ដោយសារការទិតៀននេះជីដូនខ្ញុំមានការភ័យខ្លាច ខ្មែរក្រហមសម្លាប់នោះដូច្នេះហើយ គាត់ត្រូវតែខិតខំធ្វើការងារធ្ងន់ធ្ងរ



លោកយាយ គ្រី វួចលាង ត្រូវជាយាយរបស់ស្រីខ្មែន

ឲ្យដូចសមាជិក ក្នុងកងដែលមិនមានផ្ទៃពោះ។ នៅពេលជីដូនខ្ញុំសម្រាលបានម្តាយខ្ញុំ គឺម្តាយខ្ញុំមាន បញ្ហាកជើងផ្នែកខាងស្តាំគឺមានឆ្អឹងកោងសំប៉ែតហើយមាន សុខភាពខ្សោយខុសពីទារកធម្មតា។ជីដូនខ្ញុំមានប្រសាសន៍ថាម្តាយខ្ញុំ ប្រហែលជាមានបញ្ហាសុខភាពនេះដោយសារខ្មែរក្រហម បង្ខំគាត់ឲ្យធ្វើការហួសកម្លាំងនិងត្រូវរអិលដួលជាញឹកញាប់ នៅអំឡុងពេលដែលគាត់មានផ្ទៃពោះ ទើបបានជាម្តាយខ្ញុំ ប្រែទៅជាបែបនេះ។បន្ទាប់ពីសម្រាលកូនបានរយៈពេលបីខែ ខ្មែរក្រហមបានចាត់តាំងឲ្យជីដូនខ្ញុំ ចេញទៅកាស់គល់ឈើដើម្បីរានដីធ្វើស្រែ, ជីកប្រឡាយ, រែកដីលើកទំនប់ និងធ្វើការងារតាមវាលស្រែនៅខាងក្រោយភូមិដែលមានចម្ងាយប្រមាណ៤ គីឡូម៉ែត្រ ដោយទុកម្តាយខ្ញុំនៅកន្លែងយាយៗមើលកុមារ។ ម្តាយខ្ញុំជាទារកដែលមានសុខភាពមិនល្អ និងជាក្មេងដែលយំច្រើនជាងកុមារដ៏ទៃទៀត។ជីដូនខ្ញុំនៅចាំថាពេលម្តាយខ្ញុំមានអាយុប្រហែល១ឆ្នាំ ២ឆ្នាំគាត់តែងតែយំតាមម្តាយនៅពេលដល់ម៉ោងចេញពីទៅធ្វើការងារតាមវាលស្រែម្តងៗ។

មានពេលមួយក្នុងឆ្នាំ១៩៧៧ ម្តាយខ្ញុំមានជំងឺក្អកផងបានយំរហូតបាត់សំឡេងធ្វើឲ្យជីដូនខ្ញុំភ័យខ្លាំងដោយគិតថាម្តាយខ្ញុំប្រហែលមិនរស់ទេ។ នៅក្នុងសម័យខ្មែរក្រហមជីដូនខ្ញុំមិនមានបាយម្ហូបហូបគ្រប់គ្រាន់ និងមិនមានទឹកដោះគ្រប់គ្រាន់ដើម្បីបំបៅកូន(ម្តាយខ្ញុំ)ទេហើយពេលកូនឈឺច្រើនក៏គ្មានថ្នាំសម្រាប់ព្យាបាល និងមិនត្រូវបានអនុញ្ញាតឲ្យនៅមើលថែកូនបានជិតដល់ដែរ។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំទៅនៅឆ្នាំ ១៩៧៩ម្តាយខ្ញុំមានអាយុ៣ឆ្នាំ និងនៅឆ្នាំ១៩៨១ ពេលគាត់អាយុ៥ឆ្នាំបានលេងលោតពីលើបាវស្រូវនៅលើផ្ទះជាមួយក្មេង ៗដ៏ទៃទៀត ក៏បានធ្វើឲ្យគាត់បាក់កជើងត្រង់កន្លែងឆ្អឹងកោងសំប៉ែតនោះ។ ដោយមិនមានពេទ្យនិងការព្យាបាលបានត្រឹមត្រូវនោះម្តាយខ្ញុំបានពិការជើងខាងស្តាំនិងដើរបុំងពៀត។

ម្តាយខ្ញុំបានចូលរៀននៅសាលាក្នុងឃុំពាមកោះស្នា នៅឆ្នាំ១៩៨៤ និងបានឈប់រៀនត្រឹមថ្នាក់ទី៨ក្នុងឆ្នាំ១៩៩៤។ នៅឆ្នាំ១៩៩៥ម្តាយខ្ញុំបានរៀបការជាមួយឪពុករបស់ខ្ញុំឈ្មោះ គាត ណាត។ រៀបការបានមួយឆ្នាំនៅឆ្នាំ១៩៩៦ ម្តាយខ្ញុំក៏កើតបានរូបនាងខ្ញុំ។ ដោយសារគាត់មានសុខភាពមិនល្អតាំងតែពីសម័យខ្មែរក្រហម មានជំងឺប្រចាំកាយ និងដំបៅរ៉ាំរ៉ៃ នៅលើជើងពិការរបស់គាត់នៅឆ្នាំ២០០១ ទើបបណ្តាលសុខភាពរបស់គាត់កាន់តែធ្លាក់ដុនដាបខ្លាំង។ នៅទីបំផុតម្តាយខ្ញុំបានស្លាប់នៅឆ្នាំ២០០៤។ ទោះបីជានាងខ្ញុំបានកើតនៅឆ្នាំ១៩៩៦ ក៏ដោយក៏របបខ្មែរក្រហមបានបន្តផលប៉ះពាល់ដល់រូបនាងខ្ញុំ និងត្រូវកំព្រាម្តាយរហូតមកដល់សព្វថ្ងៃ។ **គាត ស្រីខ្មែន**

# ស៊ឹម សឿន

សាលាក្តីខ្មែរក្រហមដែលបានចាប់ផ្តើមក្នុងឆ្នាំ២០០៦បានថមថយទៅៗនៅក្នុងឆ្នាំ២០១៩នេះ និងឈានទៅរកការបញ្ចប់ទាំងស្រុងក្នុងពេលដ៏ខ្លីខាងមុខៗ ស្ថាប័ននិងការិយាល័យច្បាប់មួយចំនួន ត្រូវបានបិទបញ្ចប់កិច្ចការរបស់ខ្លួន ហើយបុគ្គលិកជាតិ និងអន្តរជាតិជាច្រើននាក់ក៏ត្រូវបានរំសាយៗ ជាមួយគ្នានេះដែរដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះនៃរបបខ្មែរក្រហមខ្វះអស់កម្លាំង ក្នុងការបន្តតាមដានដំណើរការនេះតទៅទៀតៗសន្ទុះនៃការចង់បានភាពយុត្តិធម៌របស់អ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហម ជាពិសេសអ្នកដែលរស់នៅតាមទីជនបទដាច់ស្រយាល ក៏ត្រូវរសាត់កាន់តែឆ្ងាយទៅៗពីផ្នត់គំនិតរបស់ខ្លួន និងអាចជាសញ្ញាមួយដែលបង្ហាញពីភាពអស់សង្ឃឹមដែលគ្មានរំពឹងថានឹងអាចត្រឡប់មកវិញ បន្ទាប់ពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមួយនេះនឹងត្រូវបិទបញ្ចប់ៗ ថ្មីៗនេះ នួន ជា អតីតបងធំទី២ អនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងប្រធានសភាតំណាងប្រជាជនកម្ពុជាក្នុងរបបខ្មែរក្រហម បានស្លាប់បាត់បង់ជីវិតទាំងបណ្តឹងសារទុក្ខប្រឆាំង នឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង របស់ខ្លួនមិនទាន់ត្រូវបានកាត់សេចក្តីៗ ទោះបីជាយ៉ាងណាក៏ដោយក៏អ្នករស់រានមានជីវិតទាំងនោះ ជាពិសេសអ្នកដែលធ្លាប់បានដាក់ពាក្យបណ្តឹងសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតភ្ជាប់ទំនាក់ទំនងឡើងវិញ និងទទួលបានការយកចិត្តទុកដាក់ខ្ពស់ពីមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការចូលរួមកសាងនូវយន្តការ«យុត្តិធម៌អន្តរកាល»មួយនាពេលខាងមុខៗ

សឿន ធ្លាប់បានស្នើសុំដាក់ពាក្យបណ្តឹងទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាលពីឆ្នាំ២០០៩ តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បី ធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងដំណើរការសវនាការកាត់ទោសមេដឹកនាំកំពូលខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតដែលត្រូវបាន ចាប់ខ្លួន និងឃុំខ្លួនជាបណ្តោះអាសន្នដោយសាលាក្តីខ្មែរ



*ទេសភាពវាលស្រែរដូវវស្សាក្នុងឃុំទឹកថ្លា ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង*

ក្រហម។ សឿង ត្រូវបានអញ្ជើញឲ្យចូលរួមតាមដានអង្គសវនាការជាមួយអ្នកឯទៀត។ ១០ឆ្នាំក្រោយការដាក់ពាក្យបណ្តឹង សឿងលែងរវីរវល់និងយកចិត្តទុកដាក់ពីរឿងកាត់ក្តីតទៅទៀតហើយ ព្រោះគាត់ខ្វល់ខ្វាយពីសុខទុក្ខខ្លួនឯងក្រុមគ្រួសារ និងប្រជាជន រស់នៅក្នុងភូមិគាត់។

យើងបានមកជួប សឿង នៅផ្ទះរបស់គាត់បន្ទាប់ពីរយៈពេល១០ឆ្នាំនៃការជួបគាត់គ្រាដំបូងក្នុងឆ្នាំ២០០៩ដើម្បីសួរសុខទុក្ខ និងចង់ដឹងពីការគិតរបស់គាត់ពីដំណើរការរបស់សាលាក្តីខ្មែរក្រហម និងការស្វែងរកយុត្តិធម៌របស់សាលាក្តីខ្មែរក្រហម ព្រមទាំងការយល់ដឹងពីយន្តការនៃការកសាង «យុត្តិធម៌អន្តរកាល» នៅក្នុងកម្រិតមូលដ្ឋាន។កំពុងស្ថិតក្នុងស្ថានភាពជំងឺបេះដូងយូរឆ្នាំ សឿង ដែលមានសភាពពិបាកក្នុងការដកដង្ហើមនិងមិនសូវនិយាយស្តីច្រើនត្រូវបន្តលេបថ្នាំ និងទទួលការព្យាបាលជាប្រចាំពីគ្រូពេទ្យជំនាញបេះដូងនៅរាជធានីភ្នំពេញ។ទោះបីជាស្ថិតក្នុងស្ថានភាពជំងឺប្រចាំកាយយ៉ាងដូច្នេះក៏ដោយក៏សឿង នៅតែបន្តកិច្ចការជួយរៀបចំសណ្តាប់ធ្នាប់ និងសុវត្ថិភាពជូនប្រជាជនទាំងអស់ដែលកំពុងរស់នៅក្នុងភូមិមានជ័យជាធម្មតាហើយ គាត់ក៏ទទួលបានការគោរពស្រឡាញ់ពីអ្នកភូមិ ជាយូរឆ្នាំកន្លងមកហើយដែរ។ សឿងគឺជាប្រធានភូមិមានជ័យ ឃុំទឹកថ្លា ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង នាពេលបច្ចុប្បន្ន។ សឿងតែងតែចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំមិនដែលអាក់ខានម្តងណាឡើយលើកលែងតែចំថ្ងៃដែល គាត់ត្រូវចេញទៅព្យាបាលជំងឺតាមកាលកំណត់របស់គ្រូពេទ្យ។ សឿង បានទិញរថយន្តគ្រួសារមួយគ្រឿង ដើម្បីសម្រួលដល់ការធ្វើដំណើររបស់គាត់មកព្យាបាលជំងឺនៅភ្នំពេញ។ នៅក្រោមផ្ទះឈើបីខ្នងរបស់គាត់សឿង មានម៉ាស៊ីនច្រូតស្រូវ គ្រឿងនិងឧបករណ៍ធ្វើស្រែមួយចំនួនទៀត ដែលអាចបញ្ជាក់បានថាក្រុមគ្រួសាររបស់គាត់ អាចរកប្រាក់ចំណូលបានមួយផ្នែកពីគ្រឿងយន្តកសិកម្ម ទាំងនេះ។យើងបានរំឭកគាត់ពីជំនួបកាលពី១០ឆ្នាំមុន និងបានសួរនាំបន្ថែមពីបទពិសោធន៍របស់គាត់ ឆ្លងកាត់របបខ្មែរក្រហម ដើម្បីថែរក្សាការចងចាំរបស់គាត់។ មិនដូចមុនឡើយ សឿង និយាយប្រាប់យើងមួយៗយឺតៗខ្យល់ដង្ហើមថប់ៗ និងទំទប់ខ្លួនស្ទើរមិនបាន។ ឆ្នាំនេះ សឿង មានអាយុ៦៧ឆ្នាំគាត់ហាក់មានការភ្លេចភ្លាំងច្រើន នូវរឿងរ៉ាវដែលបានកើតមានក្នុងជីវិតរបស់គាត់ ជាពិសេសរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម។

មិនយូរប៉ុន្មាន សឿង បានប្រាប់យើងថាគាត់ពិបាកនិយាយនិងចង់ស្ទះម្តងៗ។ ឮដូច្នេះយើងបានផ្អាកការសន្ទនាមួយរំពេច ហើយក៏មិនសួរដេញដោលគាត់ច្រើនតទៅទៀតទេ។ យើងបានបញ្ចប់ការសួរនាំគាត់ត្រឹមរយៈពេលប៉ុន្មាននាទីប៉ុណ្ណោះបន្ទាប់ពីគាត់បាននិយាយនូវឃ្លាដ៏ខ្លីមួយថា« ប្រជាពលរដ្ឋផ្សេង គេពិបាកណាស់តែខ្ញុំមិនសូវពិបាកដូចគេទេ»។ យើងបានបញ្ចប់ការសួនាំទាំងក្តីសោកស្តាយ ព្រោះថាមិនបានសួរបញ្ជាក់គាត់ពីឫសគល់ និងអត្ថន័យនៃឃ្លាចុងក្រោយរបស់គាត់។ ពាក្យសម្តីមួយឃ្លានេះ បានក្លាយជាការចាប់អារម្មណ៍និងចោទជាសំណួរថា តើ សឿង ជានរណា ហើយមានតួនាទីជាអ្វីកាលពីអំឡុងពេលនៃរបបខ្មែរក្រហម?

សឿង បានងើបចេញពីកៅអីជ័រប្លាស្ទិកពណ៌ខៀវចាស់ រួចដើរទ្រោមៗទៅកាន់កៅអីឈើប្រណិតហង្សទេវ



ស៊ឹម សឿង ប្រធានភូមិមានជ័យ ឃុំទឹកថ្លា ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង

ស្ថិតនៅលើគ្រែឈើក្បែរនោះ រួចក៏សម្រួលខ្លួនគាត់នៅលើគ្រែនោះ។ ប៉ុន្មាននាទីក្រោយមកកូនប្រសារប្រុសរបស់ សឿង បានយកថ្នាំមកបញ្ចុកគាត់ រួចក៏ទម្រេតខ្លួនម្ដងទៀតនៅលើកៅអីនោះក្នុងស្ថានភាពរហិតរហៃ និងអស់កម្លាំង។ មិនបង្អង់យូរក្រុមការងារយើងបានចាកចេញពីផ្ទះ សឿង ឆ្ពោះទៅកាន់ផ្ទះកូនស្រីគាត់ ដែលមានអាយុប្រហែលជាង ៤០ឆ្នាំ ក្នុងគោលបំណងចង់សួរព័ត៌មានបន្ថែមពីឪពុកគាត់។ ប៉ុន្តែយើងមិនបានសម្រេចបំណងនេះទេ។ កូនស្រី និងកូនប្រសារប្រុសមួយគូរទៀតរបស់សឿងហាក់ជជែកមិនស៊ីសង្វាក់គ្នាទាល់តែសោះពីបញ្ហាផ្សេងៗក្នុងគ្រួសារ ជាហេតុធ្វើឲ្យយើងសម្រេចចិត្តចាកចេញម្ដងទៀត ហើយធ្វើដំណើរទៅកាន់ភូមិផ្សេងដែលជាភូមិគោលដៅបន្ទាប់។ យើងបានធ្វើដំណើរតាមផ្លូវលំប្របមាត់ព្រែកមួយ ដែលមានចម្ងាយប្រមាណ២គីឡូម៉ែត្រពីគ្នា។

ហៀបនឹងទៅដល់ភូមិព្រៃទទឹងដែលជា គោលដៅទៅហើយយើងបានសម្រាកហូបអាហារថ្ងៃត្រង់ នៅក្នុងបរិវេណវត្តមួយ។ នៅទីនោះ យើងបានជួបជាមួយជំទប់ឃុំទឹកថ្លាម្នាក់គណៈកម្មការវត្តបីបួននាក់ និងព្រះសង្ឃវ័យចំណាស់មួយអង្គ។យើងទាំងអស់គ្នា បានជជែកគ្នាលេងពីនេះពីនោះតាមទម្លាប់របស់យើង។ ហូបអាហារថ្ងៃត្រង់បណ្ដើរនិយាយបណ្ដើរឆ្លៀតសួរនាំពីបទពិសោធន៍ឆ្លងកាត់ របបខ្មែរក្រហមបណ្ដើរ។ ការសន្ទនាបានឈានដល់ការសម្រិតសម្រាំងចំណុចសំខាន់ៗ និងបានផ្ដោតចំៗលើជីវិតក្រោមរបបខ្មែរក្រហម។ ព័ត៌មានបន្ថែមពី សឿង ក៏ត្រូវបានដឹងបន្ថែមទៀតដែរ ប៉ុន្តែមិនច្រើនប៉ុន្មានទេហើយក៏មិនស៊ីជម្រៅពេកដែរ។

កំពុងស្ថិតនៅក្នុងសាលាឆាន់ ប្រក់ស័ង្កសីចាស់មួយ ហ៊ុម សួន ដែលកំពុងពិសារអាហារថ្ងៃត្រង់នៅលើគ្រែរនាបឫស្សីគឺជាជំទប់ទី២ឃុំទឹកថ្លា។ អ៊ុំប្រុសម្នាក់ទៀត (មិនស្គាល់ឈ្មោះដែលកំពុងអង្គុយលើគ្រែឈើចាស់មួយក្បែរគ្នា នឹង សួនគឺជាគណៈកម្មការវត្ត។ អ៊ុំស្រីៗពីរបីនាក់ទៀតគឺជាអ្នកថែរក្សាទីធ្លាវត្ត និងមើលការខុសត្រូវម្ហូបអាហារក្នុងវត្ត។ សួន និងព្រះសង្ឃវ័យចំណាស់បានរៀបរាប់ប្រាប់យើងត្រួសៗពីប្រវត្តិរបស់ខ្លួន និងបង្ហើបឲ្យដឹងពីសឿងថាធ្លាប់បម្រើការជាគណៈភូមិប្រធានភូមិមានជ័យ និងក្រោយមកជាប្រធានសហករណ៍មានជ័យ។សឿងមានបងប្អូនបង្កើត២ នាក់។ បងស្រីរបស់គាត់ បានស្លាប់ក្នុងសម័យសង្គមរាស្ត្រនិយម។ សឿង ធ្លាប់ចូលរួមក្នុងចលនាខ្មែររំដោះ មុនឆ្នាំ១៩៧៥ និងមានវត្តមានក្នុងចលនាបះបោរ ដែលមិនទទួលបានជោគជ័យក្នុងចុងឆ្នាំ១៩៧៨ នៅក្នុងទឹកដីឃុំទឹកថ្លា ស្រុកព្រៃវែង (បច្ចុប្បន្នស្រុកស្វាយអន្ទរ)។ ប្រជាជនទាំងអស់បានហៅព្រឹត្តិការណ៍នោះថាជាបាតុកម្មប្រឆាំងនឹងក្រុម ខ្មែរក្រហមមកពីភូមិភាគនិរតីដែលចូលមកគ្រប់គ្រងភូមិ ភាគបូព៌ាក្នុងឆ្នាំ១៩៧៨។ ភាពបរាជ័យនេះ បានបង្កឲ្យមានការជម្លៀសទ្រង់ទ្រាយធំនៅក្នុងឃុំទឹកថ្លា។ ប្រជាជននិងអតីតកម្មាភិបាលខ្មែរក្រហមភូមិភាគបូព៌ាភាគច្រើន ត្រូវបានជម្លៀសទៅកាន់ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងបាត់ដំបងជាកន្លែងដែលសមាជិកគ្រួសារស្ទើរតែទាំងអស់ត្រូវបាន សម្លាប់ស្លាប់និងបាត់ខ្លួនរហូតដល់សព្វថ្ងៃ។

អ្នកដែលនៅសេសសល់ ត្រូវបានបញ្ជូនឲ្យទៅរស់នៅក្នុងឃុំធាយ ស្រុកបាភ្នំ, ឃុំព្រៃឃ្នេស ស្រុកមេសាង និងឃុំសំរោង ស្រុកព្រៃវែង។ សឿង ជាប់ឈ្មោះក្នុងបញ្ជីដែលត្រូវបញ្ជូនទៅកាន់តំបន់ដីខ្លាញ់ដូចអ្នកឯទៀតៗ ប៉ុន្តែគាត់មិនបានទៅដល់គោលដៅតាមការកំណត់ឡើយ ព្រោះកងទ័ពវៀតណាម និងកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានចូលមកដល់ប្រទេសកម្ពុជា និងបានវាយដណ្ដើមកាន់កាប់បានខេត្តស្វាយរៀង និងព្រៃវែង។សឿងបានត្រឡប់មកកាន់ភូមិកំណើតវិញ និងបានក្លាយជាមេភូមិតាំងពីពេលនោះរហូតមកដល់សព្វថ្ងៃ។ គោលបំណងតែមួយគត់របស់ សឿង នាពេលបច្ចុប្បន្ននេះ គឺធ្វើយ៉ាងណាឲ្យក្រុមគ្រួសាររបស់គាត់អាចរស់នៅបានស្រួលមានស្រូវអង្ករហូបចុកគ្រប់គ្រាន់ និងមានមធ្យោបាយធ្វើដំណើរសមរម្យ។

**ផេង ពង្សរ៉ាស៊ី**

# សិស្សានុសិស្សនៅអនុវិទ្យាល័យក្រពើពីរ ក្នុងស្រុកវាលវែងសិក្សាបន្ថែមអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

នៅម៉ោង៩ព្រឹកថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានសហការជាមួយក្រសួងអប់រំយុវជន និងកីឡា រៀបចំធ្វើវេទិកាថ្នាក់រៀនមួយស្តីពី សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ជាលើកទី៣ នៅអនុវិទ្យាល័យក្រពើពីរ ដែលមានសិស្សានុសិស្សចូលរួមចំនួន៤២នាក់ (ស្រី១៩នាក់)។ អនុវិទ្យាល័យក្រពើពីរមានទីតាំងស្ថិតនៅក្នុងភូមិក្រពើពីរក្រោម ឃុំក្រពើពីរស្រុកវាលវែងខេត្តពោធិ៍សាត់។ ក្រពើពីរគឺជាអតីតមូលដ្ឋានកងទ័ពខ្មែរក្រហមឈរជើង ដើម្បីវាយប្រយុទ្ធជាមួយកងទ័ពវៀតណាម និងកងទ័ពរបស់រដ្ឋកម្ពុជាដែលបានឈរជើងនៅតាមផ្លូវជាតិលេខ៥៦ និងទីតាំងមួយចំនួនទៀតនៅក្នុងស្រុកភ្នំក្រវាញ។ បន្ទាប់ពីកងទ័ពខ្មែរក្រហមទាំងនោះបានធ្វើសមាហរណកម្ម ចុះចូលជាមួយរាជរដ្ឋាភិបាលនៅឆ្នាំ១៩៩៦ អតីតខ្មែរក្រហមនិងក្រុមគ្រួសារបានសម្រេចចិត្តរស់នៅតំបន់នេះ ហើយបានបង្កើតជាភូមិឃុំ និងសាងសង់សាលារៀនសម្រាប់កូនចៅបានរៀនសូត្ររហូតដល់សព្វថ្ងៃនេះ។

វេទិកាថ្នាក់រៀនស្តីពីសារសំខាន់ នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)មានគោលបំណងដើម្បីបង្កើនចំណេះដឹងផ្នែកប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់សិស្សានុសិស្សនៅកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យនៅទូទាំងប្រទេសកម្ពុជា។ ជាពិសេសគឺបង្កើតឲ្យមានកិច្ចពិភាក្សា ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យក្នុងចំ



លោក ឡុង ដានី, នាយកសាលា និងសិក្សានុសិស្សអនុវិទ្យាល័យក្រពើពីរ ថតរូបជុំគ្នាក្រោយបញ្ចប់វេទិកាថ្នាក់រៀន

ណោមសិស្សានុសិស្ស និងវាគ្មិនៗ វេទិកាថ្នាក់រៀននេះក៏មានតួនាទីជួយដល់ក្មេងៗជំនាន់ក្រោយ ក្នុងការរៀនសូត្រអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យមានការអត់ឱនយោគយល់អធ្យាស្រ័យ និងទប់ស្កាត់កុំឲ្យអំពើប្រល័យពូជសាសន៍នៅកម្ពុជាកើតឡើងសារជាថ្មី។

មុនពេលចាប់ផ្តើមវេទិកាថ្នាក់រៀនស្តីពី សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) លោកនាយកអនុវិទ្យាល័យក្រពើពីរ ភន ផានិត បានលើកឡើងថាអនុវិទ្យាល័យក្រពើពីរ ទើបតែបង្កើតនៅក្នុងឆ្នាំសិក្សា២០១៤ - ២០១៥ដោយមានអគារសិក្សាចំនួនពីរខ្នង មួយខ្នងសាងសង់ឡើងក្រោមជំនួយឧបត្ថម្ភរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងអគារមួយខ្នងទៀតសាងសង់ដោយរាជរដ្ឋាភិបាលកម្ពុជា។ សាលាអនុវិទ្យាល័យក្រពើពីរមានចំនួន១១ បន្ទប់មានសិស្សានុសិស្សសរុបចំនួន៥៧នាក់ (ស្រី២៧នាក់) និងមានគ្រូចំនួន៦នាក់ (ស្រីម្នាក់)។ ជាទូទៅសិស្សានុសិស្សដែលបញ្ចប់ថ្នាក់ទី៩ ភាគច្រើនបានបោះបង់ការសិក្សាដោយសារមិនមានលទ្ធភាព ទៅបន្តការសិក្សានៅថ្នាក់វិទ្យាល័យនៅប្រម៉ោយទីរួមស្រុកវាលវែងទៀត ពីព្រោះមានការខ្វះខាតផ្នែកជីវភាពនិងវិទ្យាល័យ មានចម្ងាយប្រមាណ៤៥គីឡូម៉ែតពីផ្ទះ។

លោកនាយកមានការរីករាយពីព្រោះវាគឺជាលើកទី ១ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមករៀបចំធ្វើវេទិកាថ្នាក់រៀនស្តីពី សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)។ លោកនាយកគិតថាវេទិកានេះនឹងជួយឲ្យសិស្សានុសិស្ស បានយល់ដឹងអំពីអ្វីដែលបានកើតមានឡើងនៅក្នុងរបបខ្មែរក្រហមដូចជា ការជម្លៀសការសម្លាប់ និងការបង្ខំឲ្យប្រជាជនធ្វើការហួសកម្លាំង។ ចំណែកកុមារមិនបានទៅសាលារៀនដើម្បីរៀនសូត្រឡើយ។ កាលពីមុនសិស្សានុសិស្សមិនសូវបានយល់ដឹង ពីរឿងរ៉ាវដែលបានកើតឡើងឡើយហើយប្រសិនបើបានដឹង គឺដឹងតែបន្តិចបន្តួចពីឪពុកម្តាយឬជីដូនជីតា ដែលជាអតីតកម្មាភិបាលខ្មែរក្រហមនិយាយប្រាប់ប៉ុណ្ណោះ ពីព្រោះប្រជាជនដែលរស់នៅក្រពើពីរនេះ ភាគច្រើនោគឺជាអតីតកម្មាភិបាលខ្មែរក្រហមដែលភៀសខ្លួនពីភ្នំពេញ និងខេត្តផ្សេងៗ។



អនុវិទ្យាល័យក្រពើពីរ

បន្ទាប់ពីសិស្សានុសិស្ស បំពេញតារាងស្ទាបស្ទង់មតិមុនវេទិកាថ្នាក់រៀន និងបានឡើងសរសេរនូវអ្វីដែលខ្លួនបានដឹង និងចង់ដឹងអំពីរបបខ្មែរក្រហម ព្រមទាំងបានទស្សនាខ្សែភាពយន្តឯកសារកុមារកម្ពុជារួចមក លោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើបទបង្ហាញអំពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម និងបកស្រាយនូវសំណួរដែលសិស្សានុសិស្សចង់ដឹងពីរបបនោះ។ នៅចុងបញ្ចប់នៃវេទិថ្នាក់រៀន សិស្សានុសិស្ស បានបំពេញតារាងស្ទាបស្ទង់មតិក្រោយវេទិកាថ្នាក់រៀន ហើយបុគ្គលិកមជ្ឈមណ្ឌលផ្សះផ្សាវាលវែងក៏បានចែកសៀវភៅ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ចំនួន៧៣ក្បាល ដល់សិស្សានុសិស្ស ដែលបានចូលរួមវេទិកាថ្នាក់រៀនទៀតផង។

ធួន លីហ័រ មានអាយុ១៨ឆ្នាំ រៀនថ្នាក់ទី៧ «ក» មានស្រុកកំណើតនៅខេត្តតាកែវ ហើយសព្វថ្ងៃរស់នៅភូមិសំឡាញយុំក្រពើពីរស្រុកវាលវែងខេត្តពោធិ៍សាត់បានឲ្យដឹងថា ក្រោយពេលបានចូលរៀនក្នុងវេទិកាថ្នាក់រៀន ស្តីអំពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)រួចមក បានធ្វើឲ្យខ្ញុំកាន់តែចង់ដឹងពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំធ្លាប់បានសួរតារបស់ខ្ញុំពីរបបខ្មែរក្រហម។

តារបស់ខ្ញុំឈ្មោះ គីម ហើយកាលសម័យនោះគាត់ធ្វើជាទាហាននៅក្នុងខេត្តតាកែវ។ តារបស់ខ្ញុំបានរត់គេចពីការបាញ់គ្នានៅបន្ទាយទាហានដែលព្រតែសំឡេងគ្រាប់ផ្ទុះឡើងទ្រហឹង។ កាលថ្នាក់ទី៦ខ្ញុំធ្លាប់រៀនជួបពាក្យថាប្រល័យពូសាសន៍ ប៉ុន្តែមិនដឹងអត្ថន័យពិតប្រាដកយ៉ាងដូចម្តេចនោះទេ។ បន្ទាប់ពីបានចូលរៀនក្នុងវេទិកាថ្នាក់រៀន បានធ្វើឲ្យខ្ញុំយល់អត្ថន័យនេះ និងចំណេះដឹងថ្មីៗបន្ថែមទៀតពីរបបខ្មែរក្រហមដូចជាក្មេងៗ នៅសម័យនោះមិនមានសាលារៀនគឺរៀនក្រោមដើមឈើ ហើយប្រជាជនគ្មានបាយហូបគ្រប់គ្រាន់ៗខ្ញុំមានចិត្តសប្បាយសប្បាយរីករាយ ដែលឃើញមានការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ហើយក៏ចង់ឲ្យមានវេទិកាថ្នាក់រៀននេះលើកក្រោយទៀត។ ខ្ញុំនឹងចែករំលែកចំណេះដល់មិត្តភក្តិដទៃទៀត ដែលមិនបានចូលរួមថ្ងៃនេះឲ្យបានដឹងដូចខ្ញុំដែរ។

ហូ ធារី ភេទស្រី ជាសិស្សថ្នាក់ទី៩ នៃអនុវិទ្យាល័យក្រពើពីររស់នៅភូមិក្រពើពីរក្រោម យុំក្រពើពីរស្រុកវាលវែងខេត្តពោធិ៍សាត់ បានសម្តែងនូវអារម្មណ៍រីករាយក្រោយពីបានចូលរៀនក្នុងវេទិកាថ្នាក់រៀន ស្តីអំពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ព្រោះវេទិកានេះបានធ្វើឲ្យខ្ញុំយល់ដឹងពីប្រវត្តិសាស្ត្រដ៏ជូរចត់របស់ប្រទេសខ្លួន ដូចជារបបខ្មែរក្រហមបានធ្វើឲ្យប្រជាជនរស់នៅជាសហករណ៍ហូបរួមគ្នា ធ្វើការរួមគ្នាជាដើម។ គ្រួសារត្រូវបានខ្មែរក្រហម បំបែកឲ្យរស់នៅឆ្ងាយពីបងប្អូន និងឪពុកម្តាយ។ របបខ្មែរក្រហមបានធ្វើឲ្យបាត់បង់ជីវិត និងខូចខាតទ្រព្យសម្បត្តិទៀតផង។

លន់ រតនា ភេទប្រុស ជាសិស្សរៀនថ្នាក់ទី៩សព្វថ្ងៃរស់នៅភូមិក្រពើពីរក្រោមយុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ រតនា និងគ្រួសារមានស្រុកកំណើតនៅខេត្តតាកែវ។ រតនា បាននិយាយថាពីមុនមកឪពុកម្តាយមិនពីរបបខ្មែរក្រហមឲ្យស្តាប់នោះទេ។ ប៉ុន្តែ ខ្ញុំធ្លាប់រៀនខ្លះដែរពីកម្មវិធីសិក្សារបស់ក្រសួងអប់រំ អំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា។ ក្រោយពី លោកគ្រូ ឡុង ដានី បានធ្វើការបកស្រាយ និងពន្យល់អំពីរបបខ្មែរក្រហមបានធ្វើឲ្យខ្ញុំបានយល់ដឹងបន្ថែមអំពីទុក្ខវេទនារបស់ប្រជាជននៅក្នុងរបបខ្មែរក្រហម និងការជម្លៀសប្រជាជនឲ្យទៅរស់នៅតាមតំបន់ជនបទ។ ប្រជាជនធ្វើការហួសកម្លាំងនិងហូបមិនគ្រាប់គ្រាន់។ មេរៀនដែលខ្ញុំបានរៀននៅថ្ងៃនេះខ្ញុំនឹងយកទៅនិយាយប្រាប់មិត្តភក្តិ និងបងប្អូនរបស់ខ្ញុំដែលមិនទាន់បានដឹងឲ្យដឹងដូចខ្ញុំដែរ។ ខ្ញុំចង់ឲ្យប្រជាជនរស់នៅដោយមានភាពសាមគ្គីគ្នា ចេះអធ្យាស្រ័យគ្នាមិនត្រូវរើសអើងពូជសាសន៍នោះទេ។

***សុង ថាណៃ***

# អតីតតំបន់គ្រាប់មីន និងកន្លែងលាក់ខ្លួនរបស់ខ្មែរក្រហម គឺជាតំបន់ធម្មជាតិដ៏ស្រស់ស្អាតនាពេលបច្ចុប្បន្ន

ក្រោយពេលសង្គ្រាមបានបញ្ចប់ គ្រាប់មីនមិនទាន់ផ្ទុះដែលជាសំណល់នៃសង្គ្រាម នៅរាយប៉ាយលើផ្ទៃដីទូទាំងប្រទេសកម្ពុជា។ ខេត្តឧត្តរមានជ័យគឺជាតំបន់បញ្ចប់សង្គ្រាមចុងក្រោយរវាងខ្មែរក្រហម និងរាជរដ្ឋាភិបាលកម្ពុជាដែលបានបន្សល់នូវគ្រាប់មីនបង្កប់យ៉ាងច្រើន។ ចាប់តាំងពីការធ្វើសមាហរណកម្មនៅដើមឆ្នាំ១៩៩៩ រហូតមកដល់បច្ចុប្បន្នមានអាវុធយុទ្ធភណ្ឌ និងគ្រាប់មីនមិនទាន់ផ្ទុះ ត្រូវបានរកឃើញនៅតំបន់ ដែលជាអតីតសមរភូមិប្រយុទ្ធនៅខេត្តឧត្តរមានជ័យជាបន្តបន្ទាប់។ ព្រៃសហគមន៍សង្ឃរុក្ខវ័នដែលជាអតីតកន្លែងលាក់ខ្លួនរបស់ខ្មែរក្រហម និងសមរភូមិប្រយុទ្ធក៏មាននៅសេសសល់គ្រាប់មិនទាន់ផ្ទុះដែរ។

នៅក្នុងខ្សែភាពយន្តឯកសារ «ឆ្នាំព្រៃ» ដែលមានព្រះតេជគុណប៊ុនសាលូតគឺជាប្រធានព្រៃសហគមន៍ និងជាមេគណខេត្តឧត្តរមានជ័យបានបង្ហាញ អំពីសកម្មភាពនៃការស្វែងរកទីតាំងគ្រាប់បែកមិនទាន់ផ្ទុះ មុនដំណើរការរៀបចំបង្កើតទៅជាសហគមន៍ការពារព្រៃឈើគឺ «ព្រៃសហគមន៍សង្ឃរុក្ខវ័ន» ដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា។ ព្រះតេជគុណ ប៊ុន សាលូត បានមានសង្ឃដីកាថា ក្រោយសង្គ្រាមស៊ីវិលបានបញ្ចប់ តំបន់នេះសម្បូរទៅដោយគ្រាប់មីនមិនទាន់ផ្ទុះដែលខ្មែរក្រហមបានដាក់ពង្រាយ និងកប់នៅក្នុងដី។ ដូច្នេះកិច្ចការដំបូងរបស់អាត្មាបានធ្វើបន្ទាប់ពីទទួលបានច្បាប់អនុញ្ញាតពីរាជរដ្ឋាភិបាល ដើម្បីកំណត់ដែនការពារព្រៃធម្មជាតិរបស់សហគមន៍រួចមកអាត្មា, ព្រមទាំងព្រះសង្ឃ,សមាជិកការពារសហគមន៍សង្ឃរុក្ខវ័ន និងអង្គការ ហាឡូត្រាស់ បានរួមគ្នាស្វែងរកទីតាំងគ្រាប់បែកមិនទាន់ផ្ទុះដើម្បីធ្វើការបោសសម្អាត។ ព្រះតេជគុណ ប៊ុន សាលូត បានមានសង្ឃដីកាបន្តថា មុនដំណើរការបោសសម្អាតគ្រាប់មីនបង្កប់ទាំងនោះ ធ្លាប់មានប្រជាជនរងគ្រោះ



វំ ភឿន អ្នកការពារព្រៃឈើ កំពុងដឹកនាំបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាទស្សនា ព្រៃសហគមន៍សង្ឃរុក្ខវ័ន្ត ក្នុងខេត្តឧត្តរមានជ័យ

ថ្នាក់ដោយជាន់ប៉ះចំគ្រាប់មីនដែរ។ នៅរវាងឆ្នាំ២០០២ និងឆ្នាំ២០០៣មានរទេះគោអ្នកភូមិបានបរចូលទៅក្នុងព្រៃដើម្បីដឹកឈើសម្រាប់សាងសង់ផ្ទះ។

រទេះគោរបស់អ្នកភូមិមួយគ្រឿង បានបរតាមគន្លងផ្លូវដែលអ្នកភូមិផ្សេងទៀតធ្វើដំណើរពីមុនមក។ ប៉ុន្តែរទេះគោនោះបានបរទៅប៉ះចំគ្រាប់មីនដែលកប់នៅក្នុងដីបណ្តាលឲ្យផ្ទុះងាប់គោទាំងអស់។ក្រោយមកនៅឆ្នាំ២០០៦ ដំណើរការរុករកគ្រាប់បែកមិនទាន់ផ្ទុះ ដែលមានទ្រង់ទ្រាយធំបានចាប់ផ្តើមឡើងហើយបានរកឃើញប្រភេទគ្រាប់បែក និងគ្រាប់មីនមិនទាន់ផ្ទុះនៅក្នុងព្រៃសហគមន៍សង្ឃរុក្ខវ័ន ជាច្រើន ដូចជា ៖ គ្រាប់បេ-៤២, គ្រាប់បែកចង្កោម, មីនគោន តេ-៨៦ និង គ្រាប់បែកកៃច្នៃ។ នៅក្នុងឆ្នាំ២០១០មានឧប្បត្តិហេតុដ៏រន្ធត់មួយ បានកើតឡើងចំពោះអ្នកភូមិដែលចូលទៅប្រមូលអនុផលព្រៃឈើ នៅក្នុងព្រៃសហគមន៍សង្ឃរុក្ខវ័ន ដោយអ្នកភូមិ៩ នាក់ដែលបានជិះលើគោយន្តនិងអ្នកបើកបរគោយន្តម្នាក់ បានបរគោយន្តប៉ះចំគ្រាប់មីនបណ្តាលឲ្យផ្ទុះស្លាប់ទាំងអស់។ គ្រាប់បែកបន្សល់ពីសង្គ្រាមទាំងនោះត្រូវបានកប់នៅក្នុងដី ហើយនៅរប៉ាត់រប៉ាយពេញផ្ទៃដីក្នុងព្រៃសហគមន៍សង្ឃរុក្ខវ័ន។ ពេលខ្លះសត្វជ្រូកព្រៃឈ្មុលដីជិតកន្លែងគ្រាប់មីនដែលកប់ក្នុងជម្រៅដីដែលនៅរាក់ ក៏អណ្តែតគ្រាប់មីននោះឡើងមកលើប៉ុន្តែ មិនបណ្តាលឲ្យផ្ទុះនិងមានគ្រោះថ្នាក់ដល់អ្នកភូមិឡើយ។ មកដល់ឆ្នាំ២០១៩នេះ សមាជិកការពារព្រៃសហគមន៍សង្ឃរុក្ខវ័នបានស្វែងរកគ្រាប់បែកមិនទាន់ផ្ទុះជាបន្តបន្ទាប់ ហើយប្រជាជនត្រូវបានហាមឃាត់មិនឲ្យទៅនេសាទ ឬរកអនុផលព្រៃឈើនៅក្នុងតំបន់ដែលសង្ស័យថាមានគ្រាប់បែកកប់នៅក្នុងដី។ ព្រះតេជគុណ ស៊ឹម ស៊ឹម មានស្រុកកំណើតនៅឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលបានចូលរួមទស្សនាខ្សែភាពយន្តឯកសារ «ឆ្នាំព្រៃ» ដែលបានចាក់បញ្ចាំងនៅសាកលវិទ្យាល័យបញ្ញាសាស្ត្រ ក្នុងក្រុងភ្នំពេញ បានបង្ហាញពីចំណាប់អារម្មណ៍ថា អាត្មាធ្លាប់ បានទៅទស្សនាព្រៃសហគមន៍សង្ឃរុក្ខវ័នកាលពីឆ្នាំ២០១៨ ។ នៅពេលអាត្មាបានទៅដល់ព្រៃសហគមន៍នេះ អាត្មាមានអារម្មណ៍ ស្រស់ស្រាយជាមួយធម្មជាតិយ៉ាងខ្លាំង។ អាត្មាមិនធ្លាប់គិតថា ព្រៃនេះគឺជាអតីតតំបន់របស់ខ្មែរក្រហមទេ។ អាត្មាក៏មិនបានដឹងអំពីតំបន់អន្លង់វែង ដែលជាអតីតតំបន់តស៊ូរបស់ខ្មែរក្រហមដែរ។ ដោយសារតែមានការរៀបរាប់ប្រាប់តាមរយៈព្រះតេជគុណ ប៊ុន សាលួត បានធ្វើឲ្យអាត្មាដឹងអំពីតំបន់អតីតខ្មែរក្រហម។ អាត្មាសូមកោតសរសើរចំពោះព្រះតេជគុណ ប៊ុត សាលួត ដែលព្រះអង្គអាចការពារព្រៃឈើបានសម្រាប់មនុស្សជំនាន់ក្រោយ។ អាត្មាក៏បានឃើញការអាស្រ័យអនុផលព្រៃឈើ របស់អ្នកភូមិដូចជាការដុតដើមឈើយកជ័រ ដកផ្សិត ដែលផ្ទុយកាលពីអតីតកាលជាតំបន់សង្គ្រាម ឮសូរតែគ្រាប់កាំភ្លើង។អាត្មាយល់ថាខ្សែភាពយន្តឯកសារនេះ គឺជាសារសម្រាប់មនុស្សគ្រប់គ្នារួមគ្នាជួយការពារ និងថែរក្សាព្រៃឈើព្រោះព្រៃឈើបានផ្តល់អត្ថប្រយោជន៍ឲ្យមនុស្សយ៉ាងច្រើន។

គ្រី គុណជីវិតា អាយុ១៩ឆ្នាំ គឺជានិស្សិតឆ្នាំទី២ ផ្នែកវិនិយោគ និងបច្ចេកវិទ្យានៃសាកលវិទ្យាល័យបញ្ញាសាស្ត្របានរៀបរាប់ថា ខ្ញុំមានអារម្មណ៍សប្បាយរីករាយព្រោះមិននឹកស្មានថាប្រទេសកម្ពុជា មានប្រភេទសត្វបក្សីកម្រស្រដៀងសត្វចាប ដែលមានសម្បុរពណ៌សនៅលើក្បាល។ ខ្សែភាពយន្តឯកសារនេះ បានពញ្ញាក់ស្មារតីយុវជនឲ្យបានដឹងពីតំបន់ ដែលមានព្រៃឈើស្រស់ស្អាតដែលពីមុនធ្លាប់ជាកន្លែងដែលមានគ្រាប់បែកស្នូរកាំភ្លើងប្រយុទ្ធគ្នា។ ព្រៃសហគមន៍សង្ឃរុក្ខវ័ននេះក៏ផ្តល់ឲ្យក្មេងៗជំនាន់ក្រោយអាចស្គាល់ប្រភេទដើមឈើកម្រ ជាច្រើនប្រភេទដូចជា ដើមក្រញូងឈើទាល ស្រឡៅ និងដើមឈើជាច្រើនប្រភេទទៀត។ អតីតតំបន់នេះធ្លាប់តែមានជម្លោះមានការបង្ហូរឈាម និងមានភាពតក់ស្លុតបានក្លាយទៅជាតំបន់ដែលមានប្រជាជនរស់នៅ និង មានព្រៃឈើស្រស់បំព្រងដែលជាការចាប់ផ្តើមជីវិតសាជាថ្មី។

**ដារ៉ារដ្ឋ មេត្តា**

# ប្រវត្តិរបស់ នួន ជា ៖ ការជជែកនៅក្រោយបន្ទប់សវនាការ

តាំងពីដើមដំបូងមក នួន ជា បានបញ្ជាក់ថា គាត់មិនមានការរំពឹងទុក ក្នុងការតស៊ូជាមួយតុលាការនេះទេ ប៉ុន្តែគាត់តស៊ូ ដើម្បីពន្យល់ទៅកាន់ប្រជាជនអំពីអ្វីដែលបានកើតឡើងអំពីមូលហេតុដែលគាត់ចូលរួមក្នុងចលនាបដិវត្តន៍ និង ពីមូលហេតុដែលបណ្តាលឲ្យកើតមានសោកនាដកម្មនេះ។គាត់បានផ្តល់តម្លៃការចងក្រងនូវការជជែកនេះថា ៖

« កេរមរតកហ្នឹងអាហ្នឹងជាកំណាប់កប់សំខាន់ណាស់ៗសរសេរសន្សំៗទៅបន្តិចទៅ យើងជួយគ្នាទៅខ្ញុំជួយមើលហើយជួយកែរ។ មិនមែនជួយកែពាក្យពេចន៍អីទេតែជួយជា គំនិតខ្ញុំខ្វះត្រង់ណាស្រួលខ្ញុំគិត។ ពិបាកណាស់ក្មួយគ្មានអីលំបាកជាងធ្វើសង្គ្រាមទេ គ្មានអីលំបាកជាងធ្វើបដិវត្តន៍ទេហើយ គ្មានអីលំបាកជាងយកឈ្នះចិត្តឯងទេអាហ្នឹងពិបាកបំផុតជាងគេ។ យកឈ្នះគេស្រួលទេតែអាយកឈ្នះខ្លួនឯងគឺថាបុគ្គលនិយម និងរួមនិយមវាកំពុងប្រយុទ្ធគ្នា។សព្វថ្ងៃនេះបុគ្គលនិយមវាឈ្នះ។ មានអីនិយាយឲ្យអស់មកខ្ញុំចេះតែគិតថាយើបើឯងងាប់ទៅមិនដឹងជាកប់ចោល ព្រោះគ្មានអ្នកណាមកនិយាយអី។ »

### កុមារ ខ្លួច

នួន ជា ដើមឡើយឈ្មោះ ឡៅ គីមរន ក្រោយមកឈ្មោះឡៅ ឌី និងក្រោយមកត្រូវបានគេស្គាល់ថា នួន ជា ប៉ុន្តែ ខ្លួច គឺជាឈ្មោះដែលម្តាយរបស់គាត់ស្រឡាញ់ជាងគេ។ គាត់ជាកូនទីបីក្នុងគ្រួសារកើតនៅថ្ងៃ ទី៧ ខែ កក្កដា ឆ្នាំ១៩២៦ នៅភូមិវត្តគរ ឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង។ តាំងពីកុមារដ្ឋានមក គាត់រៀនមិនសូវពូកែទេ តែក៏រៀនមិនដែលធ្លាក់ដែរ។ គាត់មានចរិតខ្លាចគេ និងមិនសូវក្លាហាន។ នៅសាលាខ្លាចគ្រូវាយឯម្តាយគាត់ច្រើនប្រដៅឲ្យខ្លាចគេដូចជា គាត់តែងព្រមានថា«តែឯងឈ្លោះជាមួយគេអញវាយ» ការទូន្មានបែបនេះហើយ ដែលធ្វើឲ្យគាត់ខ្លាចគេ។ ពេលដល់សាលារៀនគាត់ខ្លាចគេណាស់ជាពិសេសក្រុម សិស្សពូកែដែលចូលចិត្តធ្វើបាបសិស្សរៀនអន់។ គាត់ចូលចិត្តរាប់អានកូនអ្នកជនបទស្រុកស្រែដូចគ្នា ហើយស្អប់ពួកទីក្រុងនិងកូនចៅអ្នកទីក្រុង។ បរិយាកាសដែលធ្វើឲ្យនួនជាគិតពីការជិះជាន់លើអ្នកក្រីក្រ។

នេះជាហេតុការណ៍សោកសង្រេងដែលធ្វើឲ្យនួន ជា ជិតដាមគិតដល់ជីវិតមនុស្សដែលត្រូវគេជិះជាន់និងធ្វើបាប។ នៅក្នុងភូមិរបស់គាត់ មានអ្នកជិតខាងធ្វើស្មៀនសាលាខេត្តបាត់ដំបងដែលជាមនុស្សកាច។ គាត់ជួលមនុស្សមកស៊ីឈ្នួលរត់រ៉ឺម៉ក។ ឈ្នួលរបស់គាត់រត់មិនសងប្រាក់គាត់ក៏បញ្ជាឲ្យក្រុមបម្រើចាប់ឈ្នួលឲ្យមកជួប។ ឈ្នួលបានអង្គុយបត់ជើងសុំទោសចៅហ្វាយថាខុសហើយ សូមអត់ទោសឲ្យផង។ ស្មៀនបានយករំពាត់ក្តគោមកវ៉ៃក្បាលឈ្នួលនោះហូរឈាមស្រោចខ្លួនបើទោះគាត់សុំទោសយ៉ាងណាក៏ដោយ។ ខ្លួចនិងក្មេងដទៃទៀតនៅក្នុងភូមិបានឃើញព្រឹត្តិការណ៍នេះ ដែលធ្វើឲ្យគាត់ចាប់អារម្មណ៍អ្នកក្រតាំងពីនោះមក។

### បន្តការសិក្សានៅប្រទេសថៃ

នៅឆ្នាំ១៩៤១ ប្រទេសថៃនៅក្រោមការគ្រប់គ្រងរបស់នាយករដ្ឋមន្ត្រីភិប៊ុនសង្គ្រាម។ ថៃបានគ្រប់គ្រងប្រទេសកម្ពុជាដែលពេលនោះ ថៃមានប្រជាធិបតេយ្យបន្តិចបន្តួចប៉ុណ្ណោះ ប៉ុន្តែវាគឺជាប្រទេសឈ្លានពានវាតទីទឹកដីប៉ុន្តែនៅគ្រាន់បើជាងបារាំងបន្តិច។ ដូចនេះអ្នកស្រុកខ្លះសប្បាយចិត្តដែរព្រោះមានសិទ្ធិសេរីភាពបន្តិចបន្តួច។ នួន ជាបានទៅបន្តរៀននៅប្រទេសថៃឆ្នាំ១៩៤២ ដោយស្នាក់អាស្រ័យនៅវត្ត។ គាត់ត្រូវបានប្តូរឈ្មោះដែលមាននាមត្រកូលរុងឡឺត ឡៅ ឌី។ គាត់ចេះតែព្រួយខ្លាចរៀនមិនទាន់គេ។ ឡៅ ឌី ចាប់ផ្តើមរៀនថ្នាក់ទី៥ដោយរៀនជាភាសាថៃ។ បន្ទាប់មក ឡៅឌី បានប្រឡងចូលត្រៀមមហាវិទ្យាល័យធម្មសាធ ផ្នែកវិទ្យាសាស្ត្រ

នយោបាយ។ គាត់ត្រូវរៀននៅថ្នាក់ត្រៀមរយៈពេលពីរឆ្នាំសិន មុននឹងចូលរៀននៅមហាវិទ្យាល័យហើយក៏ស្ថិតនៅក្នុងអំឡុងពេលដែលសង្គ្រាមចាប់ផ្ទុះឡើងដែរ។ នៅក្នុងថ្នាក់មានតែគាត់ម្នាក់ទេ ដែលជាខ្មែរមកពីខេត្តបាត់ដំបង។ កាលពីដើមគាត់ចង់រៀនពេទ្យព្រោះគាត់គិតថារៀនពេទ្យ ដើម្បីបម្រើប្រជាជន ប៉ុន្តែគ្រួសាររបស់គាត់មិនមានប្រាក់គ្រប់គ្រាន់ដូច្នេះគាត់ក៏ផ្លាស់ប្តូរចិត្តវិញ។ គាត់គិតថានៅពេលគាត់ចូលជានិស្សិតនៅសាកលវិទ្យាល័យធម្មសាត គាត់អាចធ្វើការផងនិងរៀនផងដែលអាចឲ្យ គាត់មានប្រាក់សម្រាប់ផ្គត់ផ្គង់ការរៀនសូត្រ និងការរស់នៅ។ ឡៅឌី ចាប់ផ្តើមមានគំនិតបដិវត្តន៍ពេលរៀនត្រៀមនេះ ព្រោះគាត់មានមិត្តភក្តិហើយគាត់បានចាប់ផ្តើមអានកាសែតចម្រើន និងកាសែតកុម្មុយនីស្តជាដើម។ ឡៅឌី បានអានកាសែតក្រុមចម្រើន ហើយក៏បានភ្ញាក់រឭកយល់អំពីការជិះជាន់។ ក្នុងចំណោមនោះ គាត់បានចាប់អារម្មណ៍ទៅលើសៀវភៅ ដែលសរសេរដោយប្រសឺតសាប់ធីថន។ ប៉ុន្តែគាត់មានអារម្មណ៍សោកស្តាយដោយសារតែក្រោយមក ប្រសឺត សាប់ធីថន បានក្លាយទៅជាជនសេរីនិយម។ ការអានទាំងនេះជាមូលហេតុដែលគាត់មិនសូវបានរៀនប៉ុន្មានទេ គឺគាត់ច្រើនតែដើរស្តាប់គេធ្វើសុន្ទរកថា ជ្រើសរើសតំណាងរាស្ត្រ។ ចាប់ពីពេលនោះមកបរិយាកាសនយោបាយបានចាប់ផ្តើមក្នុងគំនិតរបស់គាត់។

តាមដែលគាត់ចាំ ពេលប្រឡងចូលមហាវិទ្យាល័យមានប្រឡងតែសេចក្តីអំពីការវិវឌ្ឍន៍នៃសង្គមមនុស្ស។គាត់បានសរសេរអំពីការវិវឌ្ឍន៍របស់សង្គម ពីសម័យសង្គមកុម្មុយនីស្តបុរាណដែលបានក្លាយទៅជា សម័យសក្តិភូមិរួចបន្តទៅសង្គមនាយទុន និងទៅសង្គមនិយមហើយទីបំផុតទៅជាសង្គមកុម្មុយនីស្ត។ គាត់វិភាគរបស់គាត់គឺផ្អែកទៅលើការវិវឌ្ឍន៍សង្គមទូទៅ។ គាត់បានសរសេរថាសង្គមកុម្មុយនីស្តបុព្វកាលគឺថាអ្វីៗរួមទាំងអស់ និងគ្រប់គ្រងដោយមេកន្ទ្រាញទាំងអស់។ បើនិយាយពីជីវភាពប្រជាជនគឺសាហាវណាស់វា



នួន ជា និង ព្រាំ ផល្លា នៅអំឡុងពេលសវនាការឆ្នាំ២០១១។ ផល្លា មានតួនាទីជាអ្នកគ្រប់គ្រងសំណុំរឿង និងអ្នកវិភាគភស្តុតាងសម្រាប់ក្រុមមេធាវីការពារក្តី នួន ជា

ផ្តាច់ការខ្លាំងណាស់តែបានម្ហូបមក គឺចែកគ្នាស៊ីអស់អត់ចេះទុកដាក់ទេៗបន្ទាប់មកបានមនុស្សវិវឌ្ឍន៍ទៅចេះធ្វើពលកម្មៗ ដូចនេះពលកម្មវាជាមូលដ្ឋាននៃការវិវឌ្ឍន៍សង្គមមនុស្សដល់មនុស្សចេះធ្វើពលកម្ម ធ្វើឲ្យការបង្កបង្កើនផលរីកចម្រើន ដែលនាំឲ្យចេះរក្សាទុកភោគផល និងបន្ទាប់មកទៅជាឯកជន ដែលបន្តមកវាជារបបសក្តិភូមិ ដែលវាវិវឌ្ឍន៍ទៅជារបបនាយទុនដែលមានការលក់ដូរ ដែលបង្កើតអ្នកមានអ្នកក្រដែលជាហេតុនាំឲ្យមានការចែកវណ្ណៈដែរគឺវណ្ណៈទាសករនិងវណ្ណៈសក្តិភូមិៗ នៅពេលសង្គមនាយទុនមានរោងចក្រវានាំទៅដល់សេរីៗ ដល់រួចទៅសង្គមនាយទុនវាកាន់តែចម្រើនឡើងទៅជាសង្គមនិយម គឺរួមស្មើគ្នាអ្នកធ្វើតិចបានហូបតិចអ្នកធ្វើច្រើនបានហូបច្រើនអ្នកមិនធ្វើអត់ហូបៗរួចដល់សង្គមនិយមវាចម្រើនទៅជាសង្គមកុម្មុយនីស្តដែលរួមទាំងអស់ៗ

សង្គមសង្គមនិយមប្រមូលដីស្រែទាំងអស់ មកធ្វើរួមគ្នាជាសហករណ៍ សង្គមនេះស្ទើរតែអស់វណ្ណៈទៅហើយៗ វណ្ណៈជិះជាន់កាន់តែទ្រោម ហើយរួចបានក្លាយជាកុម្មុយនីស្តៗ កុម្មុយនីស្តនេះគាត់មិនដឹងទេ ព្រោះកាលពីអំឡុងពេលកម្ពុជាប្រជាធិបតេយ្យមានឈ្មោះ បក្សកុម្មុយនីស្តមែន ប៉ុន្តែទៅមិនទាន់ដល់កុម្មុយនីស្តនៅឡើយទេ ព្រោះមិនទាន់សម្រេចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យដូចនេះគេហៅថាជាសង្គមប្រជាធិបតេយ្យប្រជាជនៗ ចំពោះប្រជាធិបតេយ្យវាមានប្រជាធិបតេយ្យរបស់ប្រជាជន និងប្រជាធិបតេយ្យរបស់អភិជន ប៉ុន្តែសម័យរបស់គាត់មានតែប្រជាធិបតេយ្យប្រជាជនដែលជាសម័យនៅចន្លោះសក្តិភូមិ និងសង្គមនិយមៗ នួន ជា បានប្រឡងជាប់ចូលរៀនផ្នែកច្បាប់នៅមហាវិទ្យាល័យធម្មសាជ ប៉ុន្តែគាត់មិនបានបញ្ចប់ការសិក្សារបស់



*រូបទី១ ( រាប់ពីខាងស្តាំ )៖ ប៉ុល ពត*
*រូបទី២ (រាប់ពីខាងឆ្វេង )៖ នួន ជា*
*រូបទី៣ (រាប់ពីខាស្តាំទី២) ៖ អៀង សារី*

គាត់សូម្បីតែឆ្នាំទី១ ដោយសារតែគាត់បានសម្រេចចិត្តចូលរួមក្នុងចលនាកម្មុយនីស្ត។

### ចាប់ផ្ដើមការងារ

នួន ជា បានប្រាប់ថា ជីវិតរបស់គាត់ធម្មតាដូចមិនមានមោទកភាពអីច្រើនទេ តែពេលកំពុងរៀនគាត់ក៏រកការងារបានធ្វើភ្លាម ដូច្នេះហើយក្នុងពេលដំណាលគ្នាគាត់រៀនផងធ្វើការផង។ ដំបូងឡើយគាត់ធ្វើការខាងធារាសាស្ត្រ ប៉ុន្តែគាត់ពិនិត្យមើលទៅ វាមិនទាក់ទងនឹងមុខវិជ្ជាច្បាប់ ដូច្នេះហើយគាត់ក៏សម្រេចចិត្តលាឈប់ បន្ទាប់ពីធ្វើការបានរយៈពេលតែមួយខែ។ ការងារដំបូងនោះភាគច្រើនគាត់សរសេរសារាចរលិខិតស្នាមតិចតួច និងពិនិត្យកន្លែងណាត្រូវការទឹកជាដើម។ គាត់ធ្វើការនេះ គឺគ្រាន់តែចង់បានប្រាក់ខែប៉ុណ្ណោះព្រោះមិនត្រូវជំនាញរបស់គាត់ ដែលជានិសិត្សច្បាប់។ បន្ទាប់មកទៀត គាត់ក៏ប្រឡងចូលធ្វើការនៅក្រសួងហិរញ្ញវត្ថុខាងក្រុមបញ្ជីកណ្ដាល។ បន្តធ្វើការនៅទៅនោះបានបីខែគាត់ក៏ឈប់ទៀត។ គាត់គ្រប់គ្រងបញ្ជីចំណាយមកពីគ្រប់ខេត្ត។ គាត់ចាប់ផ្ដើមហត់នឿយជាមួយការងារនេះដែលទាក់ទងនឹងតួរលេខ ហើយដែលមិនទាក់ទងនឹងមុខវិជ្ជាច្បាប់របស់គាត់។ នៅក្នុងអំឡុងពេលនោះ គាត់បានសិក្សានៅវត្តរយៈពេលបីខែ។បន្ទាប់ពីសិក្សានៅវត្ត និងធ្វើការងារក៏មានសេចក្តីប្រកាសពីក្រសួងការបរទេស ដូច្នេះគាត់ក៏ឈប់ពីការងារនៅខាងក្រសួងហិរញ្ញវត្ថុ ហើយបានប្រឡងទៅធ្វើការនៅក្រសួងការបរទេសវិញ។

ពេលធ្វើការចុង ក្រោយគឺនៅក្រសួងការបរទេស គេចាត់ឲ្យគាត់រៀបចំឯកសារ ដោយទទួលខុសត្រូវខាងផ្នែកតណ្ឌចិនបូករួមមួយទៀត។ ពេលនោះគាត់បានយល់ដឹងយ៉ាងច្រើនពីគំនិតជាតិនិយម តាមរយៈការងាររបស់គាត់។ ថ្ងៃមួយ គាត់បានជួបឯកសារមានការរាយការណ៍ពីខាងទូតខ្មែរអំពីបារាំងបាញ់ប្រជាជនលាវនៅទន្លេមេគង្គ ហើយមកបាញ់ប្រជាជនខ្មែរទៀត។គាត់ឈឺចិត្ត និងបានគិតថាប្រទេសនិងប្រជាជនខ្លួនត្រូវបានគេធ្វើបាប ហេតុដូច្នេះហើយគាត់កើតគំនិតថាតើគាត់ធ្វើការនៅទីនេះបម្រើអ្នកណា? គឺបម្រើតែវណ្ណៈកាន់អំណាចតែដដែល។ ដូច្នេះគំនិតគាត់បានចែកចេញជាពីរទីមួយ គឺបួសរហូត។ ទីពីរបើបួសដោះស្រាយបានតែផលប្រយោជន៍ផ្ទាល់ខ្លួនតែប៉ុណ្ណោះ ក៏ប៉ុន្តែបើទៅតស៊ូរំដោះជាតិគាត់អាចបម្រើប្រជាជនបានច្រើន។ គួបផ្សំគាត់មើលកាសែតឃើញលទ្ធិកុម្មុយនីស្តល្អនៅឆ្នាំ១៩៤៩ និងចិនកុម្មុយនីស្តកំពុងឡើងកាន់អំណាចផង គាត់ក៏សម្រេចចិត្តតែម្តង ប៉ុន្តែនៅប្រទាញប្រទង់គ្នារវាងប្រយោជន៍ផ្ទាល់ខ្លួនព្រោះគាត់ធ្វើការនៅក្រសួងការបរទេសនោះ ទិសដៅរបស់គាត់គឺចង់ធ្វើការងារខាងទូត។ គិតយូរទៅគាត់បានសម្រេចចិត្តតែម្តងគឺលាឈប់ធ្វើការពីក្រសួងការបរទេស ហើយចេញមកទាក់ទងជាមួយបក្សថៃដើម្បីទៅតស៊ូរំដោះជាតិរបស់គាត់។

បន្ទាប់មកបានបក្សថៃបានទាក់ទងជាមួយបក្សវៀតណាម។ គាត់ចូលមកស្រុកខ្មែរដំបូងនៅឃុំតាសាញ ស្រុកសំឡូតនៃខេត្តបាត់ដំបង។ គោលការណ៍បក្សកុម្មុយនីស្តថៃកាលនោះ គឺប្រឆាំងនឹងប្រទេសណាដែលឈ្លានពាននិងប្រឆាំងរបបសក្តិភូមិ ដើម្បីកសាងប្រទេសពីសង្គមនិយមទៅកុម្មុយនីស្តនិយម។ បក្សនេះធំដែរគឺតាំងពីសម័យជប៉ុន ប៉ុន្តែបក្សនេះគ្មានមូលដ្ឋានតាមជនបទមិនបានចុះជនបទ។ ដល់ពេលវណ្ណៈកាន់អំណាចមានការបង្ក្រាប ចាប់ខ្ទេចខ្ទីអស់ដូចនៅតណ្ឌនេស៊ីអញ្ចឹងដែរ។

នួន ជា បានពិសោធន៍នេះយក មកគិតថាបើគ្មានកសិករគឺទៅមិនរួចទេ។ គាត់បាប្រៀបធៀបស្ថានការណ៍របស់ថៃនិងស្រុកខ្មែរដើម្បីបង្កើតមាគ៌ារំដោះជាតិយ៉ាងម៉េចនេះគឺជាទិសដៅរបស់គាត់។ គាត់បានបន្តអានសៀវភៅកុម្មុយនីស្តដែលភាគច្រើននិយាយអំពីលទ្ធិម៉ាក្ស- លេនីននិងម៉ៅសេទុង។ សៀវភៅមួយដែលគាត់ចាប់អារម្មណ៍ គឺការបន្ទន់សតិអារម្មណ៍របស់ជនកុម្មុយនីស្ត ដែលនិពន្ធដោយលីវសៅស៊ីអតីត ប្រធានាធិបតីចិនដែលត្រូវបានគេចាប់ខ្លួនដោយចោទថាគាត់សេរីនិយម ប៉ុន្តែក្រោយមកបានដោះលែងគាត់វិញ។ ចំណុចដែលល្អហើយគាត់ចាប់អារម្មណ៍ គឺការកម្ចាត់ភាព

បុគ្គលនិយមហើយគិតគូររួម ប៉ុន្តែសៀវភៅគាត់ត្រូវបានគេរិះគន់ថាមិននិយាយពីវណ្ណៈ។ កម្ចាត់ធាតុបុគ្គលនិយមមានន័យថាកម្ចាត់ផលប្រយោជន៍ផ្ទាល់ខ្លួនកុំឃើញតែផលប្រយោជន៍ផ្ទាល់ខ្លួនកុំមានតែអញ។ បើមានអញមានខ្លួនអញបើមានខ្លួនអញមានម្ចាស់ម្ចាស់ សម្បត្តិអាហ្នឹង គេហៅថាអញនិយមគិតតែផលប្រយោជន៍ផ្ទាល់ខ្លួនមិនគិតដល់ផលប្រយោជន៍ជាតិ។ ស្អីក៏អញដើម្បីផលប្រយោជន៍អញមុខមាត់អញកិត្តិយសអញ។ គេថាឲ្យអញគេសរសើរអញ។ អាហ្នឹងវាចូលខាងសេរីនិយមមិនគោរពតាមការចាត់តាំងហើយការសើរើនិយមនេះគឺសំដៅដល់ការមិនឈរលើកម្មកររកសិករ ចង់ឈរលើកម្លាំងបញ្ញាជនប៉ុន្តែលិទ្ធិម៉ាក្ស-លេនីន ផ្អែកលើកម្មកររកសិករដាច់ខាតប៉ុន្តែយើងមិនចោលបញ្ញាជនអនុធនទេ ប៉ុន្តែក្រុមនេះគឺជាកម្លាំងវណ្ណៈសិរ្ស។ ការអានសៀវភៅទ្រឹស្តីនេះ គឺគ្រាន់តែជាពន្លឺទេប៉ុន្តែការអនុវត្តជាក់ស្តែងគឺទៅតាមសភាពការប្រទេស។បើយកតាមសៀវភៅម៉ាក្ស-លេនីន អាហ្នឹងគេហៅថាគម្ពីរនិយមប៉ុន្តែបើចោលទាំងអស់ ទៅជាសេរីនិយម។ ដូច្នេះវាគ្រាន់តែជាពន្លឺ ដើម្បីយើងប្រៀបធៀបសភាពការណ៍ប្រទេស និងវាគ្រាន់តែឲ្យបានជាគំនិតសម្រាប់ពិចារណា។

វាដូចជាទ្រឹស្តីព្រះពុទ្ធអញ្ចឹង ព្រះពុទ្ធគ្រាន់តែឲ្យអ្នកឯងធ្វើល្អអញ្ចឹង ប៉ុន្តែរឿងធ្វើមិនល្អអាហ្នឹងជារឿងរបស់អ្នកឯង។ ពេលដែលគាត់កំពុងអាននោះ គឺគាត់បានឃើញត្រូវទៅនឹងសភាពការប្រទេសកម្ពុជា។ មានទស្សនាវដ្តីមួយសរសេរដោយមានគូរដើមឈើមួយមាន៖ វៀតណាម លាវ ខ្មែរ ជួយគ្នាស្រោចដើមឈើ រក្សាឫសដើមឈើ រួចបានសរសេរថាទាល់តែសាមគ្គីខ្មែរវៀតណាម លាវ ទើបរំដោះជាតិបាន។ ពេលនោះ គាត់បានចាប់ផ្តើមគិតហើយរវាងគាត់ជាមួយវៀតណាមមិនមានទំនាស់ទេរវាងបុគ្គល។ ប៉ុន្តែដល់ក្រោយមកគាត់ទៅវៀតណាមឃើញសហព័ន្ធឥណ្ឌូចិន គាត់ថាមិនមែនកុម្មុយនីស្តពិតប្រាកដទេ។ វៀតណាមតែងតែនិយាយថាយើងធ្វើការគ្រាន់តែបែកបរិវេណគ្នាប៉ុណ្ណោះ ប៉ុន្តែបើតាមឥណ្ឌូចិនយើងមើលទៅគឺវាតែមួយទេ ដល់អញ្ចឹងយើងចាប់ផ្តើមដឹងពីគំនិតវៀតណាម។ ការតស៊ូ ដើម្បីរំដោះប្រទេស នួន ជា ចេញពីប្រទេសថៃនៅឆ្នាំ១៩៥០ ដោយមិនមានភារៈកិច្ចជាកម្មាភិបាលអ្វីទេ គឺគ្រាន់តែទទួលខុសត្រូវខាងឃោសនាគេហៅថាមន្ទីរឃោសនាដែលមានខ្មែរ និងវៀតណាមប៉ុន្តែវៀតណាមជាអ្នកកាន់កាប់គ្រប់គ្រង។

ការងារចម្បងគឺទៅបើកសាលាអប់រំ នៅតាមភូមិឃុំ អប់រំសហគមន៍នារីស្នេហាជាតិ អប់រំកម្មាភិបាលភូមិឃុំ។ ឯកសារអប់រំគឺអំពីការងារប្រាំជំហានគឺ ១) ស៊ើបការណ៍ ២) ឃោសនា ៣) អប់រំ ៤) ចាត់តាំង និង ៥) ដឹកនាំតស៊ូ។ ពេលនោះគាត់សង្កេតឃើញថា ទំនាក់ទំនងរវាងវៀតណាមដែលទៅជាមួយខ្មែរគឺនៅល្អទេ ប៉ុន្តែគ្រាន់តែវៀតណាមព្យាយាមធ្វើជាមេលើខ្មែរ។ដល់ពេលចូលធ្វើបដិវត្តន៍នៅព្រៃទើបគាត់បានដឹងកាន់តែច្បាស់ថាគំនិតពីររបស់គាត់កាលពីដំបូងបួស និងបដិវត្តន៍វាបែកច្បាស់ហើយដឹងថាបដិវត្តន៍ គឺជាគំនិតត្រឹមត្រូវ។

នៅឆ្នាំ ១៩៥៣ ខាងមជ្ឈិមបក្សវៀតណាមបានជ្រើសរើស នួន ជា ទៅរៀននៅវៀតណាមខាងជើង។ វៀតណាមជ្រើសរើសគាត់ ដោយសារគាត់មានកម្រិតវប្បធម៌ខ្ពស់ និងស្អាតស្អំលេចធ្លោជាងគេ។ ចលនាបដិវត្តន៍ក្នុងពេលនោះគឺប្រឆាំងនឹងបារាំងច្រើនជាង ចំណែកឯគណបក្សសង្គមរាស្ត្រនិយមមិនមែនជំទាស់ច្រើនទេ ប៉ុន្តែគ្រាន់តែគិតថាជាបរិវាររបស់បារាំងដដែល ហើយបដិវត្តន៍មិនទទួលស្គាល់ឯករាជ្យ ឆ្នាំ១៩៥៣ទេ។ ការរៀននោះគឺអំពីទស្សនៈសកលលោកបែកជាពីរកងគឺកុម្មុយនីស្តនិងចក្រពត្តិ។ ក្នុងពេលកំពុងរៀន គាត់បានមើលលក្ខខណ្ឌក្នុងបក្សឃើញថាក្រោយពេលរំដោះប្រទេសទាំង៣ ពីអាណានិគមនិយមបារាំងហើយ នឹងមានចាត់ចែងសហព័ន្ធឥណ្ឌូចិន នួន ជា ភ្ញាក់ព្រឺតពេលឃើញ ដោយគិតថាវៀតណាមពិតជាដឹកនាំជាមិនខាន។ លេខាបក្សទ្រឹងជីងខស្សាហ៍និយាយថាខ្មែរវៀតណាម លាវ ដូចជាផ្ទះមានបីបន្ទប់ក្រោមដំបូលតែមួយ។ ពេលនោះហើយ ដែលគាត់ចាប់ផ្តើមសង្ស័យពីឧបាយកល

របស់វៀតណាម។

នៅឆ្នាំ១៩៥៦នួន ជា បានបញ្ចប់ការរៀនសូត្រនៅវៀតណាមហើយបានចូលមកស្រុកខ្មែរ។ គាត់ ត្រូវបានណែនាំឲ្យស្គាល់សាឡុតសជាលើកដំបូង។ សាឡុតសបានពន្យល់អំពីសភាពការណ៍នៅភ្នំពេញ។ នួន ជា ចាប់ពីពេលនោះមកទទួលខុសត្រូវទាក់ទងខាងជនបទ។



***ភ្នំពេញថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៧៨***
***-រូបឈរកណ្តាលខាងស្តាំ៖ ប៉ុល ពត នាយករដ្ឋមន្ត្រី និងជាលេខាបក្សកុម្មុយនីស្តកម្ពុជា***
***-រូបឈរកណ្តាលខាងឆ្វេង៖ វ៉ាង តុងស៊ិន អនុប្រធានគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន***
***-រូបនៅពីក្រោយ វ៉ាង តុងស៊ិន៖ ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋ កម្ពុជាប្រជាធិបតេយ្យ***
***-រូបខាងឆ្វេងទី១៖ ហ៊ូ យ៉ាបាង អគ្គលេខាធិការគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន***
***-រូបខាងឆ្វេងទី២៖ នួន ជា ប្រធានសភាតំណាងប្រជាជន និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា***

ការកសាងបក្សបានចាប់ផ្តើមឡើងវិញ ដោយនៅឆ្នាំ១៩៦០មហាសន្និបាតបានសម្រេចជ្រើសរើស ទូ សាមុត ឡើងធ្វើជាលេខា និង នួន ជា ជាអនុលេខាបក្ស។ នៅបន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ឆ្នាំ១៩៧០សម្តេចបានអំពាវនាវឲ្យកូនចៅចូលព្រៃម៉ាគី ដែលនេះជាការជួយដល់ខ្មែរក្រហម។ពេលនោះចលនាបដិវត្តន៍បានអប់រំមិត្តៗឲ្យចុះទៅមូលដ្ឋាន និងចាប់ផ្តើមវាយយកអាវុធតាមប៉ុស្តិ៍ប៉ូលីស។ ពេលនោះការតស៊ូដោយអាវុធចាប់ផ្តើមឡើងដោយហិង្សា។ ក្រោយរំដោះ ឆ្នាំ១៩៧៥ នួន ជា នៅតែមានតួនាទីជាអនុលេខាក្សកុម្មុយនីស្តកម្ពុជាដដែល និងត្រូវបានតែងតាំងជាប្រធានសភាប្រជាជនសម្រាប់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ គឺជារបបមួយដែលត្រូវបានចោទប្រកាន់ថា បានធ្វើឲ្យប្រជាជនប្រមាណជិតពីរលាននាក់បានស្លាប់បាត់បង់ជីវិត។

## មូលហេតុរបស់ នួន ជា

គាត់បានលើកឡើងអំពីការស្លាប់ របស់ប្រជាជនថាវាមានបញ្ហាពីរដោយឡែកពីគ្នា។ ទីមួយគឺការស្លាប់បាត់បង់ជីវិតប្រជាជនស្លូតត្រង់ និងមួយទៀតគឺការស្លាប់របស់ក្រុម

ក្បត់នៅក្នុងបក្ស ដោយសារតែពួកគេមិនស្ថិតនៅក្នុងបក្សទៀតទេព្រោះពួកគេបានក្បត់ និងត្រូវបានចាត់ទុកថាជាភ្នាក់ងារបម្រើបរទេស ដែលត្រូវតែសម្លាប់ចោល។គាត់ក៏បន្ថែមទៀតថា ប៉ុល ពត ជាអ្នកសម្រេចចិត្តចុងក្រោយសម្រាប់ការសម្លាប់នេះ។ គាត់ក៏បានលើកឡើងដែរថា ប៉ុល ពត និងគាត់មិនដឹងច្រើនទេ អំពីការសម្លាប់ប្រជាជនស្លូតត្រង់ក៏ប៉ុន្តែគាត់ទទួលស្គាល់ការសម្លាប់កម្មាភិបាលក្បត់។

នៅពេលដែលឆ្លើយនឹងសំណួរថា តើជាការត្រឹមត្រូវទេក្នុងការសម្លាប់ជនក្បត់? គាត់បានឆ្លើយថា «បើថាទៅវាថាឯងយោរយោប៉ុន្តែយើងមើល គិតមើលអីចេះសមមិនសមមើលគ្រោះថ្នាក់ចំពោះជាតិប៉ុនណា? កុំឲ្យមើលជាបុគ្គលបើពួកអស់ហ្នឹងនៅ គ្រោះថ្នាក់របស់ជាតិប៉ុនណា? ត្រូវមើលអញ្ចឹងបានឃើញមើលទំហំវាអាហ្នឹងនៅនឹងទស្សនៈ។ទំហំវាប៉ុនណា? គ្រោះថ្នាក់មិនតិចទេណា។ មិនមែនតូចតាចទេមិនមែនរឿងធម្មតាទេមិនមែនរឿងបាត់បង់ទឹកដីមួយចំអាម ពីរចំអាមឯណារឿងបាត់បង់ទឹកដីប្រទេសមួយ...ជាតិកម្ពុជាមួយទាំងមូលហើយបាត់បង់រហូតរាប់សតវត្សរ៍ មិនឆាយរើទេបើពួកហ្នឹងនៅ។ កូនចៅជំនាន់ក្រោយវាទៅជាស្អី? រូបភាពជាខ្មែរប៉ុន្តែខ្លឹមសារជាស្អី? អាហ្នឹងយើងត្រូវថ្លឹងមើលអាហ្នឹងបានហ៊ានវិនិច្ឆ័យថាការដោះស្រាយហ្នឹងត្រូវ។ ប៉ុន្តែបើមិនមើលឲ្យទូលាយមើលឃើញតែចង្អៀតឃើញពីរឿងអាណិតអាសូរគ្នាអាហ្នឹងអត់ទេប្រទេសជាតិទៅហើយ» គឺមានន័យថាធ្វើខ្ញុំយួនយូរអង្វែង។ រហូតគេក្តាប់បានហើយស្មោះត្រង់នឹងគេហើយ។

ដូច្នេះហើយដើម្បីកសាងសង្គមមួយថ្មីគឺ ត្រូវធ្វើបដិវត្តន៍« គឺលុបលាងអាចាស់ចោលទៅអ្វីដែលវាអន់ថយកុំយកមកធ្វើទៀតគឺអ្វីដែលថ្មីដែលចម្រើនយកមក។ ឯដឹកនាំពីមុនគឺថាយ៉ាងម៉េច?របបចាស់ [គឺ] របបសក្តិភូមិ ក្រាប លុតពុករលួយពាលាអាវាសែស្រីសំដីងស្រីញី ស្រីខូចអីពាសពេញសង្គមបោកប្រាស់។ល្អទេអាហ្នឹងទៅយកតាមហ្នឹងបានទេអត់បានទេត្រូវដោះស្រាយឲ្យស្អាត។នេះត្រូវដោះស្រាយឲ្យស្អាតមិនមែនសម្លាប់ទេ គឺកុំឲ្យមានបញ្ហាអញ្ចឹងទៀត។ អានេះហៅថាបដិវត្តន៍គឺប្រើឲ្យទៅចម្រើនឡើង។ដូច្នេះមិនមែនផ្លាស់មនុស្សឯណា[គឺ]ផ្លាស់របប[...]មិនមែនផ្លាស់ប្តូរតែមេដឹកនាំទេគឺផ្លាស់ប្តូរសង្គមតែម្តង គឺឲ្យសង្គមទៅជាសង្គមចម្រើនសង្គមឈានទៅសង្គមនិយម គឺថារួមគ្នារស់រួមគ្នាបង្កបង្កើនផលមានអីជួយឧបត្ថម្ភគ្នាទៅវិញទៅមក កុំឲ្យជិះជាន់គ្នា គឺបានសេចក្តីថាកម្ចាត់ការជិះជាន់ក្នុងសង្គម កុំឲ្យមានវណ្ណៈជិះជាន់មនុស្សកុំឲ្យមានវណ្ណៈជិះជាន់វណ្ណៈ។ ទាំងអស់គ្នាមានហូបមានចុកមានស្លៀកមានពាក់ស្មើគ្នា នេះបានគេហៅថារបបស្អាតស្អំរបបមួយភ្លឺស្វាងរបបមួយដែលសុខសន្តិភាព។ នេះជាទិសដៅប៉ុន្តែទៅវាមិនបានវាបំផ្លាញ [តាម] សង្គ្រាមចារកម្មវាបំផ្លាញយើងភ្លាម»។ ចំពោះការកម្ចាត់គឺមានន័យថា«កម្ចាត់ធាតុ កម្ចាត់ចរិតដែលប្រើអំណាចអាជ្ញា។ ការកសាងបក្សគឺថាកុំប្រើអាជ្ញាកុំប្រើអំណាច ហើយកុំខូចកាចនឹងស្រីញីកុំវក់នឹងស្រាកុំលុយកាក់។ លុយកាក់នេះចង់និយាយអំពីសម្ភារ។ បើសម្ភារវាគ្របដណ្តប់ហើយវាទៅជាបុគ្គលនិយម។ ដូច្នេះការកសាងប្រទេសគឺកម្ចាត់ធាតុបុគ្គល និយមកម្ចាត់ធាតុមិនមែនកម្ចាត់មនុស្សទេ កម្ចាត់ធាតុបុគ្គលនិយមធាតុអត្តនោម័តិធាតុអាត្មានិយម។ ស្អីក៏ខ្លួនឯងត្រូវ ស្អីក៏ខ្លួនឯងពូកែស្អីក៏ខ្លួនឯងមិនខុស។ អានេះខ្ពស់ណាស់ផលប្រយោជន៍គឺផលប្រយោជន៍បុគ្គលមិនមែនគិត ផលប្រយោជន៍រួមឯណា។ គាត់បាននិយាយទៀតថា «បើទុកពួកហ្នឹងបាត់ប្រទេសជាតិបាត់ប្រជាជន ស្លាប់ប្រជាជន បាត់ប្រទេសកម្ពុជាគ្មានកម្ពុជាសល់ដល់ឥឡូវហ្នឹងទេ។ អាហ្នឹងសម្លាប់ជាតិ។ ផ្ទាល់ខ្លួន វាតែងតែមានមនោសញ្ចេតនាអីខ្លះក៏ប៉ុន្តែគាត់បែងចែកផ្ទាល់ខ្លួនហើយនឹងរួមច្បាស់។ បើគិតរួមយើងយកផ្ទាល់ខ្លួនជាមនោសញ្ចេតនាធ្លាប់រាប់អានគ្នា ធ្លាប់អីគ្នា ហើយជាតិទាំងមូលត្រូវយកអ្នកណា?គាត់យកជាតិហើយ ឯផ្ទាល់ខ្លួនទុកដោយឡែកសិនដោះស្រាយសិនទៅ»។ គាត់«គ្មានការសោកស្តាយអីទេ[ចំពោះការបាត់បង់ពួកហ្នឹង]។គាត់សោកស្តាយជាតិរបស់គាត់ជាង។ ជាតិគាត់ប្រឡាក់ប្រឡូកអញ្ចឹងទៅ

ហើយគាត់សោកស្តាយជាង។ គាត់ស្តាយមាគ៌ាស្តាយគោលជំហររបស់កម្ពុជាប្រជាធិបតេយ្យ គាត់ស្តាយដែលពួកហ្នឹងវាធ្វើខូចអស់ហើយ» ។

**នួន ជា តទល់នឹងតុលាការ**

នៅថ្ងៃដំបូងនៃសវនាការនួនជាបង្ហាញបំណងចង់បំភ្លឺការពិត ដែលកើតមានឡើងក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាដើម្បីប្រវត្តិសាស្ត្រមួយដ៏ត្រឹមត្រូវ។ គាត់ចាប់ផ្តើមដោយរិះគន់ថាតុលាការនេះ មិនមានភាពយុត្តិធម៌សម្រាប់គាត់តាំងពីដំបូងមកម្ល៉េះដោយហេតុថា យកតែបញ្ហាមួយចំណែកប៉ុណ្ណោះមកជំនុំជម្រះ។ គាត់និយាយថាសត្វក្រពើមួយទាំងមូលគេយកតែខ្លួនមកនិយាយ តែមិនយកក្បាល និង កន្ទុយដែលជាផ្នែកសំខាន់ក្នុងការបម្រើដល់សកម្មភាពរាល់ថ្ងៃរបស់វាឬក្នុងន័យម្យ៉ាងទៀតថាឫសគល់ និងបច្ច័យរបស់វា គឺជាអ្វីដែលបានកើតឡើងតាំងពីមុនឆ្នាំ១៩៧៥ និងក្រោយឆ្នាំ១៩៧៩ដែលតុលាការនេះមិនយកមកពិចារណា ។ តុលាការបានសម្រេចមិនយកសំណុំរឿងទាំងមូលមកដេញដោល ប៉ុន្តែផ្ទុយទៅវិញដោយគិតពីវ័យរបស់ជនជាប់ចោទតុលាការបានបំបែកនីតិវិធី ដោយយកតែផ្នែកនៃការជម្លៀសប្រជាជននៅដំណាក់កាលទី១ និងទី២មកកាត់សេចក្តី។

នៅពេលសំណុំរឿង០០២/០១ត្រូវបានបញ្ចប់ដោយនួន ជា ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត តុលាការបានរៀបចំសំណុំរឿងតូចមួយ ទីពីរមួយទៀតគឺសំណុំរឿង០០២/០២ដែលគ្របដណ្តប់លើអង្គហេតុការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី២ ដែលកម្រិតត្រឹមការប្រព្រឹត្តលើជនជាតិចាម សហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្មការដ្ឋានទំនប់១ មករាការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខភ្នំក្រោលការប្រព្រឹត្តលើពុទ្ធសាសនិកការប្រព្រឹត្តលើជនជាតិចាម ដោយមិនរួមបញ្ចូលមន្ទីរសន្តិសុខក្រូចឆ្មារ ការប្រព្រឹត្តលើជនជាតិវៀតណាមដោយមិនរួមបញ្ចូលខក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តន៍កម្ពុជានៅលើទឹកដីវៀតណាមនិងការដាក់បទបញ្ញាអំពីការរៀបការ។នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូង បានចេញសាលក្រមសម្រាប់សំណុំរឿងចុងក្រោយនេះដោយបានដាក់ទោស នួន ជា ឲ្យជាប់ឃុំមួយជីវិតចំពោះរាល់បទចោទទាំងអស់។

**នួន ជា បានឆ្លើយតបទៅនឹងសាលក្រមដែលផ្តន្ទាទោសគាត់អស់មួយជីវិតថា ៖**

«អត់អីទេ ព្រោះខ្ញុំវិភាគមុនហើយមុខជាទៅផ្លូវហ្នឹងហើយ។ ខ្ញុំមិនសោកស្តាយទេ ប៉ុន្តែខ្ញុំឈឺចាប់ចំពោះតុលាការនេះ ប៉ុន្តែខ្ញុំមិនអស់សង្ឃឹមទេ។ ពីព្រោះដូចខ្ញុំជម្រាបប្រាប់អញ្ចឹង អារឿងផ្ទាល់ខ្លួនរបស់ខ្ញុំមិនអីទេ ប៉ុន្តែអារឿងយុត្តិធម៌ប្រជាជនទាំងមូលនេះវាសំខាន់សម្រាប់ប្រទេសជាតិ ព្រោះខ្ញុំតែម្នាក់ឯងមានស្អី។ ប៉ុន្តែតុលាការនេះវាប៉ះពាល់ដល់ប្រជាជនយុត្តិធម៌របស់ជាតិទាំងមូល។ យុត្តិធម៌គ្មានទេក្នុងសកលលោកយុត្តិធម៌នៅលើអ្នកកាន់អំណាច អ្នកណាកាន់អំណាចគេថាយុត្តិធម៌។យុត្តិធម៌ ដើម្បីអ្នកកាន់អំណាចមិនមែនយុត្តិធម៌របស់ប្រជាជនទេ។ សច្ចធម៌មានវាជាធម៌មិនចេះស្លាប់។ យុត្តិធម៌ប្រែប្រួលទៅតាមអ្នកកាន់អំណាច។ ដូច្នេះខ្ញុំនៅតែថាខ្លួនខ្ញុំស្នេហាជាតិដឹងថា ខ្ញុំត្រឹមត្រូវព្រោះខ្ញុំតស៊ូដើម្បីជាតិ ប៉ុន្តែអ្នកឯងអយុត្តិធម៌មកលើខ្ញុំ ព្រោះអ្នកឯងមានអំណាច។ អំណាចរបស់អ្នកអយុត្តិធម៌។

ខ្ញុំមិនបដិសេធអ្នកដែលរងគ្រោះទេ។ ខ្ញុំនិយាយតែមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជា គឺធ្វើឲ្យអ្នកក្រមានហូបមានចុក មានស្លៀកមានពាក់ឲ្យផុតពីការជិះជាន់។ ខ្ញុំចូលរួមមរណទុក្ខខាងផ្លូវចិត្តជាមួយអ្នករងគ្រោះ។ ខ្ញុំមិនសូមអភ័យទោសទេព្រោះខ្ញុំគ្មានខុសអ្វី។ ខ្ញុំចូលរួមមរណទុក្ខសោកស្តាយ»។

នួន ជា បានស្លាប់នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩។ សាកសពរបស់គាត់ត្រូវបានបូជានៅថ្ងៃទី៩ ខែសីហា ឆ្នាំ ២០១៩។ **ព្រាំ ផល្លា**

# ឧបទ្ទវហេតុកប៉ាល់ម៉ាយ៉ាហ្គេសនៅកោះតាងក្នុងខែឧសភាឆ្នាំ១៩៧៥

## I) *សេចក្តីផ្តើម*

### *១-ទីតាំងភូមិសាស្ត្រកោះតាង*

*កោះតាង គឺជាកោះមួយក្នុងចំណោមកោះ និងកូនកោះទាំង៦៤ ស្ថិតនៅក្នុងដែនទឹកសមុទ្រនៃប្រទេសកម្ពុជា។ កោះតាងស្ថិតនៅប៉ែកនិរតី និងមានចម្ងាយប្រមាណ៥២ គីឡូម៉ែត្រពីក្រុងព្រះសីហនុ និងជាកោះមួយស្ថិតនៅចន្លោះកណ្តាលរវាងកោះពូលូវៃនិងក្រុងព្រះសីហនុ។កោះតាងស្ថិតនៅចន្លោះខ្សែរបណ្តោយ និងខ្សែរទទឹង (103°7′E 10°18′N)។*

*កោះតាងមានទំហំប្រមាណ៥,៩ គីឡូម៉ែត្រការ៉េ (បណ្តោយប្រវែង៦,៤ គីឡូម៉ែត្រ និងទទឹងចន្លោះពី០,១ដល់៣,២គីឡូម៉ែត្រ) និងជាកោះដ៏ស្រស់ស្អាតមួយដែលគ្របដណ្តប់ទៅដោយកូនភ្នំ និងព្រៃឈើប្រមាណ៩០ភាគរយ ហើយមានឆ្នេរខ្សាច់ស្អាត និងទឹកសមុទ្រថ្លា។ កោះនេះមានថ្មប៉ប្រះទឹកផ្កាថ្ម និងជីវចម្រុះជាច្រើនរស់នៅក្រោមទឹកសមុទ្រ ប៉ុន្តែមិនធ្លាប់មានប្រជាជនស៊ីវិលរស់នៅលើកោះតាងតាំងពីមុនរហូតមកទល់នឹងបច្ចុប្បន្ន។ កោះតាង គឺជាមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋានកងទ័ពជើងទឹក នៃប្រទេសកម្ពុជាដែលបានបោះទីតាំងការពារដែនកោះ និងដែនទឹកសមុទ្រកម្ពុជាចាប់ពីតាំងរបបសង្គមរាស្ត្រនិយម, របបសាធារណរដ្ឋខ្មែរ, របបកម្ពុជាប្រជាធិបតេយ្យ, របបសាធារណរដ្ឋប្រជាមានិតកម្ពុជានិងរាជរដ្ឋាភិបាលនាពេលបច្ចុប្បន្ននេះ។*

### *២- ការចូលកាន់កាប់កោះនៅដែនសមុទ្រកម្ពុជារបស់កងទ័ពខ្មែរក្រហមបន្ទាប់ពីថ្ងៃទី១៧ខែមេសាឆ្នាំ១៩៧៥*

*កងពលទី៣នៃភូមិភាគនិរតីរបស់ខ្មែរក្រហម គឺជាកងពលមួយ ដែលបានចូលកាន់កាប់កោះនិងកូនកោះនៅក្នុងដែនទឹកសមុទ្រកម្ពុជា បន្ទាប់ពីការឡើងកាន់កាប់អំណាចរបស់ខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។កងពលទី៣ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៤ ដោយតាម៉ុកលេខាភូមិភាគនិរតី ដើម្បីរួមចំណែកវាយសម្រុកចូលកាន់កាប់ទីក្រុងភ្នំពេញនៅក្នុងអំឡុងខែមេសា ឆ្នាំ១៩៧៥។ កងពលទី៣ នៃភូមិភាគនិរតីគឺជាកងទ័ពថ្មើរជើងប្រយុទ្ធនៅលើគោក។ ប្រធានកងពលទី៣ មានឈ្មោះមាស មុត ដែលជាកូនប្រសាប្រុសម្នាក់របស់តាម៉ុក (ប្រពន្ធរបស់ មាស មុត មានឈ្មោះ ខុម ត្រូវជាកូនស្រីច្បងរបស់តាម៉ុក។ ខុម ជាលេខាស្រុកត្រាំកក់តំបន់១៣ភូមិភាគនិរតី)។ មុនពេលឡើងធ្វើជាប្រធានកងពលទី៣មាសមុត គឺជាអនុលេខាតំបន់១៣នៃភូមិភាគនិរតី។*

*បំណែកសមាសភាពកងទ័ពនៃកងពលទី៣ នេះភាគច្រើន គឺជាកូនចៅរបស់កសិករធ្វើស្រែចម្ការនៅក្នុងខេត្តកំពត ខេត្តតាកែវ និងខេត្តកំពង់ស្ពឺ ដែលបានចូលធ្វើកងទ័ពខ្មែរក្រហមនៅចន្លោះពីឆ្នាំ១៩៧០ ដល់ ១៩៧៥។ ឌូ អ៊ិន មានស្រុកកំណើតនៅស្រុកព្រៃកប្បាស ខេត្តតាកែវ និងជាកងទ័ពខ្មែរក្រហមនៃកងពលទី៣ភូមិភាគនិរតី បានមានប្រ*



*កប៉ាល់ម៉ាយ៉ាហ្គេស ដឹកទំនិញរបស់សហរដ្ឋអាមេរិក។*
*រូបថត ៖ បណ្ណសារកងទ័ពអាកាសសហរដ្ឋអាមេរិក*

សាសន៍ថាខ្ញុំបានចូលបដិវត្តន៍ខ្មែរក្រហម ដោយស្ម័គ្រចិត្ត ក្នុងឆ្នាំ១៩៧២ នៅមុនដំបូងធ្វើជាកងឈ្លបនៅឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស។ នៅក្នុងឆ្នាំ១៩៧៣ខ្មែរក្រហមបានបញ្ជូន អ៊ុន ឲ្យមកធ្វើជាកងទ័ពតំបន់៣៣ បន្ទាប់ហាត់រៀនយុទ្ធសាស្ត្រកងទ័ពមួយរយៈពេលខ្លី ខ្មែរក្រហមបានបញ្ជូន អ៊ុន ឲ្យទៅវាយជាមួយទាហានរបបសាធារណរដ្ឋខ្មែរនៅព្រៃលកមៀត ភ្នំស្រួចផ្លូវជាតិលេខ៤។ នៅក្នុងឆ្នាំ១៩៧៤ អ៊ុន ត្រូវបានចាត់តាំងបញ្ចូលក្នុងកងពលទី៣ របស់ភូមិភាគនិរតី។ ប៉ាក់ សុខ មានស្រុកកំណើតនៅស្រុកឈូក ខេត្តកំពត និងបានចូលធ្វើបដិវត្តន៍ខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧២ ពេលនោះ សុខ មានអាយុជាង១០ឆ្នាំ។ បន្ទាប់មកខ្មែរក្រហមចាត់តាំងឲ្យ សុខ បម្រើជាកងទ័ពតំបន់៣៥ ការចូលធ្វើកងទ័ពគឺសុខបានហាត់រៀនបាញ់កាំភ្លើងក្រាបលូនតែបន្តិចបន្តួច បន្ទាប់មកក៏បានចូលសមរភូមិវាយជាមួយទាហាន លន់ នល់ តែម្តង។

នៅឆ្នាំ១៩៧៤ ខ្មែរក្រហមបានបញ្ជូន សុខ មកចូលនៅក្នុងកងពលទី៣របស់ភូមិភាគនរតី។ ចំណែក ម៉ៅ វ៉ាន់ ដែលជាអតីតកងទ័ពខ្មែរក្រហមម្នាក់ នៅក្នុងកងវរសេនាតូច ៤១០នៃកងពលទី៣ភូមិភាគនិរតីដែរនោះ បានមានប្រសាសន៍ថាគាត់មានស្រុកកំណើតនៅស្រុកកងពិសី ខេត្តកំពង់ស្ពឺ និងបានចូលធ្វើកងឈ្លបនៅក្នុងឆ្នាំ១៩៧២ និងបន្តឡើងមកធ្វើជាកងទ័ពតំបន់៣៣។ នៅក្នុងឆ្នាំ១៩៧៤ ខ្មែរក្រហមបានបញ្ជូនវ៉ាន់មកបញ្ចូលក្នុងកងពលទី៣នេះតែម្តង។ កងពលទី៣ នៃភូមិភាគនិរតីភាគច្រើនធ្វើសកម្មភាពប្រយុទ្ធជាមួយទាហានរបបសាធារណរដ្ឋខ្មែរតាមផ្លូវជាតិលេខ៤ នៅម្តុំដោះកញ្ជរ ស្រែខ្ពង់ មហាសាំងក្នុងស្រុកភ្នំស្រួច ។ ខ្មែរក្រហមក៏ធ្លាប់បានបញ្ជូនកងពលលេខ៣ ទៅវាយនៅខាងកំពង់ឆ្នាំង ដូចជានៅលង្វែក សាលាលេខ៥ ដាំផ្កា បន្ទាប់មកទើបដកត្រឡប់មកផ្លូវជាតិលេខ៤ ខេត្តកំពង់ស្ពឺវិញ។ នៅក្នុងមេសា ឆ្នាំ១៩៧៥ កងពលទី៣នៃភូមិភាគនិរតីត្រូវបានខ្មែរក្រហមចាត់តាំងឲ្យវាយចូលទីក្រុងភ្នំពេញតាមទិសផ្លូវជាតិលេខ៤។ នៅខណៈពេលដែលកងទ័ពនៃកងពលទី៣ បានចូលមកដល់ចោមចៅ និងព្រលានយន្តហោះពោធិ៍ចិនតុងនោះ ប្រធានកងពលទីមាសមុតបានបញ្ជាឲ្យកងទ័ពនៃកងពលទី៣ ទាំងអស់ដកត្រឡប់ក្រោយមកឈរជើងនៅម្តុំដម្ពូវត្ត័, បែកចានដើម្បីធ្វើដំណើរមកបោះទីតាំងនៅកំពង់សោម ។ បន្ទាប់ពីកងទ័ពស្នាក់នៅមូលដ្ឋានកងទ័ពរាម បានរយៈពេលពីរបីថ្ងៃ មាសមុតបានបញ្ជាឲ្យកងទ័ពនៃកងពលទី៣ មួយចំនួនធ្វើដំណើរទៅឈរជើងនៅលើកោះដែលជាដែនទឹកនៃប្រទេសកម្ពុជានិងអតីតកោះរបស់កម្ពុជា មួយចំនួនទៀតដែលគ្រប់គ្រងដោយប្រទេសវៀតណាម ។

### ៣ - កងវរសេនាតូចនៃកងពលទី៣ ដែលឈរជើងនៅលើកោះតាង

មាស មុត ដែលជាប្រធានកងពលទី៣ បានចាត់តាំងឲ្យកងវរសេនាតូចលេខ៤១០នៃវរសេនាធំ២១ទៅប្រចាំការនៅតាមកោះដូរមុខមួយចំនួនដូចជា កោះពូលូវ៉ៃ, កោះតាងនិងកោះព្រីង។ កងវរសេនាតូច៤១០ មានប្រធានទទួលបន្ទុកនយោបាយឈ្មោះហម និងអនុប្រធានទទួលបន្ទុកខាងយោធាឈ្មោះសំណាង។ វរសេនាតូច៤១០ រួមមាន៤កងអនុសេនាធំគឺកងអនុសេនាធំ(គ-៧), កងអនុសេនាធំ (គ-៨), កងអនុសេនាធំ(គ-៩)និងកងអនុសេនាធំ(គ-១០)។បន្ទាប់ពីរំដោះភ្នំពេញថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ កងទ័ពនៃកម្លាំងវរសេនាតូច៤១០មួយចំនួនបានស្លាប់នៅលើសមរភូមិ និងមួយ



កងទ័ពជើងទឹកសហរដ្ឋអាមេរិករត់ចេញពីឧទ្ធម្ភាគចក្រដែលចុះចតនៅលើកោះតាង មានចម្ងាយ៣០ម៉ាយពីឆ្នេរសមុទ្រកម្ពុជា

ចំនួនទៀតបានបែកខ្ញែកនៅខណៈពេលដែលត្រូវបញ្ជូនទៅឈរជើងនៅតាមកោះ គឺកងវរសេនាតូច៤១០ មានកងទ័ពចំនួនប្រមាណជា២០០នាក់តែប៉ុណ្ណោះ (កម្លាំងសរុបរបស់វរសេនាតូច៤១០មានប្រហែល៤០០នាក់កាលពីមុនពេលវាយចូលទីក្រុងភ្នំពេញ)។ ប្រធាននិងអនុប្រធានវរសេនាតូច៤១០ ឈ្មោះ ហម និង សំណាង មានភារកិច្ចប្រចាំការនៅទីបញ្ជាការកងវរសេនាតូច៤១០នៅរាម គឺមិនទៅឈរប្រចាំការនៅតាមកោះជាមួយកងទ័ពឡើយ ។ ខ្មែរក្រហមបានបែងចែកឲ្យកងអនុសេនាធំ(គ-៨) និងកងអនុសេនាធំ (គ-១០)ត្រូវឈរជើងប្រចាំការនៅលើកោះតាងក្នុងនោះអនុសេនាធំ (គ-១០) ឈរជើងនៅម្តុំឆ្នេរខាងលិចនិងអនុសេនាធំ( គ- ៨) ប្រចាំការនៅម្តុំប៉ុស្តិ៍ទាហានចាស់ (នៅឆ្នេរខាងកើត)។ ចំណែកកងអនុសេនាធំ(គ-៧)និងកងអនុសេនាធំ(គ-៩)ត្រូវបានចាត់តាំងឲ្យទៅយាមប្រចាំការនៅកោះពូលូវៃ និងកោះព្រីង(កោះព្រីងមានកងទ័ពតែមួយអនុសេនាតូច)។ មេបញ្ជាការខ្មែរក្រហមដែលប្រចាំការនៅកោះតាងរួមមាន ឈ្មោះម៉េន ប្រធានកងអនុសេនាធំ(គ-៨) និងឈ្មោះ ម៉ន ប្រធានកងអនុសេនាធំ (គ-១០)។

កងកម្លាំងសរុបនៅលើកោះតាងមានចំនួនប្រហែល ១០០នាក់(ចំនួនកងទ័ពបញ្ចូលគ្នាទាំងពីរអនុសេនាធំ គ-៨ និងគ-១០) ប៉ុន្តែដោយសារខ្មែរក្រហម ត្រូវបញ្ជូនកងទ័ពទៅកាន់កាប់កោះក្រចកសេះ(ពូលូប៉ងសង់)ថែមទៀតនោះ ខ្មែរក្រហមបានបញ្ជាឲ្យដកកងទ័ពមួយចំនួនពីគ-៨និងគ-១០រួមមានប្រធានកងអនុសេនាធំឈ្មោះម៉េនម៉ន និងកងទ័ពមួយចំនួនទៀតបានទៅចូលរួមជាមួយកងវរសេនាតូចលេខ ៤៧០ ដែលមានមេបញ្ជាការឈ្មោះទន ដើម្បីធ្វើដំណើរទៅកាន់កាប់កោះក្រចកសេះពូលូប៉ងសង់ពីប្រទេសវៀតណាម។ ដូច្នេះកងទ័ពខ្មែរក្រហមដែលនៅសេសសល់ និងបានប្រយុទ្ធជាមួយទាហានសហរដ្ឋអាមេរិកនៅកោះតាងក្នុងថ្ងៃទី១៥ ខែឧសភាឆ្នាំ១៩៧៥គឺមានចំនួនប្រហែលជា៥០នាក់ និងមានឈ្មោះប្រេះហ៊ិននិងម៉ៅវ៉ាន់ដែលជាប្រធានកង អនុសេនាតូចចំណុះឲ្យគ-៨និងគ-១០ជាអ្នកដឹកនាំប្រយុទ្ធ។

## II) ខទ្ធវហេតុកប៉ាលម៉ាយ៉ាហ្គេសនៅកោះតាង

### ១- ព្រឹត្តិការណ៍ចាប់កប៉ាល់ម៉ាយ៉ាហ្គេស និងការបញ្ជូនមកចតនៅកោះតាង

កប៉ាលម៉ាយ៉ាហ្គេស (S.S. Mayaguez) គឺជាកប៉ាលដឹកទំនិញចំណាស់មួយរបស់ក្រុមហ៊ុន ឯកជនសហរដ្ឋអាមេរិកដែលមានចំណុះ១០,៤៨៤តោន ។

បន្ទាប់ពីរបបក្រុងសៃហ្គនបានដួលរលំទៅប្រហែលជាជិត២សប្តាហ៍ គឺនៅថ្ងៃទី១២ ខែឧសភាឆ្នាំ១៩៧៥កប៉ាល់ម៉ាយ៉ាហ្គេស បានដឹកទំនិញសម្ភាររបស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងសៃហ្គន ប្រទេសវៀតណាមខាងត្បូង និងទំនិញផ្សេងៗទៀត បានធ្វើដំណើរចេញពីទីក្រុងហុងកុង ឆ្លងកាត់តាមឈូងសមុទ្រថៃឡង់ដ៍ ឆ្ពោះទៅកាន់ទីក្រុងកំពង់ផែសាតតាហ៊ីប ខេត្តឈុនបុរីនៃប្រទេសថៃ។ នៅខណៈពេលដែលកប៉ាល់ម៉ាយ៉ាហ្គេសបានធ្វើដំណើរមកប្រឈមជាមួយកោះពូលូវ៉ៃរបស់ប្រទេសកម្ពុជាកងទ័ពខ្មែរក្រហមដែលឈរជើងនៅកោះពូលូវ៉ៃ គឺជាកងទ័ពដែលមិនមានជំនាញខាងជើងទឹកបន្តិចនោះ បានបើកកប៉ាល់ប្រភេទ ប៉េ-សេ-អេហ្វ [Patrol Craft Fast (PCF)/Swift Boat] ចំនួន២គ្រឿងនិងមានកងទ័ពប្រមាណជាង១០នាក់ប្រកបដោយអាវុធគ្រប់ដៃបានចេញដំណើរទៅស្ទាក់ចាប់កប៉ាល់ម៉ាយ៉ាហ្គេស ដែលស្ថិតនៅចម្ងាយប្រមាណជាង១០គីឡូ ម៉ែត្រពីកោះពូលូវ៉ៃ។ កងទ័ពខ្មែរក្រហមបានបាញ់កាំភ្លើងអឹម-៧៩ ជាសញ្ញាឲ្យកប៉ាលម៉ាយ៉ាហ្គេសឈប់ បន្ទាប់មកកងទ័ពខ្មែរក្រហមបានបញ្ជាឲ្យនាវិក បើកកប៉ាលម៉ាយ៉ាហ្គេសចូលមកកោះពូលូវ៉ៃជាមួយកប៉ាលប៉េ-សេ-អេហ្វរបស់ខ្លួន។ បន្ទាប់ពីចតនៅកោះពូលូវ៉ៃមួយយប់គឺនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៥ខ្មែរក្រហមបានបញ្ជូនកប៉ាល់ម៉ាយ៉ាហ្គេស ពីកោះពូលូវ៉ៃមកកាន់កោះតាង។នៅខណៈពេលចាប់កប៉ាលម៉ាយ៉ាហ្គេសនេះ កងទ័ពខ្មែរក្រហម ក៏បានរាយការណ៍តាមវិទ្យុទាក់ទងទៅកាន់ទីបញ្ជាការធំនៅកំពង់សោម។ មុនដំបូងបញ្ជាការដ្ឋាននៅកំ

ពង់សោម បានបញ្ជាឲ្យទុកកប៉ាល់ម៉ាយ៉ាហ្គេសនៅកោះពូលូវៃមួយយប់ បន្ទាប់មកត្រូវបញ្ជូនកប៉ាល់ម៉ាយ៉ាហ្គេស និងក្រុមនាវិកមកកោះតាង និងបញ្ជូនបន្តមកកំពង់សោម។ ប៉ុន្តែនៅពេលដែលបញ្ជូនកប៉ាល់ម៉ាយ៉ាហ្គេស និងក្រុមនាវិកមកដល់កោះតាងហើយកងទ័ពខ្មែរក្រហម បានឡើងទៅយាមការពារនៅលើកប៉ាលម៉ាយ៉ាហ្គេស បានរយៈពេលមួយយប់មួយថ្ងៃក៏មានការប្រែប្រួល គឺព្រលប់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៥ ខាងទីបញ្ជាការធំនៅកំពង់សោមក៏បានប្រាប់មកទៀតថា ត្រូវឲ្យកងទ័ពខ្មែរក្រហមចុះចេញពីលើកប៉ាល់ម៉ាយ៉ាហ្គេសទាំងអស់ ហើយបញ្ជាឲ្យកងទ័ពខ្មែរក្រហមយក



រូបថតពីលើអាកាសបង្ហាញពីឆ្នេរខាងលិច និងខាងកើតកោះតាង នៅថ្ងៃ១៤ ខែឧសភា ឆ្នាំ១៩៧៥។

ក្រុមនាវិកទាំងអស់ចេញពីកប៉ាល់ និងដឹកមកទុកនៅកោះរ៉ុង (កោះរ៉ុងសន្លឹម)។ ចំណែកកប៉ាល់ម៉ាយ៉ាហ្គេសត្រូវទុកនៅកោះតាង គឺមិនចាំបាច់បញ្ជូនមកកំពង់សោមឡើយ។ អតីតកងទ័ពខ្មែរក្រហម ដែលបានឈរជើងនៅលើកោះតាង ឈ្មោះ ប៉ាក់ សុខ បានរៀបរាប់ថា រហូតដល់យប់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៥ ទើបមានបញ្ជាឲ្យកងទ័ពចុះពីកប៉ាល់ម៉ាយ៉ាហ្គេសមកនៅលើកោះវិញ នៅខណៈពេលនោះខ្មែរក្រហមបានបញ្ជាឲ្យក្រុមនាវិកទាំងអស់ ចុះពីលើកប៉ាល់ម៉ាយ៉ាហ្គេសដែរ ប៉ុន្តែនៅមានសល់នាវិកម្នាក់លាក់ខ្លួនក្នុងកប៉ាល់ដែលកងទ័ពខ្មែរក្រហមរកមិនឃើញ។ នាវិកម្នាក់នោះប្រហែលជាកាន់ខាងទូរលេខផងបានទាក់ទងទៅខាងសហរដ្ឋអាមេរិករហូត បន្ទាប់មកនាវិកនោះក៏បានឡើងជិះអូមបរបើកសំដៅទៅរកនាវាចម្បាំងសហរដ្ឋអាមេរិកបាត់ទៅ។ អតីតប្រធានកងអនុសេនាតូចចំណុះឲ្យកងអនុសេនាធំ (គ-១០)នៃកងទ័ពខ្មែរក្រហមដែលធ្លាប់ឈរជើងនៅកោះតាងឈ្មោះ ប្រេះ ហ៊ិន ក៏បានឲ្យដឹងថា មេបញ្ជាការវរសេនាតូច៤១០ ឈ្មោះ សំណាង និងកងទ័ពខ្មែរក្រហមផ្សេងទៀតបានបើកកប៉ាល់ ប៉េ-សេ-អេហ្វ ពីកោះពូលូវៃមកកោះតាងជាមួយកប៉ាល់ម៉ាយ៉ាហ្គេសដែរ។ ហ៊ិន និងកងទ័ពផ្សេងទៀតត្រូវបានចាត់តាំងឲ្យយាមការពារកប៉ាល់ម៉ាយ៉ាហ្គេស។ បន្ទាប់ពីយាមការពារនៅលើកប៉ាល់បានរយៈពេល មួយយប់មួយថ្ងៃគឺនៅព្រលប់ថ្ងៃទី១៤ ខែឧសភា ក៏មានបញ្ជាពីកំពង់សោមមកឲ្យកងទ័ពទាំងអស់ចុះចេញពីកប៉ាល់មកនៅលើកោះវិញ។ ចំណែកក្រុមនាវិកនៃកប៉ាល់ម៉ាយ៉ាហ្គេសទាំងអស់ត្រូវបញ្ជូនមកទុកនៅកោះរ៉ុង។ ខ្មែរក្រហមបានយកទូកនេសាទថៃ ដែលកងទ័ពខ្មែរក្រហមចាប់បាន មុនពេលព្រឹត្តការណ៍កប៉ាល់ម៉ាយ៉ាហ្គេសនេះឲ្យដឹកក្រុមនាវិកទាំងអស់ទៅកាន់កោះរ៉ុង ដោយកងទ័ពខ្មែរក្រហមបញ្ជាឲ្យអ្នកនេសាទថៃ ដែលចាប់មកជាមួយទូកនេសាទជាអ្នកបើកទូកដឹកក្រុម នាវិក។ ចំណែកកងទ័ពខ្មែរក្រហមក៏បានជិះកប៉ាល់ ប៉េ-សេ-អេហ្វ អមមកជាមួយដែរ។ នៅពេលធ្វើដំណើរ ជិតដល់កោះរ៉ុងនៅវេលារំលងអាធ្រាតឈានចូលថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៥ ទីបញ្ជាការធំនៅកំពង់សោមបានបញ្ជាឲ្យកងទ័ពខ្មែរក្រហម ដោះលែងក្រុមនាវិកទាំងអស់ត្រឡប់ទៅប្រទេសថៃវិញ។

## ៧- ការប៉ះទង្គិចរវាងទាហានសហរដ្ឋអាមេរិក និងកងទ័ពខ្មែរក្រហមនៅកោះតាង

បន្ទាប់ពីកងទ័ពខ្មែរក្រហមចាប់កប៉ាល់ម៉ាយ៉ាហ្គេស វិទ្យុសំឡេងសហរដ្ឋអាមេរិក បានផ្សាយជាញឹកញាប់ឲ្យរដ្ឋាភិបាលខ្មែរក្រហម ដែលចូលកាន់កាប់ទីក្រុងភ្នំពេញថ្មីៗដោះលែងកប៉ាល់ម៉ាយ៉ាហ្គេស និងក្រុមនាវិកឲ្យត្រឡប់ទៅវិញជា

បន្ទាន់បើមិនដូច្នេះទេ ទាហានសហរដ្ឋអាមេរិកនឹងមកកម្ទេចកោះតាង និងក្រុងកំពង់សោមឲ្យក្លាយទៅជាផេះតែម្ដង។ នៅវេលាយប់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៥ ថ្នាក់ដឹកនាំ ខ្មែរក្រហមក៏បានបញ្ជាឲ្យកងទ័ពខ្មែរក្រហមដោះលែងក្រុមនាវិកដើម្បីធ្វើដំណើរទៅប្រទេសថៃវិញ ប៉ុន្តែនៅពេលកំពុងតែរៀបចំដោះលែងឲ្យកប៉ាល់ម៉ាយ៉ាហ្គេស ត្រឡប់ទៅវិញនោះស្រាប់តែនៅព្រលឹមស្រាងៗថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៥ នោះសហរដ្ឋអាមេរិកបានបញ្ជូនយន្តហោះទម្លាក់គ្រាប់បែកមកទម្លាក់ជុំវិញកប៉ាលម៉ាយ៉ាហ្គេស និងជុំវិញកោះតាង។ នៅពេលដំណាលគ្នានេះដែរ មានទាហានសហរដ្ឋអាមេរិកប្រមាណជិត២០០នាក់ បានជិះឧទ្ធម្ភាគចក្រចំនួន៨គ្រឿងចេញពីមូលដ្ឋានទាហានជើងអាកាសរបស់សហរដ្ឋអាមេរិកនៅអូរតាប៉ាវប្រទេសថៃមកចុះនៅលើកោះតាង។

ចំណែក នាវាចម្បាំង អូមបរ និងសម្ភារមួយចំនួនទៀតក៏ត្រូវបានយកមកដាក់នៅជិតកោះតាង ក្នុងគោលបំណងវាយរំដោះយកកប៉ាល់ម៉ាយ៉ាហ្គេស និងក្រុមនាវិកយកត្រឡប់ទៅវិញ។នៅព្រឹកថ្ងៃដដែលនោះ សហរដ្ឋអាមេរិកក៏បានបញ្ជូនយន្តហោះឲ្យទៅទម្លាក់គ្រាប់បែក នៅកំពង់ផែកំពង់សោម, រោង ចក្រប្រេងកាតនៅកំពង់សោមរោងចក្រទឹកដោះគោនិងមូលដ្ឋានកងទ័ពជើងទឹកខ្មែរក្រហម នៅរាមធ្វើឲ្យមានការខូចខាតយ៉ាងដំណំ ។

ចាប់ផ្ដើមតាំងពីព្រលឹម ទាហានសហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកនៅលើកោះតាង បាញ់ផ្សែងពុល និងបញ្ជាឲ្យឧទ្ធម្ភាគចក្របន្ទាបចុះ ដើម្បីឲ្យទាហានរបស់ខ្លួនចុះតាមជណ្ដើរមកប្រយុទ្ធនៅលើដីផ្ទាល់ ដោយចាប់ផ្ដើមពីឆ្នេរខាងលិចនៃកោះតាង និងបន្តប្រយុទ្ធនៅឆ្នេរខាងកើត នៅក្នុងពេលកំពុងប្រយុទ្ធនោះទាហានសហរដ្ឋអាមេរិក បានបើកកប៉ាល់ម៉ាយ៉ាហ្គេសចាកចេញពីកោះតាងផងដែរ។ការប្រយុទ្ធបានចាប់ផ្ដើមតាំងពីព្រលឹមរហូតដល់ពេលរសៀល កងទ័ពខ្មែរក្រហមដែលប្រចាំការនៅឆ្នេរភាគខាងលិច និងឆ្នេរភាគខាងកើតបានអស់គ្រាប់កាំភ្លើង និងបានបាក់ទ័ពរត់គេចខ្លួនចូលក្នុងព្រៃ និងឡើងលើភ្នំស្ទើរតែទាំងអស់។ ចំណែកទាហានសហរដ្ឋអាមេរិកក៏ចាប់ផ្ដើមប្រមែប្រមូលទាហាន និងសាកសពទាហានដើម្បីធ្វើដំណើរត្រឡប់ទៅមូលដ្ឋានកងទ័ពនៅអូរតាប៉ាវនៃប្រទេសថៃវិញនៅម៉ោងប្រហែលជា៨ យប់ក្នុងថ្ងៃដដែល ។

ប៉ាក់ សុខ បានរៀបរាប់ថា ទាហានអាមេរិកាំងបានចុះឧទ្ធម្ភាគចក្រ២គ្រឿងនៅលើកោះតាង ខ្ញុំកាន់កាំភ្លើងអា១២,៧ (ដូសេត)កាំភ្លើងនោះអត់មានជើងទេ គឺខ្ញុំបានចងខ្សែបាញ់តែម្ដង។ នៅខណៈពេលនោះខ្ញុំត្រូវរបួសហើយគឺត្រូវគ្រាប់ទាហានអាមេរិកាំងបាញ់ពីខាងលើចុះមក និងត្រូវផ្សែងពុលទៀតនោះគឺខ្ញុំរត់ទៅណាលែងរួចតែម្ដង។ បន្ទាប់ពីងើបពីពុលមកខ្ញុំបានបាញ់ទៀតគឺបាញ់រហូតដល់ដាច់កន្ទុយនិងធ្លាក់ឧទ្ធម្ភាគចក្រមួយគ្រឿង។ ខ្ញុំបន្តបាញ់ឧទ្ធម្ភាគចក្រមួយគ្រឿងទៀតដែលបានហោះឆ្លៀលនៅជិតខ្ញុំ ហើយខ្ញុំបានបាញ់ធ្លាក់ប្រហែលជាង១០ម៉ែត្រពីកន្លែងខ្ញុំ។

ប្រេះ ហ៊ិនដែលជាអតីតប្រធានកងអនុសេនាតូចចំណុះកងអនុសេនាធំ( គ- ១ ០ ) នៃកងទ័ពខ្មែរក្រហមប្រចាំនៅឆ្នេរភាគខាងលិចក៏បានឲ្យដឹងថា នៅព្រឹកព្រលឹមឡើងទាហានសហរដ្ឋអាមេរិកបានប្រើឧទ្ធម្ភាគចក្រ យន្តហោះធុនមិចនិង F-105ចាប់ផ្ដើមទម្លាក់និងវាយនៅកោះតាងហើយទាហានសហរដ្ឋអាមេរិក ក៏បានយកកប៉ាល់ម៉ាយ៉ាហ្គេសចេញពីកោះតាងភ្លាមៗ នៅខណៈពេលដែលកំពុងតែប្រយុទ្ធគ្នានោះ។មុននឹងឧទ្ធម្ភាគចក្របានចុះចតលើកោះតាង គឺកម្លាំងខ្យល់របស់ឧទ្ធម្ភាគចក្របានបក់បោកស្មៅ និងកូនឈើតូចៗរាបដល់ដីទាហានអាមេរិកាំងបានមើលឃើញកងទ័ពខ្មែរក្រហមច្បាស់ទោះបីជីកលេណដ្ឋានជម្រៅណាក៏ដោយ។ ហ៊ិនក៏បានបន្ថែមថាកងទ័ពខ្មែរក្រហមមានតែកាំភ្លើងដូសេត(១២,៧) មួយដើម មីតត្រេ យី(A kind of Mitrailleuse) មួយដើម បេ-៤០មួយដើម អឹម-៧៩មួយដើម និងកាំភ្លើងដៃ(AK-47 and M-16)ហើយពេលវាយជាមួយទាហានអាមេរិកាំងនោះ កងទ័ពខ្មែរក្រហមបានចាញ់បានរត់ខ្ចាត់ខ្ចាយចូលព្រៃ និង

ឡើងភ្នំអស់។ហ៊ានផ្ទាល់ក៏បានរត់បែកពីកងទ័ពផ្សេងទៀតនិងបានអត់បាយរយៈពេលថ្ងៃគឺអត់បាយផងដើររកកងទ័ពផ្សេងទៀតផងៗ

ម៉ៅ វ៉ាន់ គឺជាអតីតប្រធានកងអនុសេនាតូចចំណុះកងអនុសេនាធំ(គ-៨)នៃកងទ័ពខ្មែរក្រហម ប្រចាំនៅឆ្នេរភាគខាងកើតបានបញ្ជាក់ថា មុនដំបូងទាហានអាមេរិកាំងបានទម្លាក់ទាហានរបស់ខ្លួនលើកោះតាង ចតកប៉ាល់ជុំវិញកោះតាងហើយទើបទាហានអាមេរិកាំងមកវាយ នៅលើកោះតាងដោយទម្លាក់គ្រាប់ផងបាញ់ផងៗ កងទ័ពខ្មែរក្រហមទើបដឹកលេណដ្ឋានបានខ្លះអត់ខ្លះ និងភាគច្រើនប្រើប្រាស់តែកាំភ្លើងដៃដូចជាអាកា៤៧ និងអឹម-១៦ៗ ចំណែកទាហានអាមេរិកាំងបានប្រើប្រាស់កាំភ្លើងទំនើបៗ និងទូកម្ពុជា(ទូកចក្រ)ច្រើនគ្រឿងរាប់មិនអស់ទេៗ វ៉ាន់ បន្ថែមថា ទាហានសហរដ្ឋអាមេរិកវាយកងទ័ពខ្មែរក្រហមខ្លាំងមែនទែនរួមទាំងជើងគោក និងជើងអាកាសផងដល់ទៅវាយខ្លាំងអីចឹង កងទ័ពខ្មែរក្រហមមានគ្រាប់ប៉ុន្មាន គឺចាប់ពីពេលព្រឹករហូតដល់ថ្ងៃរសៀលនោះ គឺកងទ័ពខ្មែរក្រហមទប់លែងបានទៀតហើយ គឺរត់ចូលព្រៃនិងឡើងភ្នំអស់ៗ

## III) ការស្លាប់ និងការខូចខាតសម្ភារចំពោះខបទ្ធវហេតុកប៉ាល់ម៉ាយ៉ាហ្គេស

### ១- ចំនួនកងទ័ពខ្មែរក្រហម និងទាហានអាមេរិកដែលបានស្លាប់

អតីតកងទ័ពខ្មែរក្រហម ដែលបានចូលរួមប្រយុទ្ធនៅលើកោះតាងមិនបានដឹងចំនួនកងទ័ពដែលបានស្លាប់ និងបាត់ខ្លួនប៉ុន្មាននាក់ឡើយៗ កងទ័ពខ្មែរក្រហមគ្រាន់តែបានដឹងថានៅពេលដើរប្រមែប្រមូលសាកសពបានឃើញ កងទ័ពខ្មែរក្រហមចំនួន៧ នាក់បានបាត់បង់ជីវិតនិងមួយចំនួនទៀត ( មិនដឹងចំនួនពិតប្រាកដ) ត្រូវបានទាហានសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកត្រូវកប៉ាល ប៉េ-សេ -អេហ្វ របស់កងទ័ពខ្មែរក្រហមលិចចូលទៅក្នុងទឹកសមុទ្រ នៅខណៈពេលដែលកងទ័ពខ្មែរក្រហមទាំងនោះធ្វើដំណើរត្រឡប់មកកោះតាងបន្ទាប់ពីជូនក្រុមនាវិកនៃកប៉ាលម៉ាយ៉ាហ្គេសទៅកោះរ៉ុង និងបានដោះលែងក្រុមនាវិកទាំងនោះឲ្យត្រឡប់ទៅ ប្រទេសថៃវិញៗកងទ័ពខ្មែរក្រហមក៏មិនបានដឹងថាទាហានសហរដ្ឋអាមេរិកប៉ុន្មានបានស្លាប់បាត់បង់អាយុជីវិតដែរ គឺកងទ័ពខ្មែរក្រហមបានដឹងត្រឹមតែថាមានទាហានសហរដ្ឋអាមេរិក បានស្លាប់ច្រើន ពេលកងទ័ពបាញ់ធ្លាក់ទូកម្ពុជា(ទូកចក្រ)នោះឃើញមានក្បាល ដៃ ជើងបានឆេះរឡោះរលួយនៅក្បែរទូកម្ពុជា(ទូកចក្រ)ៗ

កងទ័ពខ្មែរក្រហម ក៏រកឃើញសាកសពទាហានអាមេរិកចំនួន២ ដែលបានរុំថង់កៅស៊ូរួចរាល់នៅលើកោះតាងនិងទាហានចំនួន៣ នាក់ទៀតនៅមានជីវិតបន្ទាប់ពីទាហានសហរដ្ឋអាមេរិកបានដកត្រឡប់ទៅវិញនៅព្រលប់ថ្ងៃដដែលៗទាហានអារិកទាំង៣ នាក់នោះបានស្លាប់ជាបន្តបន្ទាប់នៅរយៈពេលប៉ុន្មានថ្ងៃក្រោយមក ម្នាក់ស្លាប់ដោយសាររបួសនិងអត់អាហារៗ ចំណែក២នាក់ទៀត បានស្លាប់ដោយសារកងទ័ពខ្មែរក្រហមបោកគ្រាប់បែក ខណៈពេលកំពុងដួតទឹកសមុទ្រនិងម្នាក់ទៀតត្រូវបានកងទ័ពខ្មែរក្រហមបាញ់សម្លាប់ខណៈពេលកំពុងពួនលាក់ខ្លួននៅរូងថ្ម ។ ខូ អ៊ុន ដែលជាអតីតកងទ័ពខ្មែរក្រហមនៃកងវរសេនាតូច ៤១០ នៃកងពលទី៣នេះបានមានប្រសាសន៍ថាបន្ទាប់ពីមានការប៉ះទង្គិចនៅកោះតាង គឺខាងទីបញ្ជាការនៅកំពង់សោមមិនអាចទាក់ទងមកកងទ័ពដែលឈរជើងនៅលើកោះតាងបានទេគឺដាច់វិទ្យុទាក់ទងទាំងអស់ហើយទីបញ្ជាការធំនៅ កំពង់សោមបានបញ្ជាឲ្យឈ្មោះសំណាងដែលជាបញ្ជាការកងវរសេនាតូច៤១០រួមជាមួយឈ្មោះ ម៉េន, ម៉ន, ហ៊ិត ដែលជាគណៈបញ្ជាការគ៨ និងគ១០ បើកកប៉ាលប៉េ-សេ-អេហ្វមួយគ្រឿងចេញពីមូលដ្ឋានកងទ័ពនៅរាមមក ស៊ើបមើលស្ថានភាពនៅកោះតាងៗ ចំណែកវិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកក៏បានប្រកាសថាទាហានសហរដ្ឋអាមេរិកបានដកទៅវិញនៅម៉ោងប្រមាណ៩យប់ថ្ងៃទី១៥ម្ល៉េះ ប៉ុន្តែខាងខ្មែរក្រហមនៅមិនទាន់ជឿលើព័ត៌មាននេះទេៗ បន្ទាប់ពីមេបញ្ជាការកងវរសេនាតូច៤១០, គ៨ និងគ១០ បានទៅដល់កោះតាង និងរាយការ

ណ៍មកខាងកំពង់សោមវិញថាទាហាន សហរដ្ឋអាមេរិកបានដកទៅវិញអស់ពិតមែនៗ ស្អែកឡើងខាងបញ្ជាការដ្ឋានកងពលនៅកំពង់សោមបានបញ្ជាឲ្យ អ៊ុន និងកងទ័ពដ៏ទៃទៀតធ្វើដំណើរមកកោះតាងដែរៗ នៅកោះតាង អ៊ុន បានចូលរួមជាមួយកងទ័ពដ៏ទៃទៀតដើរបោសសម្អាត និងប្រមូលសាកសពយកទៅកប់នៅតាមព្រៃក្បែរឆ្នេរៗ អ៊ុន បានឲ្យដឹងថាគាត់ និងកងទ័ពផ្សេងៗទៀតបានប្រមូលកប់សាកសពកងទ័ពខ្មែរក្រហមចំនួន៧នាក់ និងទាហានសហរដ្ឋអាមេរិកដែលមានរុំថង់កៅស៊ូចំនួន២នាក់ៗ ប្រេះ ហ៊ិន បានបន្ថែមទៀតថាពេលនោះកងទ័ពខ្មែរក្រហមមិនបានគិតគូរវែង ឆ្ងាយឡើយ កងទ័ពខ្មែរក្រហមបានរុញសាកសព ទាហានអាមេរិកាំងបណ្តែតទឹកចោលគឺកងទ័ពទាំងនោះ ធ្វើយ៉ាងណាឲ្យតែសាកសពបានចេញផុតកោះតែប៉ុណ្ណោះៗ

## ២- ការខូចខាតផ្នែកសម្ភារ

ខាងភាគីខ្មែរក្រហមក៏មានការខូចខាតសម្ភារមួយចំនួនដូចជាកប៉ាល់ប៉េ-សេ-អេហ្វទូកនេសាទថៃ និងទូកជនភៀសខ្លួនវៀតណាមដែលកងទ័ពខ្មែរក្រហមបានចាប់មុនការប៉ះទង្គិចនេះៗ ចំណែកមូលដ្ឋានកងទ័ពខ្មែរក្រហមនៅលើកោះតាង មូលដ្ឋានកងទ័ពខ្មែរក្រហមនៅរាមរោងចក្រប្រេងកាតនៅកំពង់សោមកំពង់ផែ កំពង់សោមត្រូវខូចខាតយ៉ាងធ្ងន់ធ្ងរៗ ភាគីខាងទាហានសហរដ្ឋអាមេរិកគឺមានខូចខាតឧទ្ធម្ភាគចក្រចំនួន៣គ្រឿង (ឧទ្ធម្ភាគចក្រមួយគ្រឿងត្រូវបានកងទ័ពខ្មែរក្រហមបាញ់ឆេះធ្លាក់នៅលើកោះតាងមួយគ្រឿង ត្រូវកងទ័ពខ្មែរក្រហមបាញ់ដាច់កន្ទុយធ្លាក់ នៅលើកោះតាងដែរ ចំណែកមួយគ្រឿងទៀត ក៏ត្រូវកងទ័ពខ្មែរក្រហមបាញ់ចំនិងបានធ្លាក់នៅក្នុងទឹកសមុទ្រ ស្ថិតនៅក្បែរកោះព្រីងរបស់កម្ពុជា) និងសម្ភារផ្សេងៗទៀតៗ

ប្រេះ ហ៊ិន និយាយថាខ្លួនបានមើលឃើញឧទ្ធម្ភាគចក្រមួយគ្រឿង ត្រូវបានកងទ័ពខ្មែរក្រហមបាញ់ឆេះសន្ធោសន្ធៅនិងបានចុចផុងសាំងនៅខាងក្រោមឧទ្ធម្ភាគចក្រចោល បន្ទាប់មកឧទ្ធម្ភាគចក្រនោះ ក៏បានធ្លាក់នៅក្នុងទឹកនៅក្បែរកោះព្រីងៗ ឧទ្ធម្ភាគចក្រមួយគ្រឿងទៀតនៅសំកាំងលើកោះតាងដើម្បីឲ្យទាហានរបស់ខ្លួនទម្លាក់ជណ្តើរចុះចំពីលើលេណដ្ឋានកងទ័ពខ្មែរក្រហម និងត្រូវកងទ័ពខ្មែរក្រហមបាញ់ត្រូវហើយឆេះធ្លាក់ៗចំណែកឧទ្ធម្ភាគចក្រទី៣ ក៏ត្រូវបានកងទ័ពខ្មែរក្រហមបាញ់ដាច់កន្ទុយធ្លាក់ នៅលើកោះនេះដែរៗ ម៉ៅ វ៉ាន់ក៏បានឲ្យដឹងថាខាងខ្មែរក្រហមបាញ់ត្រូវ និងធ្លាក់ឧទ្ធម្ភាគចក្រចំនួនគ្រឿងមានមួយគ្រឿងត្រូវដាច់កន្ទុយៗមានទាហានអាមេរិកាំងមួយចំនួនបានស្លាប់នៅលើឧទ្ធម្ភាគចក្រ, ខ្លះនៅក្បែរឧទ្ធម្ភាគចក្រ, ខ្លះស្លាប់នៅលើកោះនិងខ្លះទៀតស្លាប់នៅក្នុងទឹកៗ ប៉ាក់សុខក៏ឲ្យដឹងថានៅ កន្លែងខ្ញុំមានទាហានអាមេរិកាំងប្រមាណជាង១០នាក់ ខ្លះស្លាប់នៅក្នុងឧទ្ធម្ភាគចក្រដែលធ្លាក់ និងទាហានខ្លះទៀតបានហែលទឹកសមុទ្រសំដៅទៅអូមបររបស់ពួកគេៗ

## ៣-ការសម្លាប់ឈ្លើយសឹក

បន្ទាប់ពីការប៉ះទង្គិចបានបញ្ចប់ ទាហានសហរដ្ឋអាមេរិកបានដកចេញពីកោះតាងភ្លាមៗនៅព្រលប់ថ្ងៃទី១៥ ខែឧសភាឆ្នាំ១៩៧៥ដោយបានបន្សល់ទុកទាហានរបស់ខ្លួននៅមានជីវិតចំនួន៣រូបនៅលើកោះតាងៗ ប៉ាក់ សុខ ដែលបានចូលរួមប្រយុទ្ធនៅលើកោះតាងបានបន្ថែមថា មានទាហានអាមេរិកាំងម្នាក់រត់ឡើងឧទ្ធម្ភាគចក្រមិនទាន់ហើយក៏បានរត់ទៅពួននៅរូងថ្មមួយកន្លែងៗ ប្រហែលជាមួយសប្តាហ៍កន្លងទៅ សុខ បានដើរទៅមើលតាមរូងថ្មក៏ប្រទះឃើញទាហាននោះក៏ភ្ញាក់ និងបានយកកាំណុងកាំភ្លើងទៅបុកនឹងទ្រូងនិងបាញ់ទាហាននោះស្លាប់ និងបានដើររកកាំភ្លើងជុំវិញសាកសពទាហាននោះ ប៉ុន្តែរកមិនឃើញឡើយៗ មុនពេលជួបនិងបាញ់សម្លាប់ទាហានអាមេរិកាំងនេះ សុខ ក៏ធ្លាប់បានដឹងថាមានទាហានអាមេរិកាំងនៅរស់លើកោះ និងបានពួនស្ទាក់តដៃជាមួយកងទ័ពខ្មែរក្រហមទៀតដងៗ

ប្រេះ ហ៊ិន បានបន្ថែមថាមានកងទ័ពខ្មែរក្រហមម្នាក់ឈ្មោះវ៉ន ធ្លាប់ត្រូវបានទាហានអាមេរិកាំងបាញ់បាក់ភ្លៅពេលដើរល្បាតនៅលើកោះបានឃើញទាហានអាមេរិកម្នាក់

កំពុងឆ្លងកាត់ទឹកសមុទ្រ នៅជិតផ្ទាំងថ្មមួយកន្លែងនៅពេលថ្ងៃត្រង់ វ៉ន ក៏បានបោះគ្រាប់បែកទៅលើទាហានមេរិកាំងនោះស្លាប់ទៅ វ៉ន មិនហ៊ានចូលទៅជិតទាហានព្រោះខ្លាចក្រែងទាហាននោះមានកាំភ្លើង។

ខូ អ៊ុន អតីតកងទ័ពខ្មែរក្រហមដែលបានមកប្រមូលសាកសព បន្ទាប់ពីការប៉ះទង្គិចនៅលើកោះតាងបានឲ្យដឹងថា គាត់បានឃើញទាហានអាមេរិកាំងម្នាក់បានដេកលើផ្ទាំងថ្មដកដង្ហើមផេតផត១ត្រូវរបួសផងអត់មានអ្វីហូបផង គឺមិនមានកងទ័ពខ្មែរក្រហមណាហ៊ានទៅជិត និងជួយសង្គ្រោះឡើយពីព្រោះខ្លាចទាហាននោះមានកាំភ្លើងបាញ់តដៃក្រោយមកទាហាអាមេរិកកាំងនោះក៏បានស្លាប់ អ៊ុន និងកងទ័ពខ្មែរក្រហមបានយកទាហាននោះទៅកប់នៅព្រៃក្បែរមាត់សមុទ្រនោះ។អតីតកងទ័ពខ្មែរក្រហមដែលធ្លាប់ចូលរួម ប្រយុទ្ធនៅលើកោះតាងបានឲ្យដឹងបន្ថែមទៀតថា ទាហានសហរដ្ឋអាមេរិកមានឧត្តមភាពខ្លាំងក្លាមានបច្ចេកទេសខ្ពស់ និងមានសម្ភារទំនើបៗ។ ដូច្នេះកងទ័ពខ្មែរក្រហមមិនហ៊ានចូលជិតចាប់ទាហាននោះទាំងរស់ក៏ សម្រេចចិត្តបាញ់និងបោកគ្រាប់បែកសម្លាប់តែម្តង។ ម្យ៉ាងទៀតកងទ័ពខ្មែរក្រហមបារម្ភថា បើចាប់ទាំង រស់ទៅខ្លាចដូចករណីនាវិកម្នាក់ដែលបានលាក់ខ្លួន នៅក្នុងកប៉ាល់ម៉ាយ៉ាហ្គេសនិងបានទាក់ទងទៅខាងសហរដ្ឋអាមេរិក ដែលនាំឲ្យសហរដ្ឋអាមេរិកបញ្ជូនទាហានមកទម្លាក់គ្រាប់ បែកនិងវាយប្រយុទ្ធនៅលើកោះតាងម្តងទៀត។

## IV) *សេចក្តីសន្និដ្ឋាន*

ការប៉ះទង្គិចរវាងកងទ័ពខ្មែរក្រហម និងទាហានសហរដ្ឋអាមេរិកនៅលើកោះតាងរបស់ប្រទេសកម្ពុជាក្នុងថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៥ គឺជាជម្លោះប្រដាប់អាវុធទ្រង់ទ្រាយធំលើកទី១ បន្ទាប់ខ្មែរក្រហមបានឡើងកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយក៏ជាការធ្វើសង្គ្រាមលើកចុងក្រោយ របស់ទាហានសហរដ្ឋអាមេរិកនៅឥណ្ឌូចិន បន្ទាប់ពីសហរដ្ឋអាមេរិកបានដកខ្លួនចេញពីសង្គ្រាមវៀតណាមនៅក្នុងឆ្នាំ១៩៧៣។

ឧបទ្ទវហេតុកប៉ាល់ម៉ាយ៉ា ហ្គេសនេះគឺជាសង្គ្រាមមួយដែលមិនគួរឲ្យកើតមាន។ សង្គ្រាមនេះបង្កឡើងនៅពេលដែលកងទ័ពខ្មែរក្រហម បានចេញទៅចាប់កប៉ាល់ម៉ាយ៉ាហ្គេស ដែលជាកប៉ាល់ដឹកទំនិញរបស់សហរដ្ឋអាមេរិកកំពុងធ្វើដំណើរនៅក្នុងឈូងសមុទ្រថៃឡង់ដ៍។ សហរដ្ឋអាមេរិកបានបញ្ជូនទាហានរបស់ខ្លួនជាមួយយន្តហោះទម្លាក់គ្រាប់ជាច្រើន គ្រឿងមកទម្លាក់និងវាយនៅកោះតាងក្នុងគោលបំណងរំដោះក្រុមនាវិក និងកប៉ាល់ម៉ាយ៉ាហ្គេសត្រឡប់ទៅវិញ។មេដឹកនាំខ្មែរក្រហម បានថ្លែងថាថ្នាក់ដឹកនាំនៅភ្នំពេញមិនបានដឹង អំពីការចាប់កប៉ាល់ម៉ាយ៉ាហ្គេសនេះភ្លាមៗទេរហូតដល់មាន វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកផ្សាយអំពីការចាប់នេះទើបបានដឹង និងបញ្ជាឲ្យកងទ័ពជើងទឹកនៅក្រុងកំពង់សោមដោះលែងក្រុមនាវិក និងកប៉ាល់ម៉ាយ៉ាហ្គេសឲ្យត្រឡប់ទៅប្រទេសថៃវិញជាបន្ទាន់ គឺតាំងពីយប់ថ្ងៃទី១៤ខែឧសភាឆ្នាំ១៩៧៥ ប៉ុន្តែសហរដ្ឋអាមេរិកនៅតែបញ្ជូនទាហាននិង យន្តហោះមកទម្លាក់ និងវាយនៅកោះតាងនៅព្រឹកថ្ងៃទី១៥ខែឧសភា ឆ្នាំ១៩៧៥ដដែល។

ចំណែកអតីតកងទ័ពជើងទឹករបស់ខ្មែរក្រហមក៏បានទទួលស្គាល់ថាខ្លួនមិនមានជំនាញខាងជើងទឹក និងបានយល់ដឹងអំពីច្បាប់អន្តរជាតិឡើយប៉ុន្តែកងទ័ពទាំងនោះបែរជាត្រូវបានចាត់តាំងឲ្យទៅឈរជើងប្រចាំការនៅតាមកោះ និងដែនសមុទ្រនៃប្រទេសកម្ពុជាបន្ទាប់ពីខ្មែរក្រហម បានកាន់កាប់ទីក្រុងភ្នំពេញថ្ងៃទី១៧ខែមេសា ឆ្នាំ១៩៧៥ទៅវិញ។អតីតកងទ័ពខ្មែរក្រហម ក៏បានទទួលស្គាល់ថាការចាប់កប៉ាលម៉ាយ៉ាហ្គេសនេះគឺខុសនឹងច្បាប់អន្តរជាតិ និងបានប្រៀបធៀបកងទ័ពខ្មែរក្រហមនៅពេលនោះទៅនឹងកងទ័ពព្រៃ ដែលមិនបានចេះច្បាប់អ្វីទាំងអស់។កងទ័ពខ្មែរក្រហមមួយចំនួនថែមទាំងមិនដែលបានស្គាល់សមុទ្រ នៅពេលដែលមេបញ្ជាការរបស់ខ្លួនចាត់តាំងឲ្យ ធ្វើដំណើរតាមកាណូតទៅឈរជើងនៅលើកោះនោះគឺបានពុលរលក និងក្អួតចង្អោរថែមទៀតផង។

**ឡុង ដានី**

# ឯក សុផល អតីតគណៈតំបន់៣៧ ស្រុកស្រែអំបិល ខេត្តកោះកុង

ឯក សុផល អាយុ៧៣ឆ្នាំគឺ ជាកូនទី៦ក្នុងចំណោម បងប្អូនប្រុសស្រី៧ នាក់នៃគ្រួសារមួយដែលមានស្រុកកំណើតនៅក្នុងភូមិតាកែវ ឃុំពាវ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ សុផលមានប្រពន្ធឈ្មោះ សុខ វ៉េន អាយុ៥០ឆ្នាំ ព្រមទាំងមានកូន៥នាក់។ សព្វថ្ងៃសុផល មានទីលំនៅក្នុងឃុំអន្លង់រាបស្រុកវាលវែងខេត្តពោធិ៍សាត់។ សុផល បានចែករំលែកពីបទពិសោធន៍ផ្ទាល់ខ្លួន ចាប់តាំងពីមុនពេលដែលខ្មែរក្រហមគ្រប់គ្រងប្រទេស និងរហូតដល់ស្រុកទេសមានសុខសន្តិភាព ដូចតទៅ ៖

កាលពីកុមារភាព ខ្ញុំរៀនដល់ថ្នាក់ទី៦សង្គមចាស់ នៅសាលាពាម ក្នុងខេត្តកំពង់ឆ្នាំង។ ក្រោយមក ខ្ញុំមានគំនិតថាចង់បួសធ្វើជាសង្ឃដើម្បីរៀនសូត្រពីផ្លូវធម៌ និងផ្លូវលោក។ពេលនោះខ្ញុំក៏បានសម្រេចចិត្តបួសធ្វើជាសង្ឃ អស់រយៈពេលបីព្រះវស្សានៅវត្តទេពឧត្តម ស្ថិតនៅក្បែរស្រុកខដុគ្គ។ ក្នុងពេលនោះដែរខ្ញុំតែងតែស្រមៃថាខ្ញុំនឹងព្យាយាមរៀនសូត្រឲ្យចប់ថ្នាក់ ប៉ុន្តែក្តីស្រមៃនេះត្រូវបានរលាយបាត់អស់ បន្ទាប់ពីខ្ញុំត្រូវបានអូសទាញពីសំណាក់មិត្តភក្តិ ឲ្យចូលរួមតស៊ូនយោបាយ។ មិនតែប៉ុណ្ណោះ ខ្ញុំក៏បានឮសម្តេចព្រះនរោត្តមសីហនុប្រកាស ប្រាប់កូនចៅជនរួមជាតិទាំងអស់ឲ្យរត់ចូលព្រៃម៉ាគីក្នុងឆ្នាំ១៩៧០។ ទាំងនេះគឺជាការជំរុញទឹកចិត្តខ្ញុំក្នុងការលាចាកសិក្ខាបទ។ ក្រោយមក ខ្ញុំបានរត់ចូលព្រៃជាមួយកងកម្លាំងខ្មែរក្រហម នៅតាមជួរភ្នំជាច្រើនដូចជាភ្នំឱរ៉ាល់ ភ្នំភ្លួល់ ភ្នំព្រះ និងខាងត្បូងភ្នំពីសដែលមានទីតាំងស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង ដែលជាដែនជម្រករបស់អ្នកតស៊ូនៃចលនាខ្មែរក្រហម។កាលនោះមានហ៊ូ នឹម, ហ៊ូ យន់ និងខៀវ សំផន បានចុះមកអប់រំប្រជាជនផ្ទាល់នៅ តាមភូមិឃុំរបស់ខ្ញុំ។រហូតដល់ឆ្នាំ១៩៧២ ខ្ញុំបានធ្វើជាអ្នកការពារសុវត្ថិភាពឲ្យហ៊ូយន់។ នៅអំឡុងពេលនោះខ្ញុំ និងកងវរសេនាតូច



យោធាខ្មែរក្រហមប្រចាំការនៅដែនសមុទ្រ

របស់ខ្ញុំ និងកងកម្លាំងខ្មែរក្រហមដទៃទៀតចាប់ផ្ដើមវាយតាមប៉ុស្តិ៍យាមរបស់ទាហាន លន់ នល់ នីមួយៗនៅក្នុងខេត្តកំពង់ឆ្នាំងៗប៉ុន្តែមុននឹងចាប់ផ្ដើមធ្វើសកម្មភាពទាំងនេះខ្ញុំ និងកងកម្លាំងផ្សេងទៀត ទទួលបានការបង្ហាត់បង្រៀនពីយុទ្ធសាស្ត្រធ្វើសង្គ្រាមពីថ្នាក់លើដូចជា របៀបវាយពិសេសវាយកាំភ្លើងធំវាយបង្ក្រប់ និងវាយរបៀបចលនាៗមិនតែប៉ុណ្ណោះខ្ញុំក៏ទទួលបានការបំពាក់បំប៉នខាងផ្នែកនយោបាយ ដោយពាក្យនេះ គឺសំដៅទៅលើភាពអង់អាចក្លាហានហ៊ានប្រយុទ្ធជាមួយសត្រូវចំពោះមុខៗ ចំពោះរបៀបវាយពិសេសនៃចលនាខ្មែរក្រហមគឺសំដៅទៅលើ «ប្រសិនបើយើងចង់វាយខ្មាំងនៅទីតាំងណាមួយ គឺយើងត្រូវពិនិត្យមើលផ្ទាល់អំពីសកម្មភាពរបស់ខ្មាំង ថាតើខ្មាំងមានសកម្មភាពយ៉ាងដូចម្ដេចមានកម្លាំងប៉ុន្មាននាក់រួមទាំងខាងក្នុង និងក្រៅបន្ទាយៗ នៅពេលដែលយើងទទួលបានព័ត៌មានជាក់លាក់ណាមួយ គឺយើងនឹងចាប់ផ្ដើមធ្វើសកម្មភាពភ្លាមៗ។

ឧទាហរណ៍ ៖ ប្រសិនបើខ្មាំងមានកម្លាំង១០០នាក់គឺយើងនឹងចំណាយកម្លាំងត្រឹមតែ១០នាក់ប៉ុណ្ណោះ ដើម្បីវាយខ្មាំងៗតើកម្លាំង១០នាក់អាចវាយខ្មាំង១០០នាក់បានយ៉ាងដូចម្ដេច? ហេតុច្នេះ ទើបទាមទារឲ្យយើងចុះស៊ើបការណ៍អំពីសកម្មភាពរបស់ខ្មាំង ដើម្បីត្រៀមអាវុធធ្វើសកម្មភាពៗ ចំពោះសកម្មភាពកន្លងទៅ ដែលកងពិសេសធ្លាប់បានធ្វើគឺយើងបានត្រៀមកាំភ្លើង៨០និង៨១មីលីម៉ែត្រខ្ចូសេត (១២) និងកាំភ្លើងអាកន្ធ្វង់ចុះជាដើមៗ

បន្ទាប់ពីត្រៀមអាវុធរួចហើយកងពិសេសចាប់ផ្ដើមក្រាបលូនដើម្បីចូលទៅដល់បន្ទាយខ្មាំង និងធ្វើសកម្មភាពដូចជាយកដីខ្សាច់ញាត់ចូលកាំភ្លើងខ្មាំងកុំឲ្យប្រើប្រាស់បាន» ។តមកទៀត ចលនាខ្មែរក្រហមចាប់ផ្ដើមរៀបចំជារចនាសម្ព័ន្ធជាច្រើនកងពលទៅតាមភូមិភាគនីមួយៗ។ បន្ទាប់ពីរៀបចំកងពលរួចមក កងកម្លាំងខ្មែរក្រហមចាប់ផ្ដើមវាយជាទ្រង់ទ្រាយធំទៅតាមការចាត់តាំងរបស់ថ្នាក់លើៗ រីឯខ្ញុំមានភារកិច្ចវាយតាមមុខព្រួញខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ និងឆ្ពោះទៅទីក្រុងភ្នំពេញៗ កងកម្លាំងខ្មែរក្រហមបានខិតខំវាយយ៉ាងស្វិតស្វាញទៅលើក្រុមទាហាន លន់ នល់ ដោយមិនបន្ធូរបន្ថយឡើយៗ ចំពោះយុទ្ធសាស្ត្រធ្វើសង្គ្រាមរវាងយោធាខ្មែរក្រហម និងទាហាន លន់ នល់ គឺមានយុទ្ធសាស្ត្រវៀងៗខ្លួនប៉ុន្តែការធ្វើសង្គ្រាម គឺពឹងផ្អែកទៅលើស្មារតីសហការប្មុនយោបាយជាមូលដ្ឋាន និងគោលជំហរសតិអារម្មណ៍គឺជាកត្តាដ៏សំខាន់ៗ កត្តាទាំងនេះ គឺយោធាខ្មែរក្រហមត្រូវបានបំពាក់បំប៉នបានយ៉ាងល្អៗ រីឯខ្ញុំតែងតែចូលរួមធ្វើសកម្មភាពជាមួយយោធាខ្មែរក្រហមថ្នាក់ក្រោមជាប់ជានិច្ច ដើម្បីរៀបចំយុទ្ធសាស្ត្រនិងចាត់ចែងកងកម្លាំងក្នុងការវាយកម្ទាត់ខ្មាំងៗ

រហូតដល់ខែមីនា ឆ្នាំ១៩៧៥ ខ្ញុំបានចូលមកក្នុងកងពលដែលឈរជើងនៅលង្វែក ហើយយោធាខ្មែរក្រហមនៅក្នុងកងពលនេះបាន ធ្វើការបង្កបង្កើនផលស្រែចម្ការនៅតាមបណ្ដាខេត្តក្បែរៗនោះៗ កាលនោះក្រុមយោធាខ្មែរក្រហមចាប់ផ្ដើមបង្កើតជាកងពលថ្មីមួយទៀតគឺកងពលទ័ពអាកាសដោយមានតាម៉េត គឺជាគណៈកងពលៗ រីឯខ្ញុំគឺជាគណៈតំបន់៣៧(ស្រែអំបិល)នៅកងពលទី១របស់ភូមិភាគបស្ចិមៗ ក្រោយមក ខ្ញុំបានផ្លាស់ទីទៅឈរជើងនៅកោះកុងនិងកោះខ្យងៗខណៈនោះដែរមានកងពល១៦៤របស់ភូមិភាគបស្ចិមដែលឈរជើងនៅខាងកំពង់សោម បានធ្វើការវាយចូលកោះត្រល់ៗ

ប៉ុន្តែការវាយចូលនេះ គឺមិនបានជោគជ័យឡើយដោយកងកម្លាំងខ្មែរក្រហមនៃកងពល១៦៤ នេះត្រូវបានទាហានវៀតណាមវាយបង្ក្រាប ព្រមទាំងហ៊ុំព័ទ្ធចាប់បានទាំងអស់ៗ សម្រាប់ខ្ញុំ ខ្ញុំគិតថា ចំពោះបញ្ហានេះ គឺដោយសារតែវៀតណាមមានគម្រោងការរួចជាស្រេច ក្នុងការហ៊ុំព័ទ្ធចាប់កងកម្លាំងកងពល១៦៤ នៃយោធាខ្មែរក្រហមៗ នៅខែមេសា ឆ្នាំ១៩៧៥ ក្រុមយោធាខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងទៅលើរបប លន់ នល់ៗ ពេលនោះ ខ្មែរក្រហមចាប់ផ្ដើមជម្លៀសប្រជាជនចេញពីទីក្រុង ហើយបានបំបិទសិទ្ធិ

សេរីភាពគំរាមកំហែង និងបង្ខំឲ្យប្រជាជនទៅធ្វើការងារបង្កបង្កើនផលយ៉ាងធ្ងន់ធ្ងរនៅតាមទីជនបទនានា។ ខ្មែរក្រហមបានរៀបចំស្រុកទេសឲ្យទៅជាប្រទេសឯករាជ្យមួយ ដោយផ្តោតសំខាន់ទៅលើការបង្កបង្កើនផលផ្នែកកសិកម្ម។ សូម្បីតែយោធាខ្មែរក្រហម ក៏ចូលរួមបង្កបង្កើនផលដូចជាប្រជាជនដទៃទៀតដែរ។ កាលនោះខ្ញុំតែងតែជួបតាម៉ុក(លេខាភូមិភាគនិរតីជាញឹកញាប់នៅមន្ទីរភូមិភាគ ដែលមានទីតាំងនៅច្បារមន។តាម៉ុកបានដើរត្រួតពិនិត្យ នៅតាមកងពលផ្សេងៗ ដោយមិនសូវមានពេលវេលានៅមួយកន្លែងឡើយ។ តាម៉ុកតែងតែចុះធ្វើការជាមួយប្រជាកសិករជាប់ជាហូរហែរ។

តាម៉ុក បានណែនាំទៅកាន់ប្រជាកសិករថា កុំធ្វើស្រែប្រវាសនឹងមេឃគឺមានន័យថា យើងត្រូវមានប្រព័ន្ធធារាសាស្ត្រដើម្បីផ្គត់ផ្គង់ដំណាំស្រូវ។ នៅពេលដែលយើងមានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ ពេលនោះហើយគឺជាពេលដែលយើងអាចធ្វើស្រែពីរទៅបីដងក្នុងមួយឆ្នាំៗ។ កាលនោះទោះបីខ្ញុំជាកងទ័ពក៏ដោយ ក៏ខ្ញុំនៅមានតួនាទីមើលប្រជាជនព្រោះកម្មាភិបាលមួយចំនួនត្រូវបានចាប់ជាបន្តបន្ទាប់ដោយភាពមិនទុកចិត្តគ្នា។

មិនយូរប៉ុន្មាន ខ្ញុំត្រូវបានថ្នាក់លើចោទ ប្រកាន់ថាជាខ្មែររយៈ កា.សេ.បេ របស់សូវៀត។ ខ្ញុំត្រូវស្ថិតនៅក្រោមការតាមដានអស់មួយរយៈ ហើយខ្ញុំនឹកគិតថាចង់សម្លាប់ខ្លួនដែរ ប៉ុន្តែក៏ផ្លាស់ប្តូរគំនិតនេះទៅវិញ។ មួយរយៈ ក្រោយមកខ្ញុំក៏បានរួចផុតពីការតាមដានរបស់ថ្នាក់លើហើយក៏ទទួលបានតួនាទីដូចកាលពីមុន។ រហូតដល់ឆ្នាំ១៩៧៩ តាម៉ុក បានចាត់តាំងខ្ញុំឲ្យដឹកនាំកងទ័ព១.០០០នាក់មកឈរជើងនៅខេត្តកំពង់ឆ្នាំងដើម្បីវាយតស៊ូជាមួយកងទ័ពវៀតណាម។កងទ័ពរបស់ខ្ញុំបានវាយតាមតំបន់មួយចំនួន ដូចជា ស្រុកមុខកំពូល ព្រៃគៀល ព្រៃប្រស់ និងភ្នំដិលជាដើម។ ទោះជាយ៉ាងណាក៏ដោយកងទ័ពខ្មែរក្រហមក៏មិនអាចទប់ស្កាត់ជាប់ ចំពោះការវាយសម្រុកចូលយ៉ាងខ្លាំងក្លា នៃចលនាកងទ័ពវៀតណាមដែរ។ដល់ឆ្នាំ១៩៨២ តាម៉ុកបានចាត់តាំងខ្ញុំ និងកងកម្លាំងដទៃទៀត ទៅប្រមូលផ្តុំគ្នានៅស្រុកអន្លង់វែងខេត្តឧត្តរមានជ័យ។ពេលនោះខ្ញុំបានដើរធ្វើការនៅ តាមតំបន់ជាច្រើនដូចជាព្រះវិហារភ្នំម្រិចកំពង់ធំស្រុកពួកនិងស្រុកក្រឡាញ់ជាដើម។ ក្នុងឆ្នាំនោះដែរ ខ្ញុំក៏បានជួបនារីម្នាក់នៅស្រុកអន្លង់វែងនេះហើយខ្ញុំបានស្នើសុំឲ្យអង្គភាព រៀបចំផ្សំផ្គុំឲ្យយើងទាំងពីររៀបការជាមួយគ្នាតែម្តង។ បន្ទាប់ពីរៀបការរួចមកយើងទាំងពីរមិនសូវមានពេលរួមរស់ជាមួយគ្នានោះទេ ដោយខ្ញុំមានភារកិច្ចចុះធ្វើការនៅតាមបណ្តាស្រុកមួយចំនួន ដែលមានរយៈពេលប្រាំមួយខែទៅមួយឆ្នាំ ទើបយើងទាំងពីរបានជួបគ្នាម្តង។ទោះជាយ៉ាងនេះក្តី វាគឺជារឿងធម្មតាទៅហើយសម្រាប់ជីវិតកងទ័ពដូចជារូបខ្ញុំ។ រហូតដល់ឆ្នាំ១៩៨៥ ខ្ញុំនិង កងកម្លាំង១០០នាក់ផ្សេងទៀតបានផ្លាស់មកឈរជើងនៅខេត្តកំពង់ឆ្នាំងវិញ ដោយធ្វើដំណើរកាត់តាមទន្លេសាប។ មានកងទ័ពមួយចំនួនហែលកាត់ទន្លេសាបរីឯមួយចំនួនទៀតក៏បានធ្វើដំណើរដោយជិះទូក ដោយមានចម្ងាយប្រហែលជាបីគីឡូម៉ែត្រ។ រឿងរ៉ាវទាំងនេះ ខ្ញុំបានឆ្លងកាត់នៅក្នុងមួយជីវិតរបស់ខ្ញុំ។

ក្នុងការធ្វើដំណើរនេះប្រសិនបើ យើងប្រទះឃើញទូករបស់កងទ័ពវៀតណាម គឺជារឿងល្អខ្លាំងណាស់សម្រាប់កងទ័ពខ្មែរក្រហម ព្រោះយើងនឹងឆក់យកឱកាសនេះដើម្បីវាយដណ្តើមយកទូកសម្រាប់បន្តដំណើរទៅមុខទៀត។ខ្ញុំបានឈរជើងនៅខេត្តកពង់ឆ្នាំងរហូតដល់ឆ្នាំ១៩៩៦។ បន្ទាប់ពីកងកម្លាំងខ្មែរក្រហមបានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជាអង្គភាពមួយចំនួន ក៏ចាប់ផ្តើមរៀបចំបង្កើតឡើងដែរ ហើយបានប្រគល់តំណែងទៅឲ្យកម្មាភិបាលខ្មែរក្រហមមួយចំនួនគ្រប់គ្រង រីឯខ្ញុំបានទទួលតួនាទីជាប្រធានកងពលដដែល។ មិនយូរប៉ុន្មានខ្ញុំបានសម្រេចចិត្តលាលែងពីតំណែងនេះ ហើយផ្លាស់មកធ្វើការនៅក្នុងមន្ទីរអភិរក្សបរិស្ថាននៅក្នុងខេត្តពោធិ៍សាត់វិញ។ រហូតដល់ឆ្នាំ២០០០ខ្ញុំបានផ្លាស់មកធ្វើជាអភិបាលរងស្រុកវាលវែងខេត្តពោធិ៍សាត់។

**ហួ ថុនា**

# ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់គរុសិស្សនៅខេត្តបាត់ដំបង

មជ្ឈមណ្ឌលឯកសារភូមិភាគខេត្តព្រៃវែងនៃមជ្ឈមណ្ឌលឯកសារកម្ពុ ជាបានសហការជាមួយក្រសួងអប់រំយុវជននិងកីឡា បានបង្កើតសិក្ខាសាលាមួយស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្នុងរយៈពេលបីថ្ងៃគិតចាប់ពីថ្ងៃទី៩-១១ ខែកក្កដា ឆ្នាំ២០១៩ ដែលមានទីតាំងស្ថិតក្នុងវិទ្យាស្ថានគរុកោសល្យភូមិភាគបាត់ដំបង។

សិក្ខាសាលា នេះបានធ្វើឡើងក្នុងគោលបំណងបួនយ៉ាង១ ) អភិវឌ្ឍចំណេះដឹងរបស់គរុសិស្សពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ២)អភិវឌ្ឍជំនាញគរុកោសល្យរបស់គរុសិស្សពីរបៀបបង្រៀន និងបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) ៣)អភិវឌ្ឍន៍សមត្ថភាពរបស់គរុសិស្សឲ្យចេះប្រើប្រាស់បទពិសោធន៍ របស់សាក្សីក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យសម្រាប់ប្រើប្រាស់ក្នុងការបង្រៀនក្នុងថ្នាក់រៀន ៤)បង្កើនប្រសិទ្ធិភាព និងនិរន្តរភាពនៃកម្មវិធីសិក្សាពីប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យជាផ្លូវការជាមួយ ក្រសួងអប់រំ យុវជន និងកីឡានៅតាមសាលារៀនក្នុងសហគមន៍ៗចំពោះសិក្ខាកាម ដែលចូលរួមក្នុងអង្គសិក្ខាសាលានេះ គឺមានគរុសិស្សឆ្នាំទី១ ជំនាន់ទី២៩ នៃវិទ្យាស្ថានគរុកោសល្យបាត់ដំបង និងនិស្សិតមកពីមហាវិទ្យាល័យសង្គមសាស្ត្រមនុស្សសាស្ត្រ ដែលមានចំនួនសរុប ៨០នាក់ៗ សិក្ខាកាមដែលចូលរួមទាំងនេះ គឺមានរហូតដល់



សិស្សានុសិស្សកំពុងសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

៧/ឯកទេសនៃមុខជំនាញនីមួយៗ ដូចជា ឯកទេសជីវៈផែនដី ឯកទេសបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន ឯកទេសអង់គ្លេស-ខ្មែរ ឯកទេសរូបគីមី ឯកទេសប្រវត្តិភូមិ និងឯកទេសប្រវត្តិសាស្ត្រ។ទោះបីជាគរុសិស្ស ដែលកំពុងតែសិក្សាក្រៅពីឯកទេសប្រវត្តិសាស្ត្រក៏ដោយ ក៏អាចមានឱកាសសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបានដែរ ព្រោះបញ្ហាប្រវត្តិសាស្ត្រដ៏អាស្រូវបែបនេះ មិនមែនចាំបាច់តែសិស្សានុសិស្ស និស្សិត ឬគរុសិស្សដែលកពុងសិក្សាផ្នែកប្រវត្តិសាស្ត្រនោះទេបុន្តែបញ្ហាប្រវត្តិសាស្ត្រនេះ គឺជាបញ្ហារបស់ប្រជាជាតិខ្មែរយើងទាំងមូល ដូច្នេះទាមទារឲ្យប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈធ្វើការសិក្សាស្វែងយល់ អំពីប្រវត្តិសាស្ត្រមួយនេះឲ្យបានច្បាស់ ដើម្បីជៀសវាងកុំឲ្យមានការស្អប់ខ្ពើមរើសអើងរវាងអតីតកម្មាភិបាលខ្មែរក្រហម និងជនរងគ្រោះ។ មិនតែប៉ុណ្ណោះនៅពេលដែលយើងយល់កាន់តែស៊ីជម្រៅអំពីប្រវត្តិនៃអំពើប្រល័យពូជសាសន៍ខ្មែរក្រហម ពេលនោះហើយគឺជាពេលដែលយើងស្គាល់ខ្លួនឯងដែរ។

មានពាក្យមួយឃ្លាដែលលោក ឆាំង យុ នាយកម ជ្ឈមណ្ឌលឯកសារកម្ពុជាបានលើកឡើងថា«សង្គមជាតិមួយមិនអាចស្គាល់ខ្លួនឯងបានឡើយ ប្រសិនបើសង្គមជាតិនោះ មិនមានការចងចាំច្បាស់លាស់អំពីប្រវត្តិសាស្ត្ររបស់ខ្លួន»។

ដូចនេះហើយ ទើបមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានខិតខំរិះរក គ្រប់មធ្យោបាយក្នុងការបញ្ជ្រាបនូវ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧ ៥-១៩៧៩) ទៅដល់សិស្សានុសិស្សគរុសិស្សគរុនិស្សិតនិស្សិតនិងគ្រូបង្រៀនជាដើម។ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានបង្កើតនូវកម្មវិធីសិក្សាផ្សេងៗ នៅទូទាំងរាជធានីខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជាដូចជា វេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សា ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)វគ្គបណ្តុះបណ្តាលនិស្សិតស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងវគ្គបណ្តុះជាច្រើនផ្សេងទៀត។

**ហូ ថុនា**



**គរុសិស្សកំពុងពិភាក្សាទៅលើមេរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យ**

# មេភូមិ ស៊ឹម ចំរើន

ស៊ឹម ចំរើនត្រូវបានជ្រើសរើសឲ្យធ្វើជាមេភូមិបន្ទាប់ពីសមាហរណកម្មនៅតំបន់អន្លង់វែង។ អន្លង់វែងគឺអតីតតំបន់តស៊ូដ៏រឹងម៉ាំរបស់កម្លាំងខ្មែរក្រហម នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ៨០និង៩០។ បន្ទាប់ពីអតីតកងកម្លាំងយោធានិងកម្មាភិបាលខ្មែរក្រហមនៅតំបន់អន្លង់វែង បានធ្វើសមាហរណកម្មចុះចូលចូលជាមួយរាជរដ្ឋាភិបាលកម្ពុជានៅដើមឆ្នាំ១៩៩៩ អតីតយោធា និងកម្មាភិបាលមួយចំនួនត្រូវបានបានជ្រើសរើសឲ្យដឹកនាំប្រជាជន ក្នុងតំបន់របស់ខ្លួនរស់នៅរហូតមកដល់សព្វថ្ងៃ។ អតីតយុទ្ធនារីខ្មែរក្រហមស៊ឹម ចំរើន អាយុ៦២ឆ្នាំបានមានប្រសាសន៍ថា«ដោយសារការខិតខំ ប្រឹងប្រែងធ្វើការនិងរៀនសូត្របន្ថែមបន្ទាប់ពីសមារណកម្ម ទើបខ្ញុំត្រូវបានជ្រើសរើសឲ្យធ្វើជាមេភូមិ និងក្រោយមកជា ក្រុមប្រឹក្សាឃុំនិងស្រុកត្រពាំងប្រាសាទ នៃខេត្តឧត្តរមានជ័យ។ ប្រជាជនដែលធ្លាប់បានស្គាល់ខ្ញុំពីមុនមកមិនជឿថាខ្ញុំអាចធ្វើកិច្ចការនេះបានឡើយព្រោះកាលពីសង្គមចាស់ខ្ញុំរៀនបានត្រឹមថ្នាក់ទី១១តែប៉ុណ្ណោះដែលស្មើនឹងថ្នាក់ទី២នៅពេលបច្ចុប្បន្ន»។

***ស៊ឹម ចំរើន ពិពណ៌នាជីវិតរបស់គាត់ដូចខាងក្រោមនេះ ៖***

ខ្ញុំកើតនៅភូមិខ្នារទ្រនង់ឃុំស្វាយរំពារស្រុកបរសេធ ខេត្តកំពង់ស្ពឺ។ ខ្ញុំបានចូលរួមជាមួយចលនាបដិវត្តន៍នៅឆ្នាំ១៩៧៣ បន្ទាប់ពីកងទ័ពរំដោះខ្មែរក្រហមបានចូលមកគ្រប់គ្រងប្រជាជននៅក្នុងភូមិរបស់ខ្ញុំ។ ពេលនោះខ្ញុំបានចូលរៀនជាមួយគ្រូបង្រៀនខ្មែរក្រហម នៅក្រោមម្លប់ឈើម្តងទៀត



*ស៊ឹម ចំរើន នៅផ្ទះស្ថិតនៅក្នុងភូមិព្រៃស្អាក ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ*

ប៉ុន្តែខ្ញុំមិនបានរៀនទៀតទាត់ឡើយ។ ទោះបីយ៉ាងណាក៏ដោយក៏ខ្ញុំខិតខំតស៊ូរៀនរហូតចេះអាន និងសរសេរអក្សរមកដល់សព្វថ្ងៃបន្ទាប់ពីខ្ញុំបានដឹកនាំកងកុមារធ្វើការងារប្រចាំថ្ងៃចប់រួចរាល់។ នៅសម័យនោះទោះបីខ្ញុំនៅវ័យក្មេងក៏ដោយក៏អង្គការចាត់តាំងឲ្យខ្ញុំ ធ្វើការងារលើកទំនប់នៅស្ទឹងកាត់ភ្លុកដូចមនុស្សធំពេញវ័យដែរ។

## ឃ្លាតពីស្រុកកំណើត

បន្ទាប់ពីយោធាខ្មែរក្រហម បានទទួលជ័យជម្នះលើរបប លន់ នល់ បានរយៈពេល៦ខែ គឺនៅតុលា ឆ្នាំ១៩៧៥ អង្គភាពយោធាតំបន់បានបញ្ជូនខ្ញុំ តាមរថភ្លើងមកទីក្រុងភ្នំពេញដោយប្រាប់ថាឲ្យមកធ្វើការនៅរោងចក្រ។ ខ្ញុំបានមកឈប់នៅចំណតរថភ្លើងក្នុងក្រុងភ្នំពេញ ហើយចៃដន្យក៏បានជួបបងស្រីរបស់ខ្ញុំឈ្មោះ ស៊ឹម ឃិន ធ្វើការនៅក្នុងកងនារីភូមិភាគនិរតីដែលត្រូវបានអង្គភាពយោធាបញ្ជូនមកភ្នំពេញដំណាលគ្នាដែរ។ ខ្ញុំបានស្នាក់នៅភ្នំពេញមួយយប់ លុះព្រឹកឡើងអង្គភាពយោធាបានចាត់តាំងខ្ញុំ និងបងស្រីខ្ញុំឲ្យឡើងជិះកប៉ាល់បន្តទៀត ហើយនៅពេលនោះមានយុវជន និងយុវនារីមកពីខេត្តតាកែវ កំពង់ស្ពឺ និងសៀមរាប ប្រមាណជាង១.០០០នាក់ជិះកប៉ាល់ចំនួនពីរគ្រឿងទៀតទៅជាមួយខ្ញុំដែរ។ ខ្ញុំនិងបងស្រីបានទៅដល់ខេត្តក្រចេះ ហើយអង្គភាពយោធាក៏បានបញ្ចូលខ្ញុំទៅក្នុងកងពល៩២០ ក្រោមការគ្រប់គ្រងរបស់តាឃិន និង សយ។ នៅក្នុងអង្គភាព ឃិន និង សយ បានអប់រំមាគ៌ារបស់បក្ស និងអំពីប្រទេសវៀតណាមដែលចង់លេបត្របាក់ទឹកដីខ្មែរ។ ទោះបីយ៉ាងណានៅពេលនោះការហូបចុកនៅក្នុងអង្គភាពយោធារបស់ខ្ញុំមិនបានគ្រប់គ្រាន់ឡើយ គឺខាងចុងភៅបានចែករបបឲ្យខ្ញុំរួមជាមួយសមាជិកទ័ពក្នុងម្នាក់ទទួលបានបាយមួយចានតូច ប៉ុណ្ណោះក្នុងមួយពេលដោយដួសដាក់នៅលើតុរួចជាស្រេច។ ខ្ញុំបានឡើងមកហូបរបបបាយដែលចុងភៅដួសទុកឲ្យ បន្ទាប់ពីខ្ញុំធ្វើការងារស្រែចម្ការរួចរាល់។ ដោយឡែកប្រជាជនរស់នៅក្នុងសហករណ៍ទទួលបានរបបបបរបីវែកក្នុងមួយពេល ដោយក្នុងមួយថ្ងៃទទួលបានបបរបីពេល ចំណែកអ្នកដែលឈឺដើងទៅធ្វើមិន



ផ្លូវទៅប្រកជប់រុនព្រំដែនខ្មែរ-ថៃ ស្ថិតក្នុងភូមិត្រពាំងបី ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

រួចគឺទទួលបានរបបបបរមួយវែក ប៉ុណ្ណោះក្នុងមួយពេល។

### ការងារថ្មីនៅមណ្ឌលគិរី

ខ្ញុំបានជួយធ្វើស្រែប្រជាជននៅខេត្តក្រចេះរយៈពេលបីខែ។ នៅដើមឆ្នាំ១៩៧៦ អង្គភាពយោធាបានយករថយន្តតុងហ្វឹងចំនួន១២ គ្រឿងដែលផលិតនៅប្រទេសចិនមកដឹកខ្ញុំ បងស្រីរបស់ខ្ញុំ ព្រមទាំងយុវជន និងយុវនារីផ្សេងទៀតបន្តទៅខេត្តមណ្ឌលគិរី។ ខ្ញុំមិនដែលស្គាល់ខេត្តមណ្ឌលគិរីពីមុនមកទេ គឺខ្ញុំធ្លាប់តែឮយាយតារបស់ខ្ញុំតំណាលប្រាប់ថាខេត្តនេះ មានជនជាតិព្នងរស់នៅច្រើនហើយមិនពាក់អាវនិងកាចសាហាវ។ ព័ត៌មាននេះបានធ្វើឲ្យខ្ញុំភ័យខ្លាចយ៉ាងខ្លាំងម្យ៉ាងទៀត ខ្ញុំត្រូវឃ្លាតកាន់តែឆ្ងាយពីផ្ទះនិងស្រុកកំណើតថែមទៀតផង។ ប៉ុន្តែពេលខ្ញុំទៅដល់ខេត្តនោះ ខ្ញុំឃើញជនជាតិព្នងរស់នៅនិងស្លៀកពាក់ ដូចប្រជាជនខ្មែរដែរហើយទទួលការអប់រំពីខ្មែរក្រហមដូចប្រជាជនខ្មែរដ៏ទៃទៀត។

ខ្ញុំបានជួយធ្វើស្រែប្រជាជននៅខេត្តក្រចេះរយៈពេលបីខែ។ នៅដើមឆ្នាំ១៩៧៦ អង្គភាពយោធាបានយករថយន្តតុងហ្វឹងចំនួន១២ គ្រឿងដែលផលិតនៅប្រទេសចិនមកដឹកខ្ញុំ បងស្រីរបស់ខ្ញុំ ព្រមទាំងយុវជន និងយុវនារីផ្សេងទៀតបន្តទៅខេត្តមណ្ឌលគិរី។ ខ្ញុំមិនដែលស្គាល់ខេត្តមណ្ឌលគិរីពីមុនមកទេ គឺខ្ញុំធ្លាប់តែឮយាយតារបស់ខ្ញុំតំណាលប្រាប់ថាខេត្តនេះមានជនជាតិព្នងរស់នៅច្រើន ហើយមិនពាក់អាវ និងកាចសាហាវ។ព័ត៌មាននេះបានធ្វើឲ្យខ្ញុំភ័យខ្លាច យ៉ាងខ្លាំងម្យ៉ាងទៀត ខ្ញុំត្រូវឃ្លាតកាន់តែឆ្ងាយពីផ្ទះនិងស្រុកកំណើតថែមទៀតផង។ប៉ុន្តែពេលខ្ញុំទៅដល់ខេត្តនោះខ្ញុំឃើញជនជាតិព្នងរស់នៅ និងស្លៀកពាក់ដូចប្រជាជនខ្មែរដែរហើយទទួលការអប់រំពីខ្មែរក្រហមដូចប្រជាជនខ្មែរដ៏ទៃទៀត។

ខ្ញុំ ត្រូវបានអង្គភាពចាត់តាំងឲ្យទៅនៅស្រុកកោះញែក ចំណែកបងស្រីរបស់ខ្ញុំទៅនៅកោះយើល។ពេលនោះ អង្គភាពយោធាកាត់ឈ្មោះខ្ញុំចេញពីកងពល៩២០ រួចបញ្ចូលទៅនៅយោធាតំបន់មណ្ឌលគិរីក្រោមការ គ្រប់គ្រងរបស់តាហម ដែលបោះទីស្នាក់ការទ័ពនៅតាមមាត់អូរ និងព្រៃនៅក្នុងស្រុកនេះ។ ក្រោយមកអង្គភាពយោធាបានចាត់តាំងខ្ញុំឲ្យលើកភ្លឺស្រែ និងបង្កបង្កើនផលដើម្បីកែប្រែទីតាំងដែលខ្ញុំរស់នៅឲ្យទៅជាភូមិដ្ឋានសម្រាប់ប្រជាជនរស់នៅ។ក្រៅពីធ្វើការងារស្រែចម្ការខ្ញុំក៏ត្រូវត្រៀមការពារព្រំដែនដែរ។

តាំងពីចេញពីផ្ទះ ឪពុកម្ដាយរបស់ខ្ញុំមិនដឹងថាខ្ញុំរស់នៅទីណាឡើយ ហើយខ្ញុំក៏មិនដែលទៅលេងផ្ទះដែរ ទោះបីខែបុណ្យទានព្រោះខ្ញុំនៅគ្រប់គ្រងសមាជិកផង។ ទោះបីយ៉ាងណានៅពេលបុណ្យភ្ជុំបិណ្ឌម្ដងៗយើងបាននាំគ្នាវេចនំរួចហៅចាស់ៗដែលធ្លាប់កាន់សីល និងចេះធម៌អាថ៌មករៀបចំពិធីសែនគម្រប់កិច្ចព្រោះតាំងពីឆ្នាំ១៩៧៣ ខ្មែរក្រហមមិនឲ្យមានលោកសង្ឃទៀតទេ។ បងប្រុសទី១របស់ខ្ញុំម្នាក់បានបួសជាព្រះសង្ឃបានរយៈពេល៨ ឆ្នាំហើយនៅពេលដែលខ្ញុំរស់នៅស្រុកកំណើត ប៉ុន្តែពេលខ្មែរក្រហមចូលមកក្នុងភូមិនៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានឲ្យគាត់សឹកវិញ។ ដោយឡែកនៅពេលបុណ្យចូលឆ្នាំខ្មែរអង្គការបានអនុញ្ញាតឲ្យសមាជិកនៅក្នុងអង្គភាពយោធាឈប់សម្រាករយៈពេលបីថ្ងៃទៅមួយអាទិត្យដូច្នេះយើងបាននាំគ្នាបេះផ្លែឈើព្រៃ និងទៅរកក្ដួចយកមកហូបជុំគ្នារួចហើយវាយស្គរ និងគុងដើម្បីរាំកម្សាន្តនៅមន្ទីរ។

### ការបាត់ខ្លួនថ្នាក់ដឹកនាំ

នៅអំឡុងឆ្នាំ១៩៧៧-១៩៧៨ សភាពការណ៍ចាប់ខ្លួនកម្មាភិបាល និងយោធាបានកើតឡើងជាបន្តបន្ទាប់ដោយអង្គការបានចាប់ខ្លួនប្រធានកងពល៩២០ តាឈិន និងសយរហូតដល់ប្រធានវរសេនាធំដោយចោទថាក្បត់និងមានទំនាក់ទំនងជាមួយវៀតណាមរួច ហើយបញ្ជូនពីខេត្តក្រចេះមកឃុំឃាំងបណ្ដោះអាសន្ននៅតំបន់របស់ខ្ញុំ។ ខ្ញុំបានលួចសាកសួរអ្នកធ្លាប់ធ្វើការជាមួយខ្ញុំនៅខេត្តក្រចេះ ទើបដឹងថា ការចាប់ខ្លួនអ្នកទាំងនោះដោយសារប្រជាជនហូបមិនគ្រប់គ្រាន់។

បន្ទាប់មក អង្គការបានបញ្ជូនតាឈិន និងសយតាមរថយន្តបន្តមកភ្នំពេញទៀត។ចំណែកគណៈតំបន់នៅមណ្ឌលគិរីរួមមានៈតាហម, តាឡាំងនិងតាកំភួនក៏បាត់ខ្លួនជាបន្ត

បន្ទាប់ដែរ ដោយអង្គការហៅទៅប្រជុំដោះស្រាយបាតុភាពការងារនៅភ្នំពេញ។ នៅឆ្នាំ១៩៧៩ ការចាប់ខ្លួនបានស្ងប់ស្ងាត់ហើយប្រធានតំបន់ថ្មីឈ្មោះ តាសារុន ក៏បានឡើងគ្រប់គ្រងជំនួស។នៅអំឡុងពេលនោះសភាពការណ៍ ច្របូកច្របល់ពីសង្គ្រាមជាមួយប្រទេសវៀតណាមក៏កើតឡើងដែរ ដូច្នេះខ្ញុំក៏ត្រូវបាន បញ្ជូនឲ្យទៅប្រចាំការនៅខ្សែត្រៀមទាំងយប់ទាំងថ្ងៃ។

## រស់នៅលាក់ខ្លួនក្នុងព្រៃ

នៅពេលកងទ័ពវៀតណាម បានវាយចូលដល់ក្នុងទីរួមស្រុកកោះញែក ខ្ញុំ និងអង្គភាពយោធាខ្មែរក្រហមបានរត់ចូលព្រៃមេម៉ង់ ដែលជាព្រៃក្រាស់មើលមិនឃើញពន្លឺថ្ងៃដើម្បីលាក់ខ្លួនចំណែកប្រជាជនបានរស់នៅតាមភូមិឃុំដដែល។ អង្គភាពទ័ពរបស់ខ្ញុំដែលដឹកនាំដោយតា ដាំង និង តានូ មិនបានរស់នៅលាយឡំជាមួយប្រជាជនឡើយ ព្រោះខ្លាចប្រជាជនរាយការណ៍ប្រាប់កងទ័ពវៀតណាម។ នៅអំឡុងពេលនោះក៏មានការឃោសនាថា កងទ័ពវៀតណាមធ្វើបាប និងធ្វើទុក្ខបុកម្នេញប្រជាជនខ្មែរ ដែលធ្វើឲ្យខ្ញុំកាន់តែភ័យខ្លាចថែមទៀត។ ដោយឡែកការរស់នៅរបស់ប្រជាជនមានការខ្វះខាតអាហារហូបចុក កើតជំងឺរាករូស គ្រុនចាញ់ និងគ្មានថ្នាំសង្កូវបណ្ដាលឲ្យស្លាប់ជាច្រើន។

## មុំបី

ខ្ញុំបានរស់នៅក្នុងព្រៃក្នុងខេត្តមណ្ឌលគិរី រហូតដល់ឆ្នាំ១៩៨០ទើបឆ្លងទឹកមកនៅខេត្តក្រចេះមួយរយៈ។ ខ្ញុំ និងអង្គភាពទ័ពតំបន់បានរស់នៅក្នុងព្រៃដោយហូបតែក្លូច និងដំឡូងប៉ុណ្ណោះ។មកដល់ឆ្នាំ១៩៨១ ទើបខ្ញុំនិងអង្គភាពទ័ពបានធ្វើដំណើរបន្តឆ្លងមកស្រុកឆែប ខេត្តព្រះវិហារដោយទុកអ្នកជំងឺណាដែលដើរមិនរួចឲ្យធ្វើដំណើរមកតាមក្រោយ។នៅតាមផ្លូវខ្ញុំបានដឹកដំឡូង និងក្លូចហូបបន្ថែម ដោយសារតែគ្មានស្បៀងអាហារហូបគ្រប់គ្រាន់។ ពេលមកដល់ទន្លេល្ពៅ (តំបន់មុំបីឬច្រក១០០១) ជាប់ព្រំដែនឡាវថៃនិងកម្ពុជាទើបខ្ញុំមានអង្ករហូបដោយសុនសេន(អតីតរដ្ឋមន្ត្រីការពារជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-៧៩) បានទាក់ទងដឹកអង្ករមកពីខាងថៃ។ ក្រៅពីអង្ករក៏មានជំនួយជាអាហារកំប៉ុងពីអង្គការអន្តរជាតិដែរ។ មានជនភៀសខ្លួនជាច្រើនបានមករស់នៅមុំបី ហើយក៏មានថ្នាំពេទ្យ និងមន្ទីរពេទ្យសម្រាប់ព្យាបាលអ្នកជំងឺនៅទីនោះដែរ ដែលមានប្រធានឈ្មោះ តាឡូន។

## ជួបជាមួយបងស្រី

ខ្ញុំបានជួបជាមួយបងស្រីរបស់ខ្ញុំវិញពេលមកដល់មុំបី ប៉ុន្តែគាត់បានរៀបការរួចហើយ។ ក្រោយមកអង្គភាពទ័ពក៏បានបំបែកខ្ញុំឲ្យធ្វើការ នៅកងដឹកជញ្ជូនចំណែកបងស្រីខ្ញុំដែលរៀបការរួច អង្គភាពទ័ពឲ្យទៅនៅកងមីង១វិញ។ ខ្ញុំមកនៅផ្នែកដឹកជញ្ជូនក្នុងកងវរសេធំលេខ២៥៩ ដឹកនាំដោយតាពិន(ឆន)នៃកងពលលេខ៨០២គ្រប់គ្រងដោយតាសារឿនវិញ។រៀងរាល់ថ្ងៃខ្ញុំត្រូវងើបពីព្រលឹមដឹកជញ្ជូនអង្ករ និងគ្រាប់រំសេវចុះពីលើភ្នំយកទៅឲ្យយោធាខ្មែរក្រហម ដែលបោះទីតាំងនៅវាលជៀស និងអូរជុចហើយពេលថ្ងៃរសៀលខ្ញុំសែងអ្នករបួស ឡើងទៅព្យាបាលនៅមន្ទីរពេទ្យនៅលើភ្នំវិញ។យូរម្ដងៗ ខ្ញុំបានដឹកជញ្ជូនស្បៀងនិងគ្រាប់រំសេវពីទន្លេល្ពៅទៅភ្នំរូង និងច្រកអានសេះ ក្នុងស្រុកជាំក្សាន្ត។ ចំណែកខាងប្រជាជនគឺតាអានជាអ្នកគ្រប់គ្រង និងដឹកនាំដែលពេលនោះបានបង្កើតភូមិមួយសម្រាប់ប្រជាជនទាំងនោះរស់នៅដោយដាក់ឈ្មោះថា ភូមិ តាអាន តែម្ដង។

## រៀបការលើកដំបូង

នៅឆ្នាំ១៩៨២ ខ្ញុំបានរៀបការជាមួយបុរសម្នាក់ដែលធ្វើជាយោធា នៅក្នុងកងវរសេធំលេខ២៥៩ជាមួយខ្ញុំនៅទន្លេល្ពៅ។ ខ្ញុំសម្រាលបានកូនប្រុសម្នាក់ដោយពេលនោះមានឆ្មបមកបង្កើតកូនឲ្យខ្ញុំនៅផ្ទះ។ នៅអំឡុងឆ្នាំ១៩៨៤ក្រោយពេល ខ្ញុំសម្រាលបានកូនស្រីទីពីរបានរយៈពេលមួយអាទិត្យ ប្ដីរបស់របស់ខ្ញុំក៏បានដើរជាន់មីនផ្ទុះស្លាប់។ នៅក្នុងឆ្នាំដដែលកងទ័ពវៀតណាមនិងកងទ័ពរដ្ឋាភិបាល បានចាប់ផ្ដើមវាយសម្រុកចូលមកកាន់តែខ្លាំង ដូច្នេះខ្ញុំនិងប្រជាជនក៏

បាននាំគ្នារត់គេចខ្លួនឡើងទៅលើភ្នំៗ ខ្ញុំជួបការលំបាកយ៉ាងខ្លាំង ព្រោះត្រូវនៅមើលថែទាំកូនតូចៗ ត្រូវរកអង្ករដាំបាយឲ្យកូនហូប និងនាំកូនរត់រកកន្លែងលាក់ខ្លួនដោយសារកងទ័ពវៀតណាម និងកងទ័ពរដ្ឋាភិបាលបានវាយចូលមកទន្ទ្រានញឹកញាប់ៗ ដូច្នេះហើយនៅឆ្នាំ១៩៨៦ អង្គភាពយោធាក៏រៀបចំឲ្យខ្ញុំមានប្តីក្រោយទៀត ដើម្បីជួយមើលថែរក្សាគ្នាៗ គាត់គឺជាយោធាពិការនៅក្នុងកងពល៨០២ៗ នៅពេលនោះរដ្ឋាភិបាលថៃមិនទាន់អនុញ្ញាតឲ្យយោធាខ្មែរក្រហម និងប្រជាជនចូលទៅក្នុងទឹកដីរបស់គេឡើយៗ ក្រោយមកក៏មានការចរចារវាងថ្នាក់ដឹកនាំខ្មែរក្រហម និងរដ្ឋាភិបាលថៃ ទើបយោធាថៃយល់ព្រមអនុញ្ញាតឲ្យប្រជាជនឆ្លងចូលក្នុងទឹកដីរបស់គេ ដូច្នេះខ្ញុំក៏បាននាំកូនចាកចេញពីមុំបី ទៅរស់នៅម្តុំចងកដិតច្រក១០០៣វិញៗនៅអំឡុងពេលនោះមានប្រជាជន និងយោធាខ្មែរក្រហមជាច្រើនកងវរសេនាធំ និងកងពលភៀសខ្លួនទៅម្តុំចងកដែរៗ

### នៅជំរំ

ពីកន្លែងដែលខ្ញុំរស់នៅម្តុំចងកទៅជំរំអូរត្រាវនៅមិនឆ្ងាយពីគ្នាប៉ុន្មានឡើយ ប៉ុន្តែខ្ញុំមិនបានចូលទៅរស់នៅជំរំទេ ព្រោះប្តីរបស់ខ្ញុំមានឈ្មោះជាកងទ័ព (អ្នកដែលមានប្តីប្រពន្ធធ្វើជាកងទ័ពមិនត្រូវអនុញ្ញាតឲ្យរស់នៅក្នុងជំរំឡើយ)ៗ ទោះបីយ៉ាងណាខ្ញុំបានកត់ឈ្មោះបើករបបពីជំរំ ដូចបងស្រីរបស់ខ្ញុំនិងអ្នកប្រជាជនទូទៅដែលរស់នៅក្នុងជំរំដែរៗ នៅរាល់ពេលបុណ្យចូលឆ្នាំខ្មែរនិងបុណ្យភ្ជុំម្តងៗ ខ្ញុំតែងតែទទួលរបបស្ករទឹកត្រីទឹកដោះគោ ប៊ីចេង សណ្តែក និងអង្ករដំណើបពីអង្គការមនុស្សធម៌ យកមកវេចនំសម្រាប់សែនតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ និងទុកហូបក្នុងគ្រួសារៗ

### ចូលមកនៅដីខ្មែរ

បន្ទាប់ពីវៀតណាមដកកងទ័ពចេញពីប្រទេសកម្ពុជានៅឆ្នាំ១៩៨៩ខ្ញុំបានចូលមកស្នាក់នៅចល័តតាមបណ្តាយព្រំដែនក្នុងទឹកខ្មែរ រហូតដល់មានការចរចារកសន្តិភាពដែលរៀបចំដោយអង្គការសហប្រជាជាតិៗនៅឆ្នាំ១៩៩៣ តាម៉ុកបានយករថយន្តដឹកខ្ញុំរួមជាមួយ អតីតយោធា កម្មាភិបាលខ្មែរក្រហមនិងជនភៀសខ្លួនពីជំរំមករស់នៅក្នុង ស្រុកអន្លង់វែងខេត្តឧត្តរមានជ័យវិញ ដែលពេលចូលមកដល់ដំបូងខ្ញុំឃើញព្រៃឈើ ដុះណែនណាន់តាន់តាប់ស្ទើរតែដើរចូលមិនចុះៗ នៅខណៈពេលនោះដែរ រថយន្តឈូសផ្លូវ និងដឹកឈើរបស់ថៃក៏បានបើកចេញចូលក្នុងដីខ្មែររាល់យប់ស្ទើរតែធ្វើឲ្យខ្ញុំដេកមិនលក់ដែរៗ ថៃបានផ្តល់ប្រាក់រថយន្តធ្វើផ្លូវ និងត្រាក់ទ័រជាច្រើនគ្រឿងដល់តាម៉ុកវិញ ជាការដោះដូរជាមួយឈើទាំងនោះៗ

### រត់គេចពីការវាយប្រយុទ្ធ

មួយរយៈក្រោយមក ខ្ញុំក៏ឃើញមានវត្តមានកងថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ហៅកាត់ថា «អ៊ុនតាក់»មកដល់តំបន់របស់ខ្ញុំរស់នៅដែរៗ ប៉ុន្តែបន្ទាប់ពីការបោះឆ្នោតនៅឆ្នាំ១៩៩៣ដែលរៀបចំឡើងដោយ «អ៊ុនតាក់» ការវាយប្រយុទ្ធបានកើតឡើងម្តងទៀតរវាងកងកម្លាំងរបស់ខ្មែរក្រហមនិងកងកម្លាំងរបស់រាជរដ្ឋាភិបាលៗ នៅអំឡុងពេលនោះខ្ញុំត្រូវបានជម្លៀសចេញពីផ្ទះនៅស្រុកអន្លង់វែង ដោយទុកតែកម្លាំងយោធាខ្មែរក្រហមនៅឈរជើង ហើយកងយោធាខ្មែរក្រហមទាំងនោះក៏ចាប់វាយមីនដើម្បីការពារទីតាំងឈរជើងរបស់ខ្លួនៗ នៅរដូវវស្សា ខ្ញុំបានត្រឡប់មកធ្វើស្រែ និងចម្ការនៅផ្ទះនៅស្រុកអន្លង់វែងវិញ (ក្រោយមកក៏បំបែកទៅជាស្រុកត្រពាំងប្រាសាទរហូតដល់សព្វថ្ងៃព្រោះកងកម្លាំងទ័ពថ្មើរជើងនិងរថក្រោះរបស់រដ្ឋាភិបាលចូលមិនដល់តំបន់របស់ខ្ញុំរស់នៅឡើយដោយសារមានភ្លៀងធ្លាក់ច្រើន និងមានទឹកហូរកាត់ផ្លូវៗ ប៉ុន្តែចាប់ពីខែតុលាដល់ ខែធ្នូ ខ្ញុំត្រូវត្រៀមរត់គេចខ្លួនឡើងទៅលើភ្នំ និងរត់ចូលទៅក្នុងដីថៃវិញ ព្រោះកងកម្លាំងរដ្ឋាភិបាលវាយសម្រុកចូលមកដល់ៗ

### ស្ថានការណ៍ប្រែប្រួល

មកដល់ឆ្នាំ១៩៩៨ កងកម្លាំងខ្មែរក្រហមខ្លះចាប់ផ្តើមចរចាធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជាៗនៅអំឡុងពេលស្ថានការណ៍នយោបាយច្របូលច្របល់

នោះ តាម៉ុក បានចាប់ខ្លួនប្រធានកងពល៨០២ ដែលមានឈ្មោះសារឿនដែលគ្រប់គ្រងនៅស្រុកត្រពាំងប្រាសាទ និងបានយកឡានមកដឹកប្រជាជនទាំងយប់ចូលទៅក្នុងទឹកដីថៃវិញ។ ឃើញស្ថានភាពដូច្នេះ ជុំ ជាតិ គឺជាមេរបស់ខ្ញុំ និងតាលាវ ក៏បានគេចខ្លួនទៅសារភាព និងចុះចូលជាមួយរាជរដ្ឋាភិបាលនៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ដើម្បីទប់ស្កាត់ស្ថានការណ៍បែបនេះតាម៉ុកបានបញ្ជាឲ្យចាប់ប្រពន្ធកូនរបស់អ្នក ដែលរត់ទៅផ្តាច់ខ្លួនចុះចូលជាមួយរដ្ឋាភិបាលដើម្បីជាការគំរាមកំហែង។

## សមាហរណកម្ម

ក្រោយមកខ្ញុំក៏បានឆ្លងទំនប់ដាច់ ទៅសារភាព និងចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជានៅ ខេត្តព្រះវិហារដែរ។ រយៈពេល៤-៥ក្រោយមកសភាពការណ៍បានស្ងប់ស្ងាត់ទើបខ្ញុំត្រឡប់មករស់នៅស្រុកត្រពាំងវិញ។ ពេលនោះ សហរដ្ឋមន្ត្រីការពារជាតិដឹកនាំដោយឯកឧត្តមទា បាញ់ ក៏បានជិះយន្តហោះមកចូលរួមពិធីសមាហរណកម្មជាផ្លូវការ បន្ទាប់ពីតាម៉ុក ត្រូវបានចាប់ខ្លួន។ ទោះបីយ៉ាងណាខ្ញុំនៅតែបារម្ភ និងខ្លាចយោធាខ្មែរក្រហមក្នុងឯងដែលនៅមានចិត្តគុំគួនចូលមកវាយប្រហារដដែល ហើយមួយយប់ៗខ្ញុំដេកមិនលក់ឡើយ។ ភ្លាមៗបន្ទាប់ពីសមាហរណកម្ម ឧទ្ធម្ភាគចក្រខាងរដ្ឋាភិបាលក៏បានហោះមកចុះចតនៅតំបន់ ខ្ញុំរស់នៅក្នុងមួយថ្ងៃចាប់៤ទៅ៥គ្រឿង ហើយខាងរាជរដ្ឋាភិបាលក៏បានប្រកាសឲ្យប្អូនណាដែលចង់ទៅលេងស្រុកកំណើតអាចមកជិះឧទ្ធម្ភាគចក្រដែល នឹងហោះទៅចុះចតនៅព្រលានយន្តហោះអន្តរជាតិពោធិ៍ចិនតុង ដោយមិនយកឈ្នួលឡើយ។ខ្ញុំមិនបានសម្រេចចិត្តទៅលេងស្រុកកំណើតទេនៅពេលនោះ ព្រោះខ្ញុំគ្មានទ្រព្យសម្បត្តិអ្វីឡើយខ្ញុំខ្មាស់អ្នកស្រុកម្យ៉ាងទៀតខ្ញុំបានបែកពីស្រុកជាង៣០ឆ្នាំមកហើយ។

## រដូវបុណ្យភ្ជុំខ្ញុំនឹកស្រុក

នៅរដូវបុណ្យភ្ជុំឆ្នាំ១៩៩៨ខ្ញុំមានអារម្មណ៍នឹកស្រុកកំណើតយ៉ាងខ្លាំង ដូច្នេះខ្ញុំក៏បានពរកូនដើរកាត់ព្រៃពីត្រពាំងប្រាសាទសំដៅមកខេត្តសៀមរាប ដើម្បីរកតាក់ស៊ីជិះបន្តមកភ្នំពេញ។ នៅតាមផ្លូវធ្វើដំណើរអ្នកបើករថយន្តបាននិយាយអំពីអំពើអាក្រក់ជាច្រើនរបស់ក្រុមខ្មែរក្រហម ដែលបានធ្វើការវាយប្រហារដាក់គ្រាប់មីនផ្តាច់ស្ពាន និងថ្នល់ ដោយអ្នកបើកបរមិនដឹងថាអ្នកជិះទាំងអស់នៅក្នុងរថយន្តគឺជាអតីតខ្មែរក្រហមឡើយ។

ចំណែកខ្ញុំ និងអ្នកជិះផ្សេងទៀតក៏មិនហ៊ានតបត និងនិយាយពីប្រវត្តិផ្ទាល់ខ្លួនដែរព្រោះខ្លាចអ្នកបើកបរស្គាល់។មកដល់ភ្នំពេញខ្ញុំបានជិះម៉ូតូឌុបទៅផ្សារដើមគរ ដើម្បីរករថយន្តជិះបន្តទៅស្ទាបលែង ខេត្តកំពង់ស្ពឺ ប៉ុន្តែដោយសាររថយន្តទៅខេត្តកំពង់ស្ពឺចេញទៅផុតអស់ ទើបខ្ញុំសម្រេចចិត្តជិះរថយន្តនៅខេត្តតាកែវ ដោយជិះវាងផ្លូវទៅឈប់នៅផ្សារស័ង្កសីនៅពេលយប់ងងឹត ព្រោះមានវាយប្រយុទ្ធគ្នារវាងកម្លាំងយោធានិងប៉ូលីសរបស់រដ្ឋាភិបាលនៅតាមបណ្តោយផ្លូវជាតិលេខ៣។ ពីផ្សារស័ង្កសីទៅស្រុកកំណើតរបស់ខ្ញុំនៅស្រុកបសេដ ខេត្តកំពង់ស្ពឺ ខ្ញុំបានកុហកអ្នកបើកម៉ូតូឌុបដែលដឹកខ្ញុំថា ខ្ញុំមកពីខេត្តកំពង់ធំ ព្រោះខ្លាចអ្នកនោះដឹងការពិតហើយស្អប់ខ្ញុំជាអតីតខ្មែរក្រហម ដែលមកពីតំបន់អន្លង់វែង។ ខ្ញុំបានមកដល់ផ្សារស្ទាបលែងនៅពេលយប់ និងបានសុំសំយាបផ្ទះប្រជាជននៅទីនោះដើម្បីចងអង្រឹងឲ្យកូនតូចរបស់ខ្ញុំដេកបណ្តោះអាសន្ន ព្រោះខ្ញុំបានចាកចេញពីស្រុកជាង៣០ឆ្នាំ ដូច្នេះចំណាំផ្ទះមិនបានឡើយ។ ប៉ុន្តែក្រោយពីម្ចាស់នោះសួរនាំខ្ញុំ ហើយខ្ញុំប្រាប់ពីប្រវត្តិរូបពិតទើបដឹងថាយើងត្រូវជាបងប្អូននឹងគ្នា។ខ្ញុំបានសូមឲ្យម្ចាស់ផ្ទះជូនខ្ញុំទៅជួបឪពុកម្តាយ។ពេលទៅដល់ផ្ទះ ឪពុកម្តាយខ្ញុំបានភ្ញាក់ស្រឡាំងកាំង និងគាំងរកហាស្តីមិនរួចដោយគិតថាខ្ញុំមិនអាចមានជីវិតរស់នៅឡើយ ព្រោះយុវជននិងយុវនារីនៅក្នុងភូមិជាច្រើនដែលបានចាកចេញទៅបម្រើបដិវត្តន៍ខ្មែរក្រហមដំណាលខ្ញុំ បានស្លាប់អស់ហើយ។ចំណែកខ្ញុំក៏មានអារម្មណ៍ថា ដូចបានរស់ម្តងទៀតដែរនៅពេលជួបឪពុកម្តាយវិញ។

ខ្ញុំបានស្នាក់នៅភូមិកំណើតរយៈពេលកន្លះខែក៏ត្រឡ

ប់មកខេត្តឧត្តរមានជ័យវិញប៉ុន្តែដោយសារ ខ្ញុំមិនស្គាល់ទីតាំងភូមិសាស្ត្រ និងផ្លូវដើរមកផ្ទះច្បាស់លាស់ក៏វង្វេងនៅព្រៃម្តុំស្រែណូយ ព្រោះអំឡុងពេលនោះពីសៀមរាបទៅអន្លង់វែងមិនទាន់មានផ្លូវសម្រាប់រថយន្តបើកបរទេ គឺមានតែផ្លូវថ្មើរជើងនិងរទេះបរឆ្លងកាត់ប៉ុណ្ណោះ។ ខ្ញុំស្នាក់នៅស្រែណូយរយៈពេលពីរថ្ងៃ ទើបពរកូនដើរកាត់ព្រៃមកដល់ផ្ទះក្នុងស្រុកត្រពាំងប្រាសាទ។ ជារៀងរាល់ឆ្នាំ ខ្ញុំបានទៅធ្វើបុណ្យនៅស្រុកកំណើតរហូតដល់ឪពុករបស់ខ្ញុំស្លាប់។

## វត្តអារាម

បន្ទាប់ពីសមាហរណកម្មឆ្នាំ១៩៩៩ យើងបាននាំគ្នារៀបចំនិងបោសសម្អាតកន្លែងសម្រាប់គោរពបូជា ដោយជ្រើសរើសយកទីតាំងដែលមានប្រាសាទបុរាណក្នុងឃុំត្រពាំងប្រាសាទ។ ក្រោយមកប្តីរបស់ខ្ញុំបានរៀបចំសាងសង់សាលាឆទានសម្រាប់ចាស់ៗមកសុំសីល។ បន្ទាប់មក ខ្ញុំ និងប្តីរបស់ខ្ញុំព្រមទាំងប្រជាជន នៅក្នុងក៏និមន្តព្រះសង្ឃមកគង់ ហើយចាប់តាំងពីពេលនោះក៏មានការជួយឧត្តម្ភឈើ ស័ង្កសីដែក និងសម្ភារពីអតីតកម្មាភិបាលខ្មែរក្រហមដើម្បីសាងសង់សំណង់ផ្សេងៗនៅក្នុងវត្តបន្ថែមទៀត។ ក្រៅពីព្រះពុទ្ធសាសនាក៏មានអ្នកផ្សព្វផ្សាយពីគ្រិស្តសាសនាចូលមកក្នុងតំបន់ខ្ញុំរស់នៅដែរ។ មានប្រជាជនចំណូលថ្មីជាច្រើនបានប្រណិប័តណ៍គ្រិស្តសាសនា តាមរយៈបងប្អូនដែលធ្វើការនៅក្នុងស្ថាប័នសាសនានេះ ចំណែកអតីតខ្មែរក្រហមមានតិចតួចប៉ុណ្ណោះ។

## ការដឹកនាំភូមិឃុំ

ខ្ញុំត្រូវបានប្រជាជនជ្រើសរើសឲ្យធ្វើជាមេភូមិបន្ទាប់ពីសមាហរណកម្មនៅដើមឆ្នាំ១៩៩៩។ ពេលនោះយោធាកម្មាភិបាល និងគ្រួសារខ្មែរក្រហម បានមករស់នៅលើដីដែលខ្លួនបានកាប់រានចាប់តាំងពីកងកម្លាំងអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ ហៅកាត់ថា «អ៊ុនតាក់» ចូលមកប្រទេសកម្ពុជានៅឆ្នាំ១៩៩៣ មកម្ល៉េះ។ នៅពេលនោះគ្រួសាររបស់អតីតខ្មែរបានរានដីដើម្បីដាំដំណាំសម្រាប់ផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ ដោយមិនកំណត់ទំហំដីឡើយ។ ចំណែកខ្ញុំបានមកនៅឃុំទំនប់ដាច់ ព្រោះខ្ញុំមានដីទទឹង៦០ម៉ែត្រនិងបណ្តោយ១.០០០ម៉ែត្រ ដែលបានរានតាំងពីមុនមក។ ប្រជាជនចាប់ផ្តើមសង់ផ្ទះតូចៗសម្រាប់ស្នាក់នៅ ហើយក៏ចាប់ផ្តើមបង្កើតផ្សារលក់ដូរដែរ។ ប្រជាជនបានដាំដំឡូងនិងសណ្តែកសម្រាប់លក់ដែលធ្វើឲ្យជីវភាពកាន់តែធូរធា។ ខ្ញុំក៏បានលើកផែនការអាទិភាពដែលថ្នាក់ជាតិបានផ្តល់ឲ្យ( វិមជ្ឈការ) ដែលជាតម្រូវការជាក់ស្តែងរបស់ប្រជាជននៅក្នុងមូលដ្ឋាន។ ចាប់តាំងពីពេលនោះមក ប្រជាជននៅក្នុងភូមិរវល់ធ្វើការងារ និងមុខរបរស្រែចម្ការរៀងខ្លួន ដោយមិនសូវមានពេលជួបជុំគ្នាដូចមុនឡើយ។ ទោះបីយ៉ាងណាយើងនៅតែឆ្លៀតពេលជួបជុំគ្នា នៅពេលមានការងារនៅក្នុងភូមិនិងពិធីបុណ្យទានផ្សេងៗ។ ខ្ញុំសង្កេតឃើញថាប្រជាជនដែលខិតខំតែទទួលបានផលច្រើន។សម្រាប់ប្រជាជនដែលមិនខិតខំបានជួបការលំបាកនិងខ្វះខាតរហូតមកដល់សព្វថ្ងៃ។ ប្រជាជនមួយចំនួនបានលក់ដីធ្លី ហើយមួយចំនួនទៀតបានញៀនស្រានិងលេងល្បែង។ ខ្ញុំ និងប្រជាជនបានជួយដោយផ្តល់ជាអង្ករនិងសម្ភារប្រើប្រាស់ដល់គ្រួសារដែលជួបបញ្ហា និងខ្វះខាតទាំងនោះប៉ុន្តែទោះបីជាយ៉ាងណាក៏សម្ភារ ដែលយើងផ្តល់ឲ្យទាំងនោះមិននៅគង់វង្សបានយូរដែរ។ បញ្ហាទាំងនេះនៅតែកើតមាននៅក្នុងភូមិរបស់ខ្ញុំ។

## ការនិយាយរឿងរ៉ាវក្នុងរបបខ្មែរក្រហម

នៅពេលខ្ញុំនិយាយពីរឿងរ៉ាវរបស់ខ្ញុំ ពេលរត់ចូលក្នុងព្រៃលាក់ខ្លួនការអត់ឃ្លាន ជំងឺ គ្មានថ្នាំព្យាបាល និងការវាយប្រយុទ្ធគ្នាបណ្តាលឲ្យស្លាប់កូនរបស់ខ្ញុំបានតបមកខ្ញុំវិញថា«ម៉ែឯងចេះតែថាៗគ្មានអ្នកណាលំបាកដល់ថ្នាក់ហ្នឹងទេ»។ នៅអំឡុងរបបខ្មែរក្រហម ខ្ញុំមិនដែលគិតថាខ្លួនខ្ញុំនៅរស់រានមានជីវិតមកដល់សព្វថ្ងៃឡើយ។ ដូច្នេះ ខ្ញុំចង់ឲ្យមានការបង្រៀន និងនិយាយរឿងរ៉ាវពីក្នុងរបបខ្មែរក្រហមកាន់តែច្រើនដើម្បីឲ្យក្មេងជំនាន់ក្រោយបានយល់ដឹង។

**សោម ប៊ុនថន**

# ដំណឹងជ្រើសរើសនិស្សិតស្ម័គ្រចិត្ត

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសនិស្សិតស្ម័គ្រចិត្តចំនួន០៥រូប (អ្នកសរសេរអត្ថបទ ២រូប អ្នកបកប្រែ ២រូប និងក្រាហ្វិកកុំព្យូទ័រ ១រូប) ក្នុងចំណោមនិស្សិតសាកលវិទ្យាល័យនានាឲ្យមកបម្រើការងារចាប់ពីខែកញ្ញា ឆ្នាំ២០១៩ ដល់ខែវិច្ឆិកា ឆ្នាំ២០១៩ ហើយអាចបន្តទៅតាមគុណភាពការងារ។

១) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការបកប្រែអត្ថបទពីភាសាអង់គ្លេសមកជាភាសាខ្មែរឬពីភាសាខ្មែរទៅភាសាអង់គ្លេស។ អត្ថបទដែលនឹងត្រូវបកប្រែគឺអត្ថបទខ្លីនិងវែង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ ច្បាប់ និងអត្ថបទពិភាក្សានានា សរសេរដោយមេធាវី សាស្ត្រាចារ្យ អ្នកស្រាវជ្រាវបរទេស ឬសរសេរ ដោយប្រជាជនកម្ពុជា។

២) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការសរសេរអត្ថបទ សម្រាប់បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដី «ស្វែងរកការពិត» និងគេហទំព័រ http://www.khmerrougehistory.org

៣) អ្នកក្រាហ្វិកកុំព្យូទ័រ ឬរចនាទស្សនាវដ្ដី តម្រូវឲ្យចេះប្រើប្រាស់កម្មវិធី InDesign និងកម្មវិធីផ្សេងៗទៀត ដែលទាក់ទងនឹងការរចនាទស្សនាវដ្ដី។

ក្នុងអំឡុងពេលធ្វើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និស្សិតស្ម័គ្រចិត្តទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យចូលរួមវគ្គបណ្ដុះបណ្ដាល និងបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានា ដែលជាដៃគូសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជា ព្រះរាជាណាចក្រថៃ ហ្វីលីពីន ហុងកុង ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ជាដើម។

**លក្ខខណ្ឌសម្រាប់និស្សិតដែលអាចដាក់ពាក្យបាន មានដូចខាងក្រោម ៖**

១) និស្សិតកំពុងសិក្សាតាមសាកលវិទ្យាល័យរដ្ឋ និងឯកជននានា ដែលអាចប្រើប្រាស់ភាសាអង់គ្លេស។

២) មានអត្តចរិតថ្លៃថ្នូរ ម៉ឺងម៉ាត់ ព្យាយាម និងមានទំនួលខុសត្រូវចំពោះការងារ។

៣) មានចំណាប់អារម្មណ៍ផ្នែកការងារប្រវត្តិសាស្ត្រ ច្បាប់ និងសារព័ត៌មាន។

និស្សិតដែលមានលក្ខណៈសម្បត្តិដូចខាងលើ ហើយមានចំណាប់អារម្មណ៍នឹងការងារស្ម័គ្រចិត្តនេះ សូមផ្ញើពាក្យសុំបម្រើការងារមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង៥ល្ងាច។

**សូមភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖**

១) លិខិតសុំធ្វើការងារ១មួយច្បាប់ (Cover Letter) ដោយបញ្ជាក់អំពីទឹកចិត្តផ្ទាល់ខ្លួនចំពោះការងារឲ្យបានច្បាស់លាស់ និងក្បោះក្បាយ ដែលសរសេរដោយសាម៉ីខ្លួន។

២) ប្រវត្តិរូបសង្ខេប១ច្បាប់ (Resume)។

សូមផ្ញើមកកាន់អាសយដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬ អ៊ីម៉ែល truthbunthorn.s@dccam.org។ ប្រសិនបើមានចម្ងល់ សូមទូរសព្ទមកលេខ ០២៣ ២១៤ ០០៩ ឬ ០១២ ៩៩៦ ៧៥០។

**សូមអរគុណ!**

# អង្គជំនុំជម្រះសាលាដំបូង
# សេចក្តីសង្ខេបសាលក្រមសំណុំរឿង០០២/០២
## *ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម*

*(តពីលេខមុន)*

*៥៦.* ខៀវ សំផន មិនធ្លាប់ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ជាផ្លូវការម្តងណាទេ ប៉ុន្តែគាត់មានវត្តមាន និងបានចូលរួមយ៉ាងទៀងទាត់នៅក្នុងកិច្ចប្រជុំផ្សេងៗ របស់គណៈកម្មាធិការអចិន្ត្រៃយ៍បក្សដែលមានការពិភាក្សា ទៅលើបញ្ហាសំខាន់ៗទាក់ទងនឹងគោលបំណងរួមនេះ។ ក្នុងនាមជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ខៀវ សំផន បានចូលរួមនៅក្នុងសន្និបាតបក្សលើកទីបី លើកទីបួន និងលើកទីប្រាំ ដែលបានអនុម័តទៅលើគោលនយោបាយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ទាក់ទងនឹងមាគ៌ានយោបាយរួមស្របទៅនឹង គោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ។ ខៀវ សំផនគឺជាសមាជិកពេញសិទ្ធិនៅពេលដែលគណៈកម្មាធិការមជ្ឈិមបក្សយល់ព្រមប្រគល់ "សិទ្ធិកម្ទេច" ឲ្យទៅបក្សកុម្មុយនីស្តកម្ពុជានៅថ្នាក់ក្រោមៗ។ក្នុងនាមជាសមាជិកពេញសិទ្ធិ នៃគណៈកម្មាធិការមជ្ឈិមបក្សដែលមានសិទ្ធិបោះឆ្នោត ខៀវ សំផន បានចូលរួមចំណែកក្នុងការអនុម័តអនុស្សរណៈរបស់គណៈកម្មាធិការមជ្ឈិមបក្សនៅពាក់កណ្តាលឆ្នាំ១៩៧៨ ដែលធ្វើការអំពាវនាវឲ្យមានការអាណិតអាសូរចំពោះ "ជនដែលត្រូវគេបោកបញ្ឆោត" ឲ្យធ្វើជាគិញយួនដែលនេះជាគោលនយោបាយមួយ ដែលអង្គជំនុំជម្រះយល់ឃើញថាគ្មានឥទ្ធិពលជាក់ស្តែងនោះទេ។

អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន ជឿជាក់ថា ខៀវ សំផន មិនត្រឹមតែបានចូលរួមគាំទ្រជាមួយអ្នកផ្សេងទៅនឹងគោលបំណងរួមប៉ុណ្ណោះទេ ប៉ុន្តែគាត់ថែមទាំងបានគាំទ្រទៅលើគោលបំណងរួមនេះជាសាធារណៈនៅគ្រប់ពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទៀតផងៗ

*៥៧.* លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងទម្រង់មួយ ដែលបានបន្តគ្រប់ពេលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានផ្សព្វផ្សាយ អះអាង និងយល់ស្របជាសាធារណៈទៅលើគោលបំណងរួមនេះ។ គាត់ជាប្រធានសន្និបាតជាតិវិសាមញ្ញមួយ ដែលបានធ្វើឡើងនៅក្រោយថ្ងៃទី១៧ខែមេសាឆ្នាំ១៩៧៥ ហើយបានចូលរួមប្រជុំផ្សេងៗនៅខែឧសភា ឆ្នាំ១៩៧៥ នៅវិហារព្រះកែវមរកតក្នុងក្រុងភ្នំពេញ។ លើសពីនេះទៀត ខៀវ សំផនបានរក្សាមាគ៌ាបក្សដោយបានដឹកនាំវគ្គបំពាក់បំប៉ននៅក្នុងអគ្គមីទ្ទីង និងវគ្គរៀនសូត្រសម្រាប់អ្នកផ្សេងៗរួមទាំងអ្នកដែលវិលត្រឡប់មកពីបរទេស និងកម្មាភិបាលក្រសួងពាណិជ្ជកម្ម ក្នុងគោលបំណងពង្រឹងស្មារតីសង្គមនិយម បង្កើតអត្តសញ្ញាណកម្មករ-កសិករ និងធ្វើឲ្យមានការគាំទ្រគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ នៅខួបអនុស្សាវរីយ៍ថ្ងៃទី១៧ ខែមេសា និងនៅព្រឹត្តការណ៍ផ្សេងៗទៀតខៀវសំផនបានកោតសរសើរជាសាធារណៈចំពោះភាពជោគជ័យរបស់ បក្សកុម្មុយនីស្តកម្ពុជា ហើយបានលើកទឹកចិត្តឲ្យប្រជាជនគាំទ្រកម្មវិធីរបស់អង្គការក្នុងការកសាង និងការពាររបបកម្ពុជាប្រជាធិបតេយ្យ។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន មិនត្រឹមតែមានការគាំទ្ររួមជាមួយអ្នកផ្សេង លើគោលបំណងរួមនេះប៉ុណ្ណោះនោះទេ ប៉ុន្តែក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ គាត់បានលើកទឹកចិត្តយ៉ាងសកម្មយ៉ាងខ្លាំងក្លា និងជាសាធារណៈអះអាងបញ្ជាក់និងគាំទ្រគោលបំណងរួមនេះ នៅក្នុងប្រទេស និងនៅលើឆាកអន្តរជាតិ។ លើសពីនេះទៀត តាមរយៈសុន្ទរ

កថានិងសេចក្តីថ្លែងការណ៍ជាសាធារណៈជាច្រើនរបស់គាត់ ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានលើកទឹកចិត្ត និងញុះញង់ឲ្យមានការអនុវត្តគោលនយោបាយផ្សេងៗ របស់បក្សកុម្មុយនីស្តកម្ពុជា។

**៥៨.** សរុបមក អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផនបានចូលរួមនៅក្នុងគោលបំណងរួមៗ ក្នុងនាមជាអ្នកតំណាងឲ្យកម្ពុជាប្រជាធិតេយ្យ ខៀវ សំផន បានគាំទ្រ និងជំរុញគោលបំណងរួមនេះហើយបានលើកទឹកចិត្តញុះញង់និងផ្តល់ភាពស្របច្បាប់ ដល់ការអនុវត្តគោលបំណងរួមតាមរយៈគោលនយោបាយឧក្រិដ្ឋ។ គាត់ក៏បានណែនាំឲ្យកម្មាភិបាលអនុវត្តគោលនយោបាយទាំងនោះ ហើយនៅពេលជាមួយគ្នានោះគាត់បានផ្តល់លទ្ធភាព និងគ្រប់គ្រងទៅលើគោលនយោបាយទាំងនោះផងដែរ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវសំ ផន បានចូលរួមចំណែកយ៉ាងសំខាន់លើការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានប្រព្រឹត្តឡើង ហើយស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។

**៥៩.**ម្យ៉ាងវិញទៀតដូចបានរៀបរាប់ខាងលើរួចមក ហើយអង្គជំនុំជម្រះយល់ឃើញថា ខៀវសំផនមានចេតនារួមជាមួយនឹងសមាជិកសហឧក្រិដ្ឋកម្មផ្សេងៗទៀតរួមទាំងមានចេតនាជាក់លាក់ និងចេតនារើសអើងដែលជាលក្ខខណ្ឌកំណត់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងគោលបំណងរួមលើកលែងតែឧក្រិដ្ឋកម្មមួយប៉ុណ្ណោះ។ អង្គជំនុំជម្រះមិនអាចកំណត់ឬសន្និដ្ឋាន ពីចេតនាប្រល័យពូជសាសន៍របស់ ខៀវ សំផន ទាក់ទងនឹងជនជាតិចាមបានឡើយ។

**៦០.** ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានប្រព្រឹត្ត តាមរយៈសហឧក្រិដ្ឋកម្មរួម(ក)ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាលការនិរទេសការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំងការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនាការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍និងអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ ដោយបង្ខំ និងការរំលោភផ្លូវភេទក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ(ខ) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជាតិ ជាតិពន្ធុនិងពូជសាសន៍វៀតណាមនិង(គ) ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩តាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយឬសុខភាពការដកហូតដោយចេតនានូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់និងការឃុំខ្លួនដោយខុសច្បាប់នៅមន្ទីរ ស-២១ ប្រឆាំងនឹងបុគ្គលទាំងឡាយដែលត្រូវទទួលបានការការពារដោយអនុសញ្ញាហ្សឺណែវឆ្នាំ១៩៤៩។ អាស្រ័យហេតុនេះអង្គជំនុំជម្រះសម្រេចផ្តន្ទាទោសចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មរួមដែល ខៀវ សំផន មានចេតនាដោយផ្ទាល់ចេតនារើសអើង និងចេតនាជាក់លាក់ដូចសមាជិកសហឧក្រិដ្ឋកម្មរួមដទៃទៀតដែរ។

**៦១.** លើសពីនេះទៀត ពាក់ព័ន្ធនឹងការស្លាប់អ្នកធ្វើការ និងកសិករនៅសហករណ៍នៅការដ្ឋានការងារ និងនៅមន្ទីរសន្តិសុខ ដោយសារតែចេតនាដោយប្រយោល (ដែលមិនស្ថិតនៅក្នុងគោលបំណងរួមអង្គជំនុំជម្រះ យល់ឃើញថា ខៀវ សំផន បានជួយនិងជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាតនៅសហករណ៍ត្រាំកក់នៅការដ្ឋានការងារទំនប់១ មករាការដ្ឋានការងារទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងមន្ទីរសន្តិសុខ ស-២១មន្ទីរសន្តិសុខក្រាំងតាចាន់និងមន្ទីរ

សន្តិសុខភ្នំក្រោល។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការប្រព្រឹត្តរបស់ ខៀវ សំផន គួរតែត្រូវចាត់ទុកថាជាទម្រង់នៃការជួយនិងជំរុញ។ គាត់បានផ្តល់ការលើកទឹកចិត្ត និងការគាំទ្រផ្នែកស្មារតីដោយបានចូលរួមនៅក្នុងកិច្ចប្រជុំ និងមានវត្តមាន ព្រមទាំងថ្លែងសុន្ទរកថានៅក្នុងវគ្គរៀនសូត្រនៅទូទាំងប្រទេសដោយបានបានលើកទឹកចិត្តយ៉ាងចំហ និងសកម្ម ហើយផ្តល់ការគាំទ្រផ្នែកស្មារតី ដល់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ក្នុងការអនុវត្តគោលនយោបាយរបស់គណៈកម្មាធិការមជ្ឈិមបក្ស។ អង្គជំនុំជម្រះយល់ឃើញថា ទង្វើទាំងនេះមានឥទ្ធិពលយ៉ាងខ្លាំង លើការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ហើយ ខៀវ សំផន បានដឹងអំពីរឿងនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចផ្តន្ទាទោសចំពោះការជួយ និងជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតដោយចេតនាដោយប្រយោល នៅតាមទីតាំងដែលកើតមានឧក្រិដ្ឋកម្មខាងលើទាំងនេះ។

៦២. ជាចុងក្រោយ ភ័ស្តុតាងពុំបានបង្ហាញដល់កម្រិតមួយដែលថាខៀវសំផនបានជួយ និងសម្របសម្រួលយ៉ាងសកម្មលើការអនុវត្តគោលនយោបាយ ប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាមឡើយ។ អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន មិនមែនជាថ្នាក់លើក្នុងន័យថាគាត់មានលទ្ធភាពទប់ស្កាត់ ឬ ដាក់ទណ្ឌកម្មលើការប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ។ ហេតុដូចច្នេះអង្គជំនុំជម្រះយល់ឃើញថាខៀវ សំផនមិនត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជាតិពន្ធុចាម និងសាសនានោះទេហើយគាត់ក៏មិនមែនជាអ្នកជួយ និងជំរុញ និងជាថ្នាក់លើដែរ។

### ១.៥. សំណងចំពោះដើមបណ្តឹងរដ្ឋប្បវេណី

៦៣.ដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន៣.៨៦៥នាក់ត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះ និងត្រូវបានបញ្ចូលទៅក្នុងក្រុមដើមបណ្តឹងរដ្ឋប្បវេណី តែមួយក្នុងពេលជំនុំជម្រះ ដែលតំណាងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

៦៤. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ជនជាប់ចោទទាំងពីរនាក់ក្នុងសំណុំរឿង ០០២ ត្រូវបានកំណត់ថាជាជនក្រីក្រគ្មានលទ្ធភាព។ អនុលោមតាមវិធានផ្ទៃក្នុង អ.វ.ត.ក. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ទទួលស្គាល់នូវវិធានការសំណងជាក់លាក់នោះ។ វិធានការទាំងនោះត្រូវបង្កើតឬកំណត់ឡើង ដោយមានការសម្របសម្រួលគ្នាជាមួយនឹងអង្គភាពគាំពារជនរងគ្រោះ ក្នុងគោលបំណងធ្វើឲ្យមានការទទួលស្គាល់យ៉ាងត្រឹមត្រូវចំពោះព្យសនកម្ម ដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង ដោយសារតែការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយ ដែលកំពុងត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២និងធ្វើឲ្យមានការផ្តល់ជាអត្ថប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីជាការដោះស្រាយចំពោះព្យសនកម្មនេះ។ នៅក្នុងសំណុំរឿង ០០២/០២ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំឲ្យមានការទទួលស្គាល់តាមផ្លូវតុលាការចំពោះគម្រោងចំនួន១៤ ថាជាសំណងសមស្របក្នុងចំណោមគម្រោងចំនួន១៨ដែលបានស្នើសុំពីដំបូង។

៦៥.អង្គជំនុំជម្រះយល់ឃើញថាឧក្រិដ្ឋកម្មទាំងឡាយដែលជនជាប់ចោទ ត្រូវបានរកឃើញថាមានពិរុទ្ធបានធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះជាច្រើនផ្សេងទៀតទទួលរងព្យសនកម្មយ៉ាងខ្លាំង ដែលមិនអាចវាស់បានដែលរួមមានការឈឺចាប់ផ្នែករាងកាយ ការខាតបង់ផ្នែកសេដ្ឋកិច្ច ការបាត់បង់សេចក្តីថ្លៃថ្នូរ ការបាក់ស្បាតផ្លូវចិត្ត និងសេចក្តីទុក្ខព្រួយ ដោយសារតែការព្រាត់ប្រាសនិរាសសមាជិកគ្រួសារ ឬសាច់ញាតិលោហិត។

៦៦. អង្គជំនុំជម្រះយល់ឃើញថាគម្រោងខាងក្រោមនេះស្របតាមលក្ខខណ្ឌតម្រូវនៃវិធាន២៣ស្ទួនបួន នៃវិធានផ្ទៃក្នុងអ.វ.ត.ក. ហេតុដូច្នេះអង្គជំនុំជម្រះសម្រេចទទួលយកគម្រោងទាំងនេះ។ គម្រោងទី១គម្រោងទី២និងគម្រោងទី៣ពាក់ព័ន្ធនឹងទម្រង់ នៃការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម

និងបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានគោលបំណងមិនឲ្យរបបបែបនេះកើតឡើងសាជាថ្មី។ គម្រោងទី៤គម្រោងទី៥គម្រោងទី៦និងគម្រោងទី១២ គឺការចងក្រងឯកសារស្តីពីបទពិសោធន៍របស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណីរួមទាំងជនរងគ្រោះ ដែលទទួលរងការប៉ះពាល់ដោយការប្រព្រឹត្តលើជនជាតិចាម ការប្រព្រឹត្តលើជនជាតិវៀតណាម និងការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ ដើម្បីទប់ស្កាត់ការកើតឡើងវិញ នៃឧក្រិដ្ឋកម្មដែលកំណត់គោលដៅទៅលើក្រុមទាំងនេះ។ គម្រោងទី៧ គម្រោងទី៨គម្រោងទី៩និងគម្រោងទី១០រម្លឹកពីការចងចាំអំពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចឲ្យសង្គមទូទៅដឹងរឿងរ៉ាវទាំងនេះ ដែលផ្តល់ជាមធ្យោបាយធ្វើឲ្យពួកគាត់អាចមានការស្ងប់អារម្មណ៍។ គម្រោងទី១១ និងផ្នែកស្តីពីការថែទាំសុខភាពនៃគម្រោងទី១៣ ផ្តល់ការថែទាំសុខភាពផ្លូវចិត្តនិងផ្លូវកាយទៅដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្តោតលើការស្តារនីតិសម្បទា។

**៦៧.** អង្គជំនុំជម្រះយល់ឃើញថាផ្នែកជាក់លាក់មួយនៃគម្រោងទី១៣ ដែលទាក់ទងនឹងការគាំទ្រផ្នែកជីវភាពមានបំណងផ្តល់អត្ថប្រយោជន៍ដល់ ដើមបណ្តឹងរដ្ឋប្បវេណីក្នុងទម្រង់សំណងជាថវិកាផ្ទាល់ទៅបុគ្គលម្នាក់ៗ។ ដោយសារតែការផ្តួចផ្តើមទាំងនេះស្ថិតនៅក្រៅវិសាលភាពនៃវិធាន ២៣ ស្ទួនបួន(១)នៃវិធានផ្ទៃក្នុង អ.វ.ត.ក. ដែលចែងថាអង្គជំនុំជម្រះអាចផ្តល់ ត្រឹមតែសំណងផ្លូវចិត្តនិងជាសមូហភាពតែប៉ុណ្ណោះ ហើយមិនមានសំណងជាថវិកាសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេហេតុដូច្នេះហើយ អង្គជំនុំជម្រះមិនអាចអនុម័តទៅលើគម្រោងទាំងនេះ ថាជាវិធានការសំណងបានឡើយ។លើសពីនេះទៅទៀត អង្គជំនុំជម្រះមិនអាចអនុម័តទៅលើគម្រោងទី១៥ដែលចង់ឲ្យមានការទទួលស្គាល់លើការឈឺចាប់ដែលជនជាតិដើមភាគតិចនៅខេត្តរតនគិរី និងខេត្តមណ្ឌលគិរី បានទទួលរងដោយសារតែការមាក់ងាយការរើសអើងនិងការធ្វើទុក្ខបុកម្នេញបានឡើយ។អង្គជំនុំជម្រះរម្លឹកថាសំណុំរឿង០០២/០២ មិនមានការចោទប្រកាន់ទាក់ទងនឹងការកំណត់គោលដៅ ការរើសអើងឬការធ្វើទុក្ខបុកម្នេញលើជនជាតិភាគតិច ដែលរស់នៅខេត្តរតនគិរីនិងមណ្ឌលគិរីឡើយ។ ទោះបីជា បានទទួលស្គាល់អំពីគុណតម្លៃនៃគម្រោងនេះក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថាគម្រោងនេះមិនបំពេញតាមលក្ខខណ្ឌនៃវិធាន ២៣ ស្ទួនបួន (១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក. នោះទេ គឺថាវិធានការសំណងត្រូវទទួលស្គាល់ថាវាជាព្យសនកម្មដែលកើតមានឡើង ដោយសារតែការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលជនជាប់ចោទត្រូវបានផ្តន្ទាទោសប៉ុណ្ណោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះបដិសេធការអនុម័តលើគម្រោងនេះ។

**៦៨.** សេចក្តីសង្ខេបនៃសំអាងហេតុរបស់អង្គជំនុំជម្រះចប់ត្រឹមនេះ ហើយជាបន្តយើងនឹងអានផ្នែកសេចក្តីសម្រេច។

## ១.៦. ផ្នែកសេចក្តីសម្រេច និងការផ្តន្ទាទោស

**៦៩.** អង្គជំនុំជម្រះបដិសេធសំណើរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ដែលសុំឲ្យកម្រិតវិសាលភាពនៃសំណុំរឿង ០០២/០២។

**៧០.** អង្គជំនុំជម្រះសម្រេចផ្លាស់ប្តូរការកំណត់បទចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំង នឹងមនុស្សជាតិតាមរយៈការសម្លាប់រង្គាល ទៅជាការធ្វើមនុស្សឃាតដោយរួមបញ្ចូលចេតនា ដោយប្រយោលពាក់ព័ន្ធនឹងការស្លាប់ដែលបានកើតឡើងក្រោមលក្ខខណ្ឌនិងកាលៈទេសៈនានាដែលត្រូវបានប្រព្រឹត្តទៅលើជនរងគ្រោះនៅតាមទីតាំងឧក្រិដ្ឋកម្មដូចតទៅនេះ៖ សហករណ៍ត្រាំកក់ការដ្ឋានការងារទំនប់១មករាការដ្ឋានការងារទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងមន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់និងមន្ទីរសន្តិសុខភ្នំក្រោល។

**(នៅមានត)**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

# ក្រសួង អប់រំ យុវជន និងកីឡា ៖ សៀវភៅ «អំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅលើពិភពលោក» ប្រទេសអាមេនី, អាល្លឺម៉ង់, កម្ពុជា, បូស្នី-ហឺហ្សីហ្គោវីន និងរវ៉ាន់ដា «និដ្ឋភាពទូទៅសម្រាប់ការបង្រៀនក្នុងថ្នាក់រៀនកម្ពុជា»

ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការស្រាវជ្រាវរួមគ្នាជាលក្ខណៈវិទ្យាសាស្ត្រអស់រយៈពេល៤ ឆ្នាំកន្លងមកលើប្រធានបទស្តីពីអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រពិភពលោក ដើម្បីជាចំណេះដឹងបន្ថែមទៀតដល់អ្នកអាន អ្នកស្រាវជ្រាវ គ្រូបង្រៀន និងសិស្សានុសិស្សទាំងអស់ទាក់ទងនឹងប្រវត្តិសាស្ត្រជាតិប្រវត្តិសាស្ត្រតំបន់និងប្រវត្តិសាស្ត្រពិភពលោក។ ប្រវត្តិសាស្ត្រនៃការសម្លាប់រង្គាលគឺមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការអភិវឌ្ឍប្រទេសជាតិ។

កិច្ចការស្រាវជ្រាវខាងលើ ក៏ជាកាតព្វកិច្ចស្រាវជ្រាវមួយដែលត្រូវបានធ្វើឡើង ដើម្បីឆ្លើយតបទៅនឹងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំគម្រោងសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះដោយសារអំពើប្រល័យពូជសាសន៍ខ្មែរក្រហម ក្នុងសំណុំរឿង០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬដែលយើងហៅថា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម។ រាជរដ្ឋាភិបាលកម្ពុជាបានឯកភាព ឲ្យមានការបង្កើតឯកសារប្រវត្តិសាស្ត្រខ្មែរក្រហម និងដាក់បញ្ចូលសៀវភៅនេះជាផ្នែកមួយនៃកម្មវិធីសិក្សា ចាប់ពីថ្នាក់បំណេះដឹងទូទៅពីថ្នាក់ទី៧ដល់ថ្នាក់ទី១២ និងនៅថ្នាក់មូលដ្ឋាននៃកម្មវិធីសិ



*អដ្ឋិធាតុជនរងគ្រោះពីរបបខ្មែរក្រហមនៅអតីតមន្ទីរសន្តិសុខក្រាំងតាចាន់ ខេត្តតាកែវ*

ក្សាថ្នាក់ឧត្តមសិក្សា។ សេចក្តីសម្រេចស.ជ.ណ.លេខ១១៣ ៨របស់រាជរដ្ឋាភិបាលនេះធ្វើឡើងនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០១៣។



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា រួមជាមួយតារាភាពយន្តហូលីវូដ ចច ក្លូនី ចូលរួមពិធីរំឭកខួប១០០ឆ្នាំ នៃអំពើប្រល័យពូជសាសន៍លើជនជាតិអាមេនី កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៦។ លោក ចច ក្លូនី បានរៀបការជាមួយ អាម៉ាល់ ក្លូនី ដែលតំណាងឲ្យប្រទេសកម្ពុជាក្នុងការទាមទារទឹកដីប្រាសាទព្រះវិហារ។ អាម៉ាល់ ក្លូនី បានតស៊ូមតិក្នុងនាមប្រទេសកម្ពុជា ដើម្បីទាមទារប្រាសាទព្រះវិហារ នៅមុនការសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិ។ រូបថតនេះត្រូវបានថតដោយ អាណា គឺជាបុគ្គលិក នៃមូលនិធិនៃវិទ្យាស្ថានសារមន្ទីរប្រល័យពូជសាសន៍អាមេនីដែលបានផ្តល់ជូន លោក ឆាំង យុ។

ដំណើរការតែងនិពន្ធពិនិត្យផ្ទៀងផ្ទាត់បោះពុម្ពនិងចែកផ្សាយសៀវភៅក្រសួងអប់រំយុវជននិងកីឡាបានគាំទ្រយ៉ាងពេញទំហឹង ដល់ កិច្ចការស្រាវជ្រាវ ជាលក្ខណៈវិទ្យាសាស្ត្ររបស់ មជ្ឈមណ្ឌលឯកសារកម្ពុជា តាំងពីដំបូង រហូតដល់ការបោះពុម្ពស្នាដៃស្រាវជ្រាវនេះ នៅក្នុងឆ្នាំ ២០១៩។ ស្នាដៃនេះដែលជាសំណេរស្រាវជ្រាវលើកដំបូងស្តីពីអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅលើពិភពលោកគឺជាការតាក់តែងនិពន្ធឡើង ដោយអ្នកស្រាវជ្រាវជាតិនិងអន្តរជាតិចំនួន៤រូបគឺៈបណ្ឌិតលី សុខឃាង ,បេក្ខបណ្ឌិតសូហ្វារីណា, បណ្ឌិតជា ដល្លា និងមេធាវីគ្រីស្តូហ្វ័រឌៀរីង និងក្រោមការពិនិត្យផ្ទៀងផ្ទាត់ពី ប្រវត្តិវិទូនិងអ្នកជំនាញប្រវត្តិសាស្ត្រល្បីៗ ជាច្រើនរូប រួមមានៈបណ្ឌិតសាស្ត្រាចារ្យអាឡិចសាន់ឌើ ហ៊ីនតុន, ប្រវត្តិវិទូនិងសាស្ត្រាចារ្យ ដេវីដឆេនដល័រ,បណ្ឌិតសាស្ត្រាចារ្យម៉ាគើសហ្សីមម័រ, បណ្ឌិតសាស្ត្រាចារ្យមីលតុនអស្បូន,មេធាវីនីកូឡាសគាំចាន់, អ្នកស្រាវជ្រាវនីស្សាដេថេលនិងអ្នកគ្រូខែលលី វ៉ាត់ សុន។ សៀវភៅនេះត្រូវបានឆ្លងកាត់ការពិភាក្សា ជាមួយសាស្ត្រាចារ្យឧត្តមសិក្សាកម្ពុជាចំនួន៥០រូប ដែលបានចូលរួមនៅក្នុងអង្គសិក្ខាសាលាស្តីអំពី ការបង្រៀនប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យរយៈពេល៣ ថ្ងៃដែលបានប្រព្រឹត្តទៅនៅក្នុងខែមេសា ឆ្នាំ២០១៩ រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជានិង

ក្រសួងអប់រំ យុវជន និងកីឡា។

មជ្ឈមណ្ឌលឯកសារកម្ពុជា បោះពុម្ពសៀវភៅនេះជាពីរភាសាគឺភាសាអង់គ្លេស និងភាសាខ្មែរហើយគ្រោងធ្វើការចែកចាយដល់គ្រូបង្រៀន និងសិស្សានុសិស្សនៅតាមវិទ្យាល័យមួយចំនួន នៅក្នុងខែធ្នូ ឆ្នាំ២០១៩ ខាងមុខសម្រាប់ប្រើប្រាស់ជាឯកសារយោងដ៏មានសារសំខាន់ក្នុងការរៀន និងបង្រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងប្រវត្តិសាស្ត្រពិភពលោក។ សៀវភៅជាភាសាខ្មែរគឺត្រូវបានត្រួតពិនិត្យសម្រួលឃ្លោងឃ្លាដោយផេង ពង្សរ៉ាស៊ី និងសុភ័ក្រ្ត ភាណា។ សូមបញ្ជាក់ថាអត្ថបទប្រទេសអាមេរិកសរសេរដោយបណ្ឌិតជាងល្វា, ប្រទេសអាល្លឺម៉ង់សរសេរដោយ បណ្ឌិតសូហ្វារីណាប្រទេសកម្ពុជាសរសេរដោយ បេក្ខបណ្ឌិត សូ ហ្វារីណា និងមេធាវី គ្រីស្តូហ្វ័រឌៀរីង,ប្រទេសបូស្នី-ហឺហ្ស៊ីហ្គោវីននិងប្រទេសរវ៉ាន់ដាសរសេរដោយបណ្ឌិត លីសុខឃាង។ឧត្ថម្ភថវិកាក្នុងការសិក្សាស្រាវជ្រាវនិងបោះពុម្ពសៀវភៅនេះ ដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)។




*ក្របសៀវភៅអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅលើពិភពលោក*

***អំពីសៀវភៅ និងទស្សនវិជ្ជាក្នុងការបង្កើតសៀវភៅ***

ក្របមុខនៃសៀវភៅ ត្រូវបានរចនាឡើងជាផ្ទៃក្រហមព្រឿងៗ និងមានចំណងជើងធំៗពណ៌សដែលអាចមើលឃើញយ៉ាងច្បាស់ថា« អំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅលើពិភពលោក(ប្រទេសអាមេរិក, អាល្លឺម៉ង់, កម្ពុជា, បូស្នី-ហឺហ្ស៊ីហ្គោវីន និងរវ៉ាន់ដា) ៖ ទិដ្ឋភាពទូទៅ សម្រាប់ការបង្រៀនក្នុងថ្នាក់រៀនកម្ពុជា»។ ចំផ្ទៃកណ្ដាលនៃក្របមុខមានរូបសំណាកអ្នកតាមួយអង្គ ដែលមើលមួយភ្លែតយើងអាចសន្និដ្ឋានបានថា ជារូបតំណាងឲ្យ ភាពគ្មានលាក់លៀមបាននៃរឿងរ៉ាវដែលបានកើត ឡើងនៅក្នុងពិភពលោកតាមរយៈព្រះភក្ត្រទាំងប្រាំបី ដែលបែរមុខទៅគ្រប់ទិសទាំងអស់។រូបសំណាកអ្នកតា ដែលមានព្រះភក្ត្រប្រាំបីនិងមានពណ៌ខុសៗគ្នានេះគឺសំដៅទៅលើភាពខុសគ្នានៃចរិតឫកពារនិងការប្រព្រឹត្តរបស់មនុស្សជាតិ

ដែលត្រូវប្រឈមនឹងភាពស្មុគស្មាញ នៃស្ថានភាពរបស់ខ្លួនៗ រូបសំណាកនេះ ក៏តំណាងឲ្យភាពអប់រំអំពីវប្បធម៌សាសនា វិទ្យាសាស្ត្រសិល្បៈ និងទស្សនវិជ្ជាដែលមនុស្សត្រូវតែគិតគូរ និងយកចិត្ត ទុកដាក់ដើម្បីបញ្ចៀសនូវរាល់អំពើមិនល្អ កើតមាននៅក្នុងសង្គមៗរូបសំណាកនេះស្ថិតនៅលើពើយតាម៉ុក លើខ្នងភ្នំដងរែក ដែលជាទីតាំងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក្នុងស្រុក អន្លង់វែងខេត្តឧត្តរមានជ័យៗ

គ្របក្រោយនៃសៀវភៅ មានពណ៌ខ្មៅដិត គ្របដណ្តប់ពាសពេញលើអក្សរតូចៗពណ៌ក្រហមជាច្រើនតួ និងរូបទង់ជាតិខុសៗគ្នានៃប្រទេសទាំង៥ ដែលជាប្រធានបទនៃការសិក្សា ហើយដែលអាចឲ្យយើងដឹងបានពីភាពឃោរឃៅអមនុស្សធម៌និងការសម្លាប់រង្គាលទៅលើប្រជាជននៃប្រទេសទាំង៥នៅលើពិភពលោកៗ

នៅទំព័រខាងក្នុងនៃសៀវភៅនេះ មុននឹងចូលដល់ការអធិប្បាយពីបរិបទប្រវត្តិសាស្ត្ររបស់ប្រទេសនីមួយៗ មានអារម្ភកថាមួយទំព័ររបស់ឯកឧត្តមបណ្ឌិតសភាចារ្យហង់ជួនណារ៉ុនរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡារៀបរាប់ពីតួនាទីនិងភារកិច្ចដ៏ចម្បង និងមានប្រសិទ្ធភាពក្នុងវិស័យអប់រំក្នុងការចូលរួមចំណែកទប់ស្កាត់នូវរាល់ធាតុផ្សំទាំងឡាយ ដែលនាំដល់ការកកើតអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងសង្គមៗសាររបស់ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីបានសង្កត់ធ្ងន់ ដោយផ្តោតយ៉ាងសំខាន់ទៅលើការបង្កើនភាពយល់ដឹងជាសកល អំពីបរិបទប្រវត្តិសាស្ត្ររបស់ប្រទេសទាំង៥ ដែលបានលើកយកមកធ្វើជាករណីសិក្សានៅក្នុងសៀវភៅនេះតាមរយៈ ការបំផុសគំនិតឆន្ទៈមនសិការ និងការវិភាគយ៉ាងស៊ីជម្រៅ ទៅលើស្ថានភាពរបស់មនុស្ស និងសង្គមនាពេលអតីតកាល ដោយធ្វើការសិក្សាប្រៀបធៀបពីកាលៈទេសៈនៃព្រឹត្តិការណ៍ នៅក្នុងប្រទេសមួយទៅនឹងប្រទេសមួយទៀត ដើម្បីរារាំងបាននូវការបំផ្លិចបំផ្លាញការបំពារបំពានហួសនិស្ស័យ ដែលបានញាំញីដល់សេចក្តីសុខរបស់



ស្តូបរំឭកវិញ្ញាណក្ខន្ធពីអំពើប្រល័យពូជសាសន៍ទៅលើជនជាតិអាមេនី ស៊ីតសឺណាកាបើដ នៅក្រុងយេរេវ៉ាន ប្រទេសអាមេនីៗ រៀងរាល់ឆ្នាំនៅថ្ងៃទី២៤ ខែមេសា ប្រជាជនអាមេនី រាប់ពាន់នាក់បានមកជួបជុំគ្នានៅស្តូបរំឭកវិញ្ញាណក្ខន្ធដើម្បីប្រារព្ធ «ថ្ងៃចងចាំនៃអំពើប្រល័យពូជសាសន៍ទៅលើជនជាតិអាមេនី»ៗ រូបថត ៖ ដោយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ខែមេសា ឆ្នាំ២០១៦ៗ

ប្រជាជាតិទាំងមូល។

ស្រដៀងគ្នានេះដែរ នៅក្នុងបុព្វកថារបស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងស្ថាបនិកវិទ្យាស្ថានស្លឹករឹត ដែលសរសេរនៅក្នុងទំព័របន្ទាប់ក៏បានគូសបញ្ជាក់អំពីភាពខ្លាំងនៃការអប់រំថា ជាថាមពលដ៏មហិមាក្នុងការកែប្រែសង្គមនាពេលអនាគត និងជាអំណាចដ៏អស្ចារ្យរបស់មនុស្សជាតិ ក្នុងការសម្រេចបាននូវសន្តិភាព សេរីភាព និងយុត្តិធម៌។ លើសពីនេះទៀត បុព្វកថារបស់លោកនាយកក៏បានបង្ហាញពីគន្លឹះ និងដំណោះស្រាយជាច្រើនក្នុងការរារាំងអំពើប្រល័យពូជសាសន៍ការសម្លាប់រង្គាល និងអំពើហិង្សាធ្ងន់ធ្ងរនានា។ក្នុងនោះការចូលរួមពីថ្នាក់មូលដ្ឋាននៅក្នុងយុទ្ធសាស្ត្រជាសកលក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មទាំងនោះ គឺជាភារកិច្ចដែលមិនអាចខ្វះបានទាល់តែសោះ។

បន្ថែមពីនេះទៀត នៅក្នុងទំព័រនៃសេចក្តីផ្តើមនៃសៀវភៅអ្នកត្រួតពិនិត្យអត្ថបទនិពន្ធភាសាអង់គ្លេសមេធាវី គ្រីស្តូហ្វ័រឌៀរីងបានអះអាងបន្ថែមថា «ខណៈដែលយុទ្ធសាស្ត្រក្នុងការធ្វើអន្តរាគមន៍ការឆ្លើយតបនិងការទប់ស្កាត់ ត្រូវពឹងផ្អែកលើស្ថាប័នជាតិនិងអន្តរជាតិ បុគ្គល និងសហគមន៍ ក៏ត្រូវតែចូលរួមចំណែកនៅក្នុងយុទ្ធនាការជាសកលនេះដែរ» និងបានបញ្ជាក់បន្ថែមថាបុគ្គលនិងសហគមន៍ ត្រូវតែសិក្សាឲ្យបានស៊ីជម្រៅទៅលើឫសគល់នៃអំពើអមនុស្សធម៌នានា ដែលអំពើទាំងនោះកើតចេញពីការលម្អៀងអាត្មានិយម និងភាពអវិជ្ជារបស់មនុស្ស។ បណ្ឌិតជា ផល្លា ដែលជាអ្នកនិពន្ធមួយរូបបានសរសេរថា ថ្វីត្បិតតែការអប់រំ គឺជាមធ្យោបាយដ៏មានសារសំខាន់បំផុតមួយ ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងការស្អប់ខ្ពើម និងការមិនអត់ឱនគ្នាក៏ដោយក៏ការទទួលបានព័ត៌មានការយល់ពីច្បាប់ និងការយល់ដឹងពីដំណោះស្រាយជាមូលដ្ឋាន គឺជាកត្តារួមចំណែកដែលមិនអាចខ្វះបានដែរ។អ្នកនិពន្ធទាំង២ខាងលើបានធ្វើសេចក្តីសន្និដ្ឋានថាមានតែការអប់រំការទទួលបានព័ត៌មានការកែទម្រង់ និងការឆ្លុះបញ្ចាំងខ្លួនឯងទេ ដែលអាចកាត់បន្ថយឥទ្ធិពលនៃការកកើតធាតុផ្សំនានាដែលនាំដល់ការកកើតអំពើអនុស្សធម៌បាន។



សាស្ត្រាចារ្យប្រវត្តិសាស្ត្រ គួង គានី នៅក្នុងសិក្ខាសាលាស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងវគ្គបណ្តុះបណ្តាលគ្រូប្រវត្តិសាស្ត្រ ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួង អប់រំ យុវជន និង កីឡា

ក្នុងទំព័របន្តបន្ទាប់ទៀត គឺជាការរៀបរាប់ពីបរិបទប្រវត្តិសាស្ត្រនៃករណីសិក្សាទាំង៥ រួមមានៈ ប្រទេស អាមេនី, អាល្លឺម៉ង់, កម្ពុជា, បូស្នី-ហឺហ្សេហ្គោវីន និងរវ៉ាន់ដា។ បរិបទប្រវត្តិសាស្ត្រនៃប្រទេសនីមួយៗត្រូវបាននិពន្ធ និងអធិប្បាយឡើងជាពីរផ្នែកគឺផ្នែកទី១)គឺជាផ្នែកមេរៀនសង្ខេប និងផ្នែកទី២)គឺជាផ្នែកមេរៀនលម្អិត។ផ្នែកនីមួយៗ មានរួមបញ្ចូលទាំង៖ ១) សកម្មភាពប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងមូលហេតុនៃការសម្លាប់រង្គាល។ ២) ដំណើរការស្វែងរកយុត្តិធម៌បន្ទាប់ពីអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលបានបញ្ចប់និង៣) ដំណើរការផ្សះផ្សាជាតិនិងការទប់ស្កាត់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនានា។

ផ្នែកទី១ «មេរៀនសង្ខេប» គឺជាផ្នែកសិក្សារបស់សិស្សខណៈដែលផ្នែកទី២«មេរៀនលម្អិត»គឺជាផ្នែកដែលគ្រូបង្រៀនប្រើប្រាស់សម្រាប់ការបង្រៀននៅក្នុងថ្នាក់ ដើម្បីបំពេញបន្ថែមទៅលើផ្នែកមេរៀនសង្ខេប ដើម្បីបង្កើនការយល់ដឹងរបស់សិស្សឲ្យកាន់តែទូលំទូលាយ។ ជាមួយគ្នានេះដែរ គ្រូបង្រៀន ដែលបង្រៀនមុខវិជ្ជាផ្សេងពីមុខវិជ្ជាប្រវត្តិវិទ្យាក៏អាចប្រើប្រាស់ផ្នែកទី១នៃករណីសិក្សានីមួយៗ សម្រាប់ការបញ្ជ្រៀបប្រវត្តិសាស្ត្រនៅក្នុងម៉ោងបង្រៀនរបស់ខ្លួនបានដែរ។ ទាំងផ្នែកទី១ និងទី២ គឺមានកម្រងសំណួរមួយចំនួនដែលគ្របអត្ថន័យមេរៀនទាំងមូល។

នៅចុងបញ្ចប់នៃសៀវភៅនេះ កម្រងសំណួរទាំងអស់ដែលមាននៅតាមបណ្តាប្រវត្តិសាស្ត្រ នៃប្រទេសនីមួយៗត្រូវបានរៀបរៀង និងផ្តល់ចម្លើយយ៉ាងក្បោះក្បាយនៅក្នុងផ្នែកចុងក្រោយ គឺផ្នែកទី៣ ដើម្បីផ្តល់ភាពងាយស្រួលដល់សិស្សានុសិស្សនិងគ្រូបង្រៀន ក្នុងការសង្កេត និងផ្ទៀងផ្ទាត់ចំពោះការបង្រៀននិងការសិក្សារបស់ខ្លួន។ ជាពិសេសទៅទៀតផ្នែកនេះអាចជួយដោះស្រាយ នូវរាល់ចម្ងល់ផ្សេងៗដែលកើតមានជាយូរមកហើយរបស់អ្នកអានទូទៅ។

ម៉្យាងវិញ ទៀតតាមរយៈការអានសំណួរនិងចម្លើយក្នុងផ្នែកទីនេះអ្នកអានក៏អាចត្រឡប់ទៅអានផ្នែកទី១ និងផ្នែកទី២បាន ក្នុងករណីដែលខ្លួនចង់ដឹងឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀតទៅលើករណីសិក្សានៃប្រទេសនីមួយៗ។ ជាមួយគ្នានេះដែរអ្នកអានអ្នកស្រាវជ្រាវ សាស្ត្រាចារ្យគ្រូបង្រៀន និងសិស្សានុសិស្សទាំងអស់អាចស្វែងយល់កាន់តែច្បាស់ ថែមទៀតតាមរយៈការចូលទៅមើលបញ្ជីឯកសារយោង ជាច្រើនដែលមានរាយឈ្មោះអ្នកនិពន្ធចំណងជើង កន្លែងបោះពុម្ពនិងឆ្នាំបោះពុម្ពយ៉ាងជាក់លាក់ នៅក្នុងផ្នែក «បញ្ជីឯកសារពិគ្រោះ»នៃសៀវភៅដើម្បីជាជំនួយដល់ការស្រាវជ្រាវ និងអានឯកសារយោងទាំងនេះដោយលម្អិត។ បញ្ជីនេះត្រូវបា នរៀបរៀងតាមលំដាប់នៃ ប្រទេសនីមួយៗដាច់ដោយឡែកពីគ្នាដែលអាចផ្តល់ភាពងាយស្រួល និងច្បាស់លាស់សម្រាប់ការសិក្សាស្រាវជ្រាវបន្ថែម។

## ទស្សនវិជ្ជានៃការបង្កើតសៀវភៅ

ការលើកយកប្រទេសទាំង៥ មកធ្វើជាករណីសិក្សាគឺពុំមានចេតនាតំណាងឲ្យ ឬសង្ខេបអំពីព្រឹត្តិការណ៍ទាំងអស់នៃអំពើអមនុស្សធម៌ ដែលកើតមាននៅក្នុងប្រវត្តិសាស្ត្រពិភពលោកទាំងស្រុងនោះទេ ហើយក៏មិនត្រូវបានចាត់ទុកថាជាករណីសិក្សាដ៏សំខាន់បំផុតស្តីពីការស្អប់ខ្ពើម និងការមិនអត់ឱនគ្នាសម្រាប់ថ្នាក់រៀននៅក្នុងប្រទេសកម្ពុជាដែរ។ទោះបីជាយ៉ាងដូច្នេះក៏ដោយក៏ជម្លោះ និងអំពើអមនុស្សធម៌ក្នុងករណីសិក្សា ដែលបានលើកយកមកសិក្សានេះត្រូវបានវិភាគវែកញែក និងចំណាត់ថ្នាក់ដែលរាប់ចាប់តាំងពីចិត្តវិទ្យារហូតដល់រចនាសម្ព័ន្ធដឹកនាំជាក់លាក់ៗ អ្នកនិពន្ធទាំង៤រូបនៅក្នុងសៀវភៅនេះ មានចេតនាបង្ហាញពីកាប្រព្រឹត្តទៅរបស់ពិភពលោកសម្រាប់អំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលថាបានប្រព្រឹត្តទៅដែលមានលក្ខណៈ ស្រដៀងគ្នាដូចគ្នានិងខុសគ្នា អាស្រ័យលើបរិបទប្រវត្តិសាស្ត្រស្ថានភាពនយោបាយ វប្បធម៌ សាសនាជាតិពន្ធុជាតិសាសន៍ និងអត្តសញ្ញាណនៃមនុស្សដែលរស់នៅក្នុងបរិស្ថានខុសៗគ្នា។

បណ្ឌិត ជា ផល្លា និងមេធាវី គ្រីស្តូហ្វ័រឌៀរីងបានសរសេរដូច្នេះថា« តាមរយៈគោលគំនិតរួមករណីផ្សេងៗនៃការ

សម្លាប់រង្គាលកើតឡើង ដោយសារតែកត្តាជាតិពន្ធុនិងពូជសាសន៍ ខណៈដែលអំពើឧក្រិដ្ឋកម្មដទៃទៀតអាចត្រូវបានចាត់ទុកថាមានលក្ខណៈនយោបាយ។ ក្រៅពីធ្វើការកំណត់គោលដៅលើក្រុមសាសនា និងជាតិពន្ធុណាមួយដែលមិនប្រតិបត្តិតាមឬមិនសមស្រប ជាមួយនឹងចក្ខុវិស័យជ្រុលនិយមនៃរបបកម្ពុជាប្រជាធិបតេយ្យរបស់ខ្លួនចំណុចដែលខុសប្លែកពីករណីសិក្សាដែលបានលើកឡើង នៅក្នុងសៀវភៅនេះគឺខ្មែរក្រហមកំណត់ក្រុមគោលដៅ ដោយផ្អែកលើភាពអត្តសញ្ញាណនិងរបៀបវារៈនយោបាយ»។

### ការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា

ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡាបានស្ងើចសរសើរចំពោះស្នាដៃនេះ និងបានផ្តល់ការឯកភាពចំពោះបេសកកម្មអប់រំ ដើម្បីលើកកម្ពស់ការយល់ដឹងពីប្រវត្តិសាស្ត្រ ឲ្យកាន់តែស៊ីជម្រៅថែមទៀតតាមរយៈការត្រិះរិះពិចារណា និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការសិក្សាយ៉ាងស៊ីជម្រៅអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដែលកើតមានឡើងនៅលើពិភពលោក។

ឯកឧត្តមបណ្ឌិតសភាចារ្យ បានមានប្រសាសន៍ដូច្នេះថា «ក្នុងនាមខ្ញុំជាអ្នកចូលចិត្ត និងស្រាវជ្រាវប្រវត្តិសាស្ត្រខ្ញុំពិតជាមានសេចក្តីសោមនស្ស និងសូមកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានចងក្រងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ របស់ប្រទេសមួយចំនួនដែលមានការសម្លាប់រង្គាល ក្នុងប្រវត្តិសាស្ត្រពិភពលោក ដូចជា ប្រទេសអាមេនី ប្រទេសអាល្លឺម៉ង់ ប្រទេសបូស្នី-ហឺហ្សេហ្គោវីន និងប្រទេសរវ៉ាន់ដា ដើម្បីបង្កើនការយល់ដឹងឲ្យកាន់តែច្បាស់ និងទូលំទូលាយថែមទៀត។ មានតែឆន្ទៈមនសិការ ចំណេះដឹង និងការយល់ដឹងស៊ីជម្រៅអំពីស្ថានភាពមនុស្សជាតិរបស់យើងទេ ទើបយើងអាចរារាំងបាននូវការបំផ្លិចបំផ្លាញការបំពារបំពានហួសនិស្ស័យ ដែលញាំញីដល់សេចក្តីសុខរបស់ប្រជាជាតិយើង»។

លោក រស់ សុវាចា អ្នកនាំពាក្យក្រសួង អប់រំ យុវជន និងកីឡា បានបញ្ជាក់ក្នុងពេលដែលលោកត្រូវបានសម្ភាសន៍ជាមួយកាសែតភ្នំពេញប៉ុស្តិ៍ ដោយរៀបរាប់ថា «ប្រជាជនកម្ពុជាចំនួន៧០ភាគរយដែលកំពុងរស់នៅសព្វថ្ងៃ មិនធ្លាប់ឆ្លងកាត់អំពើប្រល័យពូជសាសន៍ទេ។ ដូច្នេះការសិក្សាអំពីអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា និងនៅជុំវិញពិភពលោកនឹងជួយដល់អ្នកទាំងនោះឲ្យយល់អំពីប្រវត្តិសាស្ត្រនិងធ្វើជាមូលដ្ឋានសម្រាប់ការសន្ទនាអន្តរជំនាន់»។ លោកបានមានប្រសាសន៍បន្តថា«សង្គ្រាមលោកលើកទី១ និងទី២ និងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺជាផ្នែកមួយនៃកម្មវិធីសិក្សាសម្រាប់ថ្នាក់ទី៩ នាពេលបច្ចុប្បន្ន» ហើយថា «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការសម្លាប់រង្គាលត្រូវបានបង្រៀននៅថ្នាក់ទី១២»។លោកបាននិយាយទៀតថា «មានឯកសារបន្ថែមទៀតដែលក្រសួងអប់រំ យុវជន និងកីឡាបានបញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូ ដោយធ្វើការសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជារួមមាន៖ ឯកសារស្តីពីអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិអាមេនី, ជនជាតិជ្វីហ្វនៅអាល្លឺម៉ង់, ជនជាតិឃឺដនៅអ៊ីរ៉ាក់, ជនជាតិម៉ូស្លីមនៅបូស្នី និងជនជាតិទុតស៊ីនៅរវ៉ាន់ដាព្រមទាំងអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាដែរ»។

### សន្និដ្ឋាន

ជារួមសៀវភៅសិក្សាថ្មីនេះដែលមានការគាំទ្រ និងទទួលស្គាល់ជាផ្លូវការពីក្រសួងអប់រំយុវជន និងកីឡា មិនត្រឹមតែជាមធ្យោបាយ ដ៏មានប្រសិទ្ធភាពមួយក្នុងការបង្កើនចំណេះដឹងសង្គម និងការចងចាំជារួមពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាមធ្យោបាយដាក់លាក់មួយក្នុងការព្យាបាលរបួសផ្លូវចិត្តជនរងគ្រោះកម្ពុជាប្រមាណ៥លាននាក់ ដែលកំពុងរស់រានមានជីវិតពីរបបខ្មែរក្រហម និងចូលរួមចំណែកផ្សះផ្សាសង្គមកម្ពុជាទាំងមូល ព្រមទាំងជាមាគ៌ាដ៏ភ្លឺស្វាងមួយឆ្ពោះទៅរកការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាល និងអំពើហិង្សាធ្ងន់ធ្ងរនៅកម្ពុជាក្នុងពេលអនាគត។ **ផេង ពង្សរ៉ាស៊ី**

# ក្រុមគ្រួសារដែលបានស្នើសុំមាតុភូមិនិវត្តន៍ទៅប្រទេសកម្ពុជាប្រជាធិបតេយ្យវិញ

តាមរយៈឯកសារបេសកម្មរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ប្រចាំនៅប្រទេសបារាំង បានកត់ត្រាអំពីសំណើសុំធ្វើមាតុភូមិនិវត្តន៍ របស់ប្រជាជនខ្មែរមកប្រទេសកម្ពុជាវិញ នៅក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យចំនួន ២៣២រូប ដែលមាននៅក្នុងបញ្ជីឯកសារអាយ «I» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅក្នុងចំណោមអ្នកសុំធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាទាំងអស់នោះក៏មានង៉ូវ វើង និងកូនៗរបស់គាត់ដែរ។

ង៉ូវ វើង សញ្ជាតិខ្មែរកើតនៅថ្ងៃទី១ខែមករា ឆ្នាំ១៩១៣ នៅឃុំសំបូរ ស្រុករំដួលខេត្តស្វាយរៀង។ឪពុករបស់ង៉ូវវើងឈ្មោះង៉ូវ ម៉ែ និងម្តាយឈ្មោះនាងហេងហោស។ង៉ូវវើងមានមុខរបរធ្វើស្រែ។ ង៉ូវវើងបានរៀបការជាមួយនារីម្នាក់ឈ្មោះនាងហឿងរស់នៅក្នុងភូមិជាមួយគ្នា។ង៉ូវវើង និងក្រុមគ្រួសារបានចាកចេញពីប្រទេសកម្ពុជានៅថ្ងៃទី១៧ខែមេសាឆ្នាំ១៩៧៥ដោយបានឈប់សុំចតនៅប្រទេសហ្វីលីពីន និងសហរដ្ឋអាមេរិកមុនពេលទៅដល់ប្រទេសបារាំងនៅថ្ងៃទី៥ ខែមេសាឆ្នាំ១៩៧៦។ ពេលទៅដល់ប្រទេសបារាំងង៉ូវវើង និងក្រុមគ្រួសារបានស្នាក់នៅសណ្ឋាគារ ឌុយមូឡាំង២៧វិថីដូឡូហ្សេរទីក្រុងប៉ារីស។ ង៉ូវ វើង បានចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជានៅថ្ងៃទី៨ខែមេសាឆ្នាំ១៩៧៦ហើយក៏បានស្នើសុំប្តូរលិខិតឆ្លងដែន ដើម្បីសុំមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ ដោយមានការចុះហត្ថលេខារបស់សាមីខ្លួនផ្ទាល់ ធ្វើនៅប៉ារីសថ្ងៃទី៨ខែមេសាឆ្នាំ១៩៧៦។



ង៉ូវ វើង ជនភៀសខ្លួនកម្ពុជានៅឆ្នាំ១៩៧៥ ហើយសុំធ្វើមាតុភូមិនិវត្តន៍មកវិញឆ្នាំ១៩៧៦

ឯកសារស្នើសុំប្តូរលិខិតឆ្លងដែននេះត្រូវបានចុះលេខN 0593P និងមានក្រសួងត្រួតពិនិត្យឃើញថាព័ត៌មានខាងលើនេះត្រឹមត្រូវតាមលិខិតឆ្លងដែនចាស់។ ក្រសួងយល់ព្រមតាមសំណូមពររបស់សាមីជន(ង៉ូវវើង)។លិខិតនេះធ្វើនៅប៉ារីសថ្ងៃទី១៩មេសាឆ្នាំ១៩៧៦ ដែលមានអ្នកទទួលខុសត្រូវក្រសួងលិខិតឆ្លងដែន ចុះហត្ថលេខាដោយឈ្មោះ តាន់ សម្បត្តិ។ លិខិតឆ្លងដែននេះ យល់ស្របព្រមតាមសេចក្តីបញ្ជាក់ខាងលើធ្វើនៅប៉ារីសថ្ងៃទី១៩ ខែមេសាឆ្នាំ១៩៧៦ ដែលមានអ្នកទទួលខុសត្រូវក្រសួងកម្ពុជាចុះហត្ថលេខាដោយឈ្មោះប៊ីចុងទី។ បេសកកម្មសម្រេចចេញលិខិតឆ្លងដែន ឲ្យទៅសាមីជន (ង៉ូវវើង)។ ធ្វើនៅប៉ារីសថ្ងៃទី១៩ខែមេសាឆ្នាំ១៩៧៦ចុះហត្ថលេខាដោយឈ្មោះកែមធី(ជ.បេសកកម្ម)។ក្រៅពីមានលិខិតស្នើសុំមាតុភូមិនិវត្តន៍ទៅប្រទេសកម្ពុជារបស់ឈ្មោះង៉ូវ វើង ក៏មានលិខិតស្នើសុំមាតុភូមិនិវត្តន៍របស់កូនៗ គាត់ដូចខាង

ក្រោម៖

**១) ង៉ូវ ភេ ជាកូនស្រីច្បងរបស់ ង៉ូវ វើង និងជាប្រពន្ធរបស់មាសសំបាត់**

ង៉ូវ ភេ សញ្ជាតិខ្មែរកើតនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៣នៅឃុំសំបួរស្រុករំដួលខេត្តស្វាយរៀង។ ង៉ូវភេបានរៀបការជាមួយបុរសម្នាក់ឈ្មោះមាស សំបាត់នៅក្នុងឆ្នាំ១៩៧០។ង៉ូវភេមានកូនពីរនាក់។ កូនទី១)ឈ្មោះមាស ខ្មា កើតនៅឆ្នាំ១៩៧០និងកូនទី២)ឈ្មោះមាសវ៉ាតានា កើតនៅឆ្នាំ១៩៧៥។ ង៉ូវ ភេ ជាមួយក្រុមគ្រួសារបានចាកចេញពីប្រទេសកម្ពុជានៅថ្ងៃ១៧ខែមេសាឆ្នាំ១៩៧៥ ហើយបានចុះចតនៅហ្វីលីពីននិងសហរដ្ឋអាមេរិកមុនពេលទៅដល់ប្រទេសបារាំង នៅថ្ងៃទី៥ខែមេសាឆ្នាំ១៩៧៦។នៅថ្ងៃទី៨ខែមេសាឆ្នាំដដែលង៉ូវភេបានចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា ហើយបានសុំមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ។

ឯកសារស្នើសុំប្តូរលិខិតឆ្លងដែននេះ ត្រូវបានចុះលេខ N0952P និងមានក្រសួងត្រួតពិនិត្យឃើញថាព័ត៌មានខាងលើនេះត្រឹមត្រូវតាមលិខិតឆ្លងដែនចាស់។ក្រសួងយល់ស្របព្រមឲ្យតាមសំណូមពររបស់សាមីជន(ង៉ូវ ភេ)។លិខិតនេះធ្វើនៅប៉ារីសថ្ងៃទី១៩ មេសាឆ្នាំ១៩៧៦ ដែលមានអ្នកទទួលខុសត្រូវក្រសួងលិខិតឆ្លងដែនចុះហត្ថលេខា ដោយឈ្មោះ តាន់សម្បត្តិ។លិខិតឆ្លងដែននេះយល់ស្របព្រមតាមសេចក្តីបញ្ជាក់ខាងលើធ្វើនៅប៉ារីសថ្ងៃទី១៩ ខែមេសាឆ្នាំ១៩៧៦ ដែលមានអ្នកទទួលខុសត្រូវក្រសួងកម្ពុជា ចុះហត្ថលេខាដោយឈ្មោះប៊ឹចុងទី។បេសកកម្មសម្រេចចេញលិខិត ឆ្លងដែនឲ្យទៅសាមីជន(ង៉ូវភេ)។ធ្វើនៅប៉ារីស ថ្ងៃទី១៩ខែមេសា ឆ្នាំ១៩៧៦ចុះហត្ថលេខាដោយឈ្មោះកែមធី។

**២) មាស សំបាត់ ត្រូវជាកូនប្រសាររបស់ ង៉ូវ វើង និងជាប្តីរបស់ ង៉ូវ ភេ**



ង៉ូវ ភេ បានភៀសខ្លួនទៅក្រៅប្រទេសនៅឆ្នាំ១៧៥ ហើយសុំធ្វើមាតុភូមិនិវត្តន៍មកវិញឆ្នាំ១៩៧៦



មាស សំបាត់ ប្តីរបស់ ង៉ូវ ភេ បានភៀសខ្លួនទៅក្រៅប្រទេសនៅឆ្នាំ១៧៥ហើយសុំធ្វើមាតុភូមិនិវត្តន៍មកវិញឆ្នាំ១៩៧៦

មាស សំបាត់ សញ្ជាតិខ្មែរកើតនៅថ្ងៃទី៩ ខែឧសភាឆ្នាំ១៩៤៣ នៅមេសថ្ងក(ក្នុងស្រុកចន្ទ្រា) ស្រុកស្វាយទាបខេត្តស្វាយរៀង។ឪពុករបស់មាសសំបាត់ឈ្មោះមាសថុក។មាសសំបាត់ មានមុខងារជានាយរងកងទ័ពជើងទឹកមុនពេលខ្មែរក្រហមឡើងកាន់អំណាច។ មាស សំបាត់ បានចាកចេញទៅក្រៅប្រទេសជាមួយប្រពន្ធកូននៅថ្ងៃ១៧ខែមេសាឆ្នាំ១៩៧៥ ។មាសសំបាត់បានសុំចតនៅប្រទេសហ្វីលីពីន និងសហរដ្ឋអាមេរិកមុនពេលទៅដល់ប្រទេសបារាំងនៅថ្ងៃទី៥ ខែមេសាឆ្នាំ១៩៧៦។ ក្រោយមកនៅថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៧៥ ដដែលមាសសំបាត់ បានសុំចូលជាមួយរណសិរ្សរួបរួមជាតិកម្ពុជា ហើយស្នើសុំវិលត្រឡប់មកប្រទេសកម្ពុជាវិញ។

ឯកសារស្នើសុំប្តូរលិខិតឆ្លងដែននេះ ត្រូវបានចុះលេខ N0590P និងមានក្រសួងត្រួតពិនិត្យឃើញថាព័ត៌មានខាងលើនេះត្រឹមត្រូវតាមលិខិតឆ្លងដែនចាស់។ក្រសួងយល់ស្របព្រមឲ្យតាមសំណូមពររបស់សាមីជន(មាសសំបាត់)។លិខិតនេះធ្វើនៅប៉ារីសថ្ងៃទី១៩មេសា ឆ្នាំ១៩៧៦ ដែលមានអ្នកទទួលខុសត្រូវក្រសួងលិខិតឆ្លងដែន ចុះហត្ថលេខាដោយឈ្មោះគាន់សម្បត្តិ។ លិខិតឆ្លងដែននេះយល់ស្របព្រមតាមសេចក្តីបញ្ជាក់ខាងលើធ្វើនៅប៉ារីសថ្ងៃទី១៩ ខែមេសាឆ្នាំ១៩៧៦ដែលមានអ្នកទទួលខុសត្រូវក្រសួងកម្ពុជា ចុះហត្ថលេខាដោយឈ្មោះ ប៊ី ចុងទី ។ បេសកកម្មសម្រេចចេញលិខិតឆ្លងដែនឲ្យទៅសមីជន(មាសសំបាត់)។ ធ្វើនៅប៉ារីសថ្ងៃទី១៩ខែមេសាឆ្នាំ១៩៧៦ចុះហត្ថលេខាដោយ កែម ធី ។

### ៣) ង៉ូវ គឹមហួយ ជាកូនស្រីទី២របស់ ង៉ូវ វ៉េង

ង៉ូវ គឹមហួយ សញ្ជាតិខ្មែរកើតនៅថ្ងៃទី១១ ខែឧសភាឆ្នាំ១៩៥៨ នៅឃុំសំបួរស្រុករំដួលខេត្តស្វាយរៀង។ង៉ូវ គឹមហួយបានចាកចេញពីប្រទេសកម្ពុជាជាមួយឪពុកម្តាយនិងបងប្អូននៅថ្ងៃ១៧ ខែមេសាឆ្នាំ១៩៧៥ ហើយបានឈប់សំចតនៅប្រទេសហ្វីលីពីននិងសហរដ្ឋអាមេរិកមុនពេលទៅ ដល់ប្រទេសបារាំងនៅខែមេសាឆ្នាំ១៩៧៦។ ពេលទៅដល់ប្រទេសបារាំងង៉ូវគឹមហួយបានចូលរួម ជាមួយរណសិរ្សរួបរួមជាតិកម្ពុជាហើយស្នើសុំលិខិតឆ្លងដែនវិលត្រឡប់ មកប្រទេសកម្ពុជាវិញនៅថ្ងៃទី៨ខែមេសាឆ្នាំ១៩៧៦។

ឯកសារស្នើសុំប្តូរលិខិតឆ្លងដែននេះ ត្រូវបានចុះលេខ N0594P និងមានក្រសួងត្រួតពិនិត្យឃើញថាព័ត៌មានខាងលើនេះត្រឹមត្រូវតាមលិខិតឆ្លងដែនចាស់។ក្រសួងយល់ស្របព្រមឲ្យតាមសំណូមពររបស់សាមីជន(ង៉ូវ គឹមហួយ)។លិខិតនេះធ្វើនៅប៉ារីសថ្ងៃទី១៩មេសាឆ្នាំ១៩៧៦ ដែលមានអ្នកទទួលខុសត្រូវក្រសួងលិខិតឆ្លងដែន ចុះហត្ថលេខាដោយឈ្មោះគាន់សម្បត្តិ។ លិខិតឆ្លងដែននេះយល់ស្របព្រមតាមសេចក្តីបញ្ជាក់ខាងលើធ្វើនៅប៉ារីសថ្ងៃទី១៩ ខែមេសាឆ្នាំ១៩៧៦ដែលមានអ្នកទទួលខុសត្រូវក្រសួងកម្ពុជាចុះហត្ថលេខា ដោយ



ង៉ូវ សេដ្ឋា ជនភៀសខ្លួនកម្ពុជានៅឆ្នាំ១៩៧៥ ហើយសុំធ្វើមាតុភូមិនិវត្តន៍មកវិញឆ្នាំ១៩៧៦

ឈ្មោះប៊ីចុងទី។បេសកកម្មសម្រេចចេញលិខិតឆ្លងដែនឲ្យទៅសមីជន(ង៉ូវ គឹមហួយ)។ ធ្វើនៅប៉ារីសថ្ងៃទី១៩ខែមេសាឆ្នាំ១៩៧៦ចុះហត្ថលេខាដោយ កែម ធី ។

### ៤) ង៉ូវ គឹមសុក ត្រូវជាកូនប្រុសទី៣របស់ ង៉ូវ វើង

ង៉ូវ គឹម សុកសញ្ជាតិខ្មែរកើតនៅថ្ងៃទី១៩ ខែកុម្ភៈឆ្នាំ១៩៦១នៅឃុំសំបួរស្រុករំដួលខេត្តស្វាយរៀង។ ង៉ូវ គឹមសុក ជាមួយគ្រួសារបានចាកចេញពីប្រទេសកម្ពុជា នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយបានចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជានៅប្រទេសបារាំង។ ង៉ូវ គឹមសុកបានស្នើសុំត្រឡប់មកប្រទេសកម្ពុជាវិញនៅថ្ងៃទី៨ខែមេសាឆ្នាំ១៩៧៦។

ឯកសារស្នើសុំប្តូរលិខិតឆ្លងដែននេះត្រូវបានចុះលេខN 0595P និងមានក្រសួងត្រួតពិនិត្យឃើញថាព័ត៌មានខាងលើ



ង៉ូវ គឹមសុក ជនភៀសខ្លួនកម្ពុជានៅឆ្នាំ១៩៧៥
ហើយសុំធ្វើមាតុភូមិនិវត្តន៍មកវិញឆ្នាំ១៩៧៦

នេះត្រឹមត្រូវតាមលិខិតឆ្លងដែនចាស់។ ក្រសួងយល់ព្រមតាមសំណូមពររបស់សាមីជន(ង៉ូវ គឹមសុក)។លិខិតនេះធ្វើនៅប៉ារីសថ្ងៃទី១៩មេសាឆ្នាំ១៩៧៦ ដែលមានអ្នកទទួលខុសត្រូវក្រសួងលិខិតឆ្លងដែនចុះហត្ថលេខា ដោយឈ្មោះគាន់សម្បត្តិ។លិខិតឆ្លងដែននេះយល់ស្របព្រមតាម សេចក្តីបញ្ជាក់ខាងលើធ្វើនៅប៉ារីសថ្ងៃទី១៩ ខែមេសាឆ្នាំ១៩៧៦ ដែលមានអ្នកទទួលខុសត្រូវក្រសួងកម្ពុជាចុះហត្ថលេខាដោយឈ្មោះប៊ីចុងទី។ បេសកកម្មសម្រេចចេញលិខិតឆ្លងដែន ឲ្យទៅសាមីជន(ង៉ូវគឹមសុក)។ធ្វើនៅប៉ារីសថ្ងៃទី១៩ខែមេសា ឆ្នាំ១៩៧៦ចុះហត្ថលេខាដោយឈ្មោះកែមធី(ជ.បេសកកម្ម)។

### ៥) ង៉ូវ សេដ្ឋា ជាកូនស្រីពៅរបស់ ង៉ូវ វើង

ង៉ូវសេដ្ឋាសញ្ជាតិខ្មែរកើតនៅថ្ងៃទី២៥ខែមីនាឆ្នាំ១៩៦២ នៅឃុំសំបួរស្រុករំដួលខេត្តស្វាយរៀង។ ង៉ូវសេដ្ឋាបានចាកចេញពីប្រទេសកម្ពុជា ជាមួយឪពុកម្តាយនិងបង។ទៅប្រទេសបារាំង បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃ១៧ខែមេសាឆ្នាំ១៩៧៥។នៅថ្ងៃទី៨ខែមេសាឆ្នាំ១៩៧៦ង៉ូវសេដ្ឋាបានស្នើសុំលិខិតឆ្លងដែន វិលត្រឡប់មកប្រទេសកម្ពុជាជាមួយក្រុមគ្រួសារ។

ឯកសារស្នើសុំប្តូរលិខិតឆ្លងដែននេះ ត្រូវបានចុះលេខ N0591P និងមានក្រសួងត្រួតពិនិត្យឃើញថាព័ត៌មានខាងលើនេះត្រឹមត្រូវតាមលិខិតឆ្លងដែនចាស់។ក្រសួងយល់ស្របព្រមឲ្យតាមសំណូមពររបស់សាមីជន(ង៉ូវ សេដ្ឋា)។ លិខិតនេះធ្វើនៅប៉ារីសថ្ងៃទី១៩មេសាឆ្នាំ១៩៧៦ ដែលមានអ្នកទទួលខុសត្រូវក្រសួងលិខិតឆ្លងដែន ចុះហត្ថលេខាដោយឈ្មោះគាន់សម្បត្តិ។ លិខិតឆ្លងដែននេះយល់ស្របព្រមតាមសេចក្តីបញ្ជាក់ខាងលើធ្វើនៅប៉ារីសថ្ងៃទី១៩ ខែមេសាឆ្នាំ១៩៧៦ដែលមានអ្នកទទួលខុសត្រូវក្រសួងកម្ពុជាចុះហត្ថលេខា ដោយឈ្មោះប៊ីចុងទី។បេសកកម្មសម្រេចចេញលិខិតឆ្លងដែនឲ្យទៅសមីជន(ង៉ូវសេដ្ឋា)។ធ្វើនៅប៉ារីសថ្ងៃទី១៩ ខែមេសាឆ្នាំ១៩៧៦ចុះហត្ថលេខាដោយកែមធី ។

**ដាត ចាន់សុនិតា**



រូបថតក្របមុខ ៖ ង៉ូវ គីមហួយ ជនភៀសខ្លួនដែលបានសុំធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញក្នុងឆ្នាំ១៩៧៦
រូបថតក្របក្រោយ ៖ ទេសភាពនៅតាមផ្លូវលំក្នុងឃុំទឹកថ្លា ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង


**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 225, September 2018 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 0291 P.M/99, 2 August 1999.